# មូលដ្ឋានគ្រឹះនៃរបៀបវារៈ

# ស្ត្រី សន្តិភាព & សន្តិសុខ

## មេរៀននិងឱកាសសម្រាប់សន្តិភាពនៅកម្ពុជាប្រកបដោយចីរភាព



# សៀវភៅណែនាំ ស្តីពី មូលដ្ឋានគ្រឹះ នៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ

## មេរៀននិងឱកាសសម្រាប់កសាងសន្តិភាព នៅកម្ពុជាប្រកបដោយចីរភាព


**ទីប្រឹក្សា៖**

បណ្ឌិត ខេត ស៊ីវែល

**ក្រុមការងារតាក់តែងនៃ អង្គការនារីដើម្បីសន្តិភាព៖**

គ្រី ស៊ុយហៀង

ឈុន ចរិយា

ឡាវ ប៊ុនរិទ្ធី

**រចនាសៀវភៅដោយ ៖**

Malia Imayama

គឹម ស្រៀន



**ISBN : 978-9924-625-14-8**

**បោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជាក្នុងឆ្នាំ ២០២៥ ដោយអង្គការនារីដើម្បីសន្តិភាព**

www.wpmcambodia.org



**© អង្គការនារីដើម្បីសន្តិភាព២០២៥**

**រាជធានីភ្នំពេញ**

គំនិតផ្តួចផ្តើមនេះទទួលបានការឧបត្ថម្ភនិងគាំទ្រដោយ

AMPLIFY

The Asia Foundation

# មាតិកា


## ជំពូកទី ១. មូលដ្ឋានគ្រឹះជាសកល 1

១.១. ប្រវត្តិ និងសារៈសំខាន់ 3

១.២. គោលគំនិតស្នូលនិងការអនុវត្តស្របនឹងក្របខ័ណ្ឌសកល 6

១.៣. វចនាសម្ព័ន្ធសកលនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ 11

១.៤. សសរស្តម្ភប្រសព្វគ្នាទាំង៤ នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ 15

១.៥. យុវជន សន្តិភាព និងសន្តិសុខ 29

១.៦. បញ្ហាថ្មីៗដែលកំពុងលេចឡើង 31

## ជំពូកទី ២. បរិបទថ្នាក់តំបន់ 35

២.១. ការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងថ្នាក់តំបន់មួយចំនួន 37

២.២. តួនាទីនៃការតស៊ូមតិក្នុងថ្នាក់សកលនិងតំបន់ 41

២.៣. បញ្ហាប្រឈម និងឱកាសក្នុងថ្នាក់តំបន់ 44

២.៤. ការអនុវត្តល្អៗ៖ ករណីសិក្សាក្នុងថ្នាក់តំបន់ 47

## ជំពូកទី ៣. មូលដ្ឋានីយកម្មនៅថ្នាក់ប្រទេស 49

៣.១. សារៈសំខាន់នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា 49

៣.២. ឈ្វេងយល់ពីសសរស្តម្ភទាំង៤ ក្នុងបរិបទកម្ពុជា 57

៣.២.១ ការទប់ស្កាត់ 58

៣.២.៣ ការការពារ 63

៣.២.២ ការសង្គ្រោះនិងការស្តារឡើងវិញ 69

៣.២.៤ ការចូលរួម 75

## ឯកសារយោង 80

# អារម្ភកថា

យើងខ្ញុំពិតជាមានមោទនភាពនិងក្ដីសង្ឃឹមយ៉ាងជ្រាលជ្រៅ ក្នុងការបង្ហាញជូននូវសៀវភៅណែនាំស្ដីពី "មូលដ្ឋានគ្រឹះនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ"។ សៀវភៅណែនាំនេះ គឺមិនមែនគ្រាន់តែជាសៀវភៅប៉ុណ្ណោះទេ ប៉ុន្តែវាជាធនធានមួយសម្រាប់ការឆ្លុះបញ្ចាំងពីដំណើរការរួមមួយរបស់យើងឆ្ពោះទៅរកសន្តិភាព និង យុត្តិធម៌យេនឌ័រ នៅក្នុងប្រទេសកម្ពុជា។

របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គឺជាក្របខណ្ឌសកលមួយដែលកើតចេញពីសេចក្ដីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ ដែលបង្ហាញនូវចក្ខុវិស័យដែលជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ របៀបវារៈនេះ បានទទួលស្គាល់ថា សន្តិភាពដែលមាននិរន្តភាព គឺមិនអាចកើតមានបាននោះទេ ប្រសិនបើគ្មានការចូលរួមពេញលេញរបស់ស្ត្រី ហើយសន្តិភាពមិនមែនត្រឹមតែជាអវត្តមាននៃសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែគឺជាវត្តមាននៃភាពយុត្តិធម៌ សមភាព និងសេចក្តីថ្លៃថ្នូរសម្រាប់ទាំងអស់គ្នា។

នៅប្រទេសកម្ពុជា របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិភាព ពិតជាមានភាពពាក់ព័ន្ធជាខ្លាំង។ ប្រជាជនកម្ពុជាបានឆ្លងកាត់នូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងរ៉ាំរ៉ៃនៃសង្គ្រាម និងឆ្លងកាត់នូវដំណើរដ៏វែងឆ្ងាយនៃការស្តារប្រទេសឡើងវិញ។ ស្ត្រីបានក្លាយជាចំណុចស្នូលនៅក្នុងដំណើរការនេះ តាមរយៈការកសាងសហគមន៍ឡើងវិញ ថែរក្សាការចងចាំ និងដឹកនាំការស្តារឡើងវិញនៅក្នុងគ្រួសារនិងសហគមន៍។ តែយ៉ាងណាមិញ ការចូលរួមចំណែករបស់ពួកគេជាញឹកញាប់មិនទាន់ទទួលបានការទទួលស្គាល់នៅក្នុងដំណើរការស្វែងរកសន្តិភាពដែលមានលក្ខណៈផ្លូវការទេ។ សៀវភៅណែនាំនេះ នឹងចូលរួមចំណែកក្នុងការបង្ហាញចេញនូវការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការកសាងសន្តិភាព។

ភ័ស្តុតាងបានបញ្ជាក់ច្បាស់ថា នៅពេលដែលស្ត្រីត្រូវបានរួមបញ្ចូលនៅក្នុងដំណើរការស្វែងរកសន្តិភាព លទ្ធផលគឺមានភាពរឹងមាំ និងបរិយាបន្ន។ ការស្រាវជ្រាវបានបង្ហាញថា នៅពេលដែលស្ត្រីចូលរួមក្នុងដំណើរការស្វែងរកសន្តិភាព នោះលទ្ធភាពដែលកិច្ចព្រមព្រៀងសន្តិភាពអាចរក្សារយៈពេលបាន១៥ឆ្នាំ អាចកើនដល់ទៅ ៣៥%។ ជាងនេះទៅទៀត ប្រទេសដែលមានអត្រានៃសមភាពយេនឌ័រខ្ពស់ គឺមិនសូវមានទំនោរក្នុងការប្រើអំពើហិង្សាក្នុងការដោះស្រាយជម្លោះនោះទេ។ ទាំងនេះមិនគ្រាន់តែជាស្ថិតិប៉ុណ្ណោះទេ ប៉ុន្តែវាជាសក្ខីភាពនៃអំណាចនៃការកសាងសន្តិភាពដែលមានបរិយាបន្ន។

យើងខ្ញុំសង្ឃឹមថា សៀវភៅណែនាំនេះនឹងអាចជាធនធានអំណានមួយដ៏មានសារៈសំខាន់ និងជាជំនួយស្មារតីដល់អ្នកពាក់ព័ន្ធ ខណៈដែលប្រទេសកម្ពុជាកំពុងចាប់ផ្តើមដំណើរការនៃការរៀបចំផែនការសកម្មភាពជាតិស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ។ សៀវភៅណែនាំនេះបានផ្តល់ព័ត៌មានអំពីបរិបទសកល តំបន់ និងថ្នាក់ជាតិ សម្រាប់ការយល់ដឹង និងការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងប្រទេសកម្ពុជា។ ដោយទាញចេញពីបទពិសោធន៍របស់ប្រទេសកម្ពុជា ពីភាពជាអ្នកដឹកនាំនៅក្នុងការរក្សាសន្តិភាពអន្តរជាតិ រហូតដល់កេរ្តិ៍ដំណែលនៃយុត្តិធម៌អន្តរកាល និងការកើនឡើងនៃកិច្ចខំប្រឹងប្រែងរបស់ស្ត្រីមូលដ្ឋាន ធនធាននេះមានគោលបំណងផ្សារភ្ជាប់បទដ្ឋានសកលនេះ ជាមួយនឹងការអនុវត្តជាក់ស្តែងនៅថ្នាក់ប្រទេស។

សៀវភៅណែនាំនេះត្រូវបានចងក្រងឡើងសម្រាប់អ្នកប្រើប្រាស់ផ្សេងៗ រួមមាន មន្ត្រីរាជការ អង្គការសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ អ្នកកសាងសន្តិភាព អ្នកអប់រំ អ្នកស្រាវជ្រាវ និងសិស្សានុសិស្ស។ សៀវភៅណែនាំនេះមិនមែនសម្រាប់តែស្ត្រីប៉ុណ្ណោះទេ វាគឺសម្រាប់មនុស្សគ្រប់រូប ដែលជឿជាក់លើសន្តិភាពប្រកបដោយបរិយាបន្ននិងចីរភាព។ យើងម្នាក់ៗមានតួនាទីក្នុងការលើកកម្ពស់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។ មិនថាដោយការចូលរួមលុបបំបាត់ផ្នត់គំនិតយេនឌ័រអវិជ្ជមាន ការគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ឬកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពឱ្យមានបរិយាបន្ននិងអន្តរប្រសព្វ សកម្មភាពរួមគ្នារបស់យើងទាំងអស់គឺពិតជាមានសារៈសំខាន់ណាស់។

សៀវភៅណែនាំនេះក៏នឹងជជែកពី សន្តិសុខអាកាសធាតុ ការចូលរួមរបស់យុវជន និងបន្ទុកនៃការងារថែទាំដែលភាគច្រើនត្រូវបានគេមើលរំលង។ ជាពិសេស សៀវភៅនេះក៏អបអរចំពោះភាពធន់ និងការដឹកនាំរបស់ស្ត្រី ដែលទោះបីជាជួបប្រទះនឹងឧបសគ្គជាប្រព័ន្ធក៏ដោយ ក៏នៅតែបន្តចូលរួមកសាងអនាគតរបស់កម្ពុជា។

រួមគ្នា! ចូលរួមកសាងសង្គមកម្ពុជាមួយពោរពេញដោយសន្តិភាពប្រកបដោយបរិយាបន្ន យុត្តិធម៌យេនឌ័រ ហើយស្ត្រី និងក្មេងស្រីមកពីគ្រប់អត្តសញ្ញាណ សុទ្ធតែអាចរស់នៅដោយគ្មានភាពភ័យខ្លាច និងឈានដល់សក្តានុពលពេញលេញរបស់ខ្លួន។

ដោយក្តីស្រឡាញ់និងសាមគ្គីភាព!
អង្គការនារីដើម្បីសន្តិភាព

# ជំពូកទី ១

# មូលដ្ឋានគ្រឹះជាសកល

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១៣២៥ និងសេចក្តីសម្រេចជាបន្តបន្ទាប់នៃរបៀបវារៈស្រ្តី សន្តិភាព និងសន្តិសុខ (WPS) គឺជាក្របខ័ណ្ឌដ៏មានឥទ្ធិពលសំដៅធ្វើយ៉ាងណាឱ្យមានការចូលរួមពីស្ត្រីក្នុងការកសាងសន្តិភាព ការដោះស្រាយទំនាស់ និងការស្តារស្ថានភាពឡើងវិញក្រោយជម្លោះបានបញ្ចប់។

រយៈពេលជាង២ទសវត្សរ៍កន្លងទៅ របៀបវារៈនេះបានពង្រីកខ្លួនបន្ថែម ដើម្បីដោះស្រាយបញ្ហាដែលជាចំណុចតភ្ជាប់រវាងយេនឌ័រ សន្តិសុខ និងយុត្តិធម៌ជាសកល។ ដោយផ្តោតលើសសរស្តម្ភទាំងបួន រួមមានការទប់ស្កាត់ ការចូលរួម ការការពារ ការសង្គ្រោះនិងការស្តារឡើងវិញ។ ទោះបីជាមានការរីកចម្រើនក៏ដោយ ក៏នៅមានចំណុចខ្វះខាតមួយចំនួនក្នុងការប្រែក្លាយការប្តេជ្ញាចិត្តជាសកលនេះមកជាសមិទ្ធផលជាក់ស្តែងនៅមូលដ្ឋានជាពិសេសនៅក្នុងតំបន់ ដូចជាអាស៊ីអាគ្នេយ៍ជាដើម។

សៀវភៅណែនាំនេះមានគោលបំណងសិក្សាពីបរិបទជុំវិញរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសមួយបានឆ្លងកាត់ប្រវត្តិសាស្ត្រជាច្រើននៃភាពធន់និងការស្តារប្រទេសឡើងវិញក្រោយជម្លោះ។ តាមការឆ្លុះបញ្ចាំងពីបទពិសោធន៍ដ៏ពិសេសរបស់កម្ពុជា (ដូចជាភាពជាអ្នកដឹកនាំរបស់កម្ពុជាក្នុងកិច្ចការរក្សាសន្តិភាពនៅថ្នាក់អន្តរជាតិ យន្តការយុត្តិធម៌អន្តរកាលតាមរយៈសាលាក្តីខ្មែរក្រហម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន) យើងនឹងពិភាក្សាថា តើក្របខ័ណ្ឌ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ អាចជំរុញឱ្យមានសន្តិភាពយូរអង្វែងនៅថ្នាក់មូលដ្ឋានដូចម្តេចខ្លះ? សៀវភៅនេះចងក្រងឡើងជុំវិញប្រធានបទសំខាន់ៗនិងវិធីសាស្ត្រអនុវត្តជាក់ស្តែង ដោយផ្តល់នូវការវិភាគគ្រប់ជ្រុងជ្រោយលើក្របខ័ណ្ឌសកល ជាចាមវ័ន្តក្នុងតំបន់ និងវិធីសាស្ត្រថ្នាក់ជាតិជាក់លាក់សម្រាប់ប្រទេសកម្ពុជា។

ក្នុងជំពូកនីមួយៗ យើងពិនិត្យមើលឧបសគ្គផ្នែករចនាសម្ព័ន្ធ និងវប្បធម៌ដែលរារាំងវឌ្ឍនភាពនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS)។ ទន្ទឹមនឹងនេះក៏សាទរចំពោះជោគជ័យដែលសម្រេចបានដោយសង្គមស៊ីវិល រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ។

យើងរំលេចពីសារៈសំខាន់នៃអន្តរប្រសព្វ ការទទួលស្គាល់តម្រូវការផ្សេងៗគ្នារបស់ស្ត្រី រួមទាំងក្រុមងាយរងគ្រោះដទៃទៀត និងការរួមបញ្ចូលទស្សនៈទាននៃរបៀបវារៈពាក់ព័ន្ធផ្សេងទៀត ដូចជារបៀបវារៈ យុវជន សន្តិភាព និងសន្តិសុខ (YPS) និងសន្តិសុខអាកាសធាតុ។

ជំពូកចុងក្រោយនឹងផ្តល់ជាអនុសាសន៍ ដែលអាចជាការតម្រង់ទិសសម្រាប់ចំណុចចាប់ផ្តើម និងវិធីសាស្ត្រសហការក្នុងការអនុវត្ត របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្ពុជា។ ការធ្វើបែបនេះ អាចជួយកាត់បន្ថយគម្លាតរវាងគោលនយោបាយ និងការអនុវត្ត តាមរយៈការផ្តល់ឧទាហរណ៍ជាក់ស្តែងដល់ ស្ថាប័នរដ្ឋ សង្គមស៊ីវិល ម្ចាស់ជំនួយ និងអ្នកអនុវត្តនានា ដើម្បីជំរុញឱ្យមានផលជះវិជ្ជមានពោរពេញដោយអត្ថន័យ។

នៅក្នុងសៀវភៅណែនាំនេះ យើងក៏គូសបញ្ជាក់ពីសារៈសំខាន់នៃក្របខ័ណ្ឌការត្រួតពិនិត្យ ការវាយតម្លៃ និងការសិក្សា (MEL) ដើម្បីធានាថា គំនិតផ្តួចផ្តើមទាក់ទងនឹង របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅតែមានគណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

ស្របពេលដែលប្រទេសកម្ពុជាកំពុងបន្តដំណើរឆ្ពោះទៅកសាងសន្តិភាពមួយប្រកបដោយបរិយាបន្ន ចីរភាព

និងយុត្តិធម៌  យើងសង្ឃឹមថាសៀវភៅណែនាំនេះនឹងក្លាយជាធនធានសម្រាប់ភាគីពាក់ព័ន្ធដែលមានឆន្ទៈបញ្ច្រាបនូវយុត្តិធម៌យេនឌ័រទៅជាស្នូលនៃសន្តិសុខនិងអភិបាលកិច្ច។



# ១.១. ប្រវត្តិ និងសារៈសំខាន់

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បានលេចរូបរាងឡើងដើម្បីឆ្លើយតបជាសកលទៅនឹងផលប៉ះពាល់វិសមាមាត្រនៃជម្លោះមកលើស្ត្រីនិងក្មេងស្រី និងភាពចាំបាច់ជាបន្ទាន់ក្នុងការជំរុញឱ្យមានការចូលរួម ពីស្ត្រីនិងក្មេងស្រីនៅក្នុងដំណើរការកសាងសន្តិភាព និងរក្សាសន្តិសុខ។

មូលដ្ឋានគ្រឹះនៃរបៀបវារៈនេះកើតចេញពីការតស៊ូមតិជាច្រើនទសវត្សរ៍របស់ចលនាដែលដឹកនាំដោយស្ត្រី ស្ថាប័នសង្គមស៊ីវិល ព្រមទាំងអ្នកដែលធ្លាប់ឆ្លងកាត់និងរស់រានមានជីវិតពីសង្គ្រាម ដែលទាមទារឱ្យមានការទទួលស្គាល់បទពិសោធន៍ និងការរួមចំណែកថែរក្សាសន្តិភាពរបស់ពួកគេ។

ការអនុម័តលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ នៅខែតុលា ឆ្នាំ២០០០ គឺជាការបោះជំហានដ៏សំខាន់មួយនៅក្នុងគោលនយោបាយអន្តរជាតិ។ សេចក្តីសម្រេចនេះ ជាសេចក្តីសម្រេចលើកដំបូងដែលទទួលស្គាល់យ៉ាងច្បាស់ពីផលប៉ះពាល់វិសមាមាត្រនៃជម្លោះប្រដាប់អាវុធមកលើស្ត្រីនិងក្មេងស្រី។

ស្ត្រី និងក្មេងស្រីត្រូវបានទទួលស្គាល់ថា ជារឿយៗរងផលប៉ះពាល់ពីជម្លោះធ្ងន់ធ្ងរជាង បើប្រៀបធៀបនឹងក្រុមផ្សេង រួមទាំងការរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រដូចជាអំពើហិង្សាផ្លូវភេទ ការបណ្តេញចេញពីទីលំនៅដោយបង្ខំ និងការបាត់បង់ប្រាក់ចំណូល មុខរបរចិញ្ចឹមជីវិត។

សេចក្តីសម្រេចនេះបានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចការពារស្ត្រីនិងក្មេងស្រីចេញពីផលប៉ះពាល់ទាំងនោះ និងរួមបញ្ចូលទស្សនៈយេនឌ័រក្នុងការទប់ស្កាត់ ការរក្សាសន្តិភាព និងកិច្ចខិតខំប្រឹងប្រែងស្តារស្ថានភាពឡើងវិញក្រោយជម្លោះ។ សេចក្តីសម្រេចក៏បានអំពាវនាវឱ្យមានវិធានការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្អែកលើយេនឌ័រ ទាំងអំឡុងពេលនិងក្រោយជម្លោះផងដែរ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ បានដាក់ចេញនូវក្របខ័ណ្ឌសម្រាប់ដោះស្រាយបញ្ហាសិទ្ធិស្ត្រីនិងសមភាពយេនឌ័រក្នុងអំឡុងពេលនិងក្រោយជម្លោះ ដោយផ្តោតលើសសរស្តម្ភសំខាន់ចំនួន៤ គឺ

I. ការទប់ស្កាត់
II. ការការពារ
III. ការសង្គ្រោះនិងការស្តារឡើងវិញ
IV. ការចូលរួម។

រយៈពេល២៥ឆ្នាំកន្លងមក មានសេចក្តីសម្រេចជាបន្តបន្ទាប់ចំនួន៩ ដែលត្រូវបានអនុម័តបន្ថែមទៀតទាក់ទងនឹងក្របខ័ណ្ឌនេះ ដែលរួមបញ្ចូលគ្នាបង្កើតបានជារបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ១។ មុនពេលការអនុម័តជាផ្លូវការលើសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ តួនាទីរបស់ស្ត្រីក្នុងកិច្ចការសន្តិភាពនិងសន្តិសុខមិនទទួលបានការយកចិត្តទុកដាក់ជាលក្ខណៈប្រព័ន្ធតែម្តង។ កិច្ចព្រមព្រៀងសន្តិភាពជាច្រើនកន្លងមក ដែលជារឿយៗសម្របសម្រួលដោយតស្សរជនជាន់ខ្ពស់ជាបុរស ពោលគឺកម្ររួមបញ្ចូលស្ត្រី ឬផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីណាស់។

មុនពេលការអនុម័តជាផ្លូវការលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ តួនាទីរបស់ស្ត្រីក្នុងកិច្ចការសន្តិភាព និងសន្តិសុខបានផាត់ចេញពីប្រព័ន្ធ។ កិច្ចព្រមព្រៀងសន្តិភាពជាប្រវត្តិសាស្ត្រកន្លងមក ដែលជារឿយៗសម្របសម្រួលដោយតស្សរជនជាន់ខ្ពស់ជាបុរស ពោលគឺកម្ររួមបញ្ចូលស្ត្រី ឬផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីណាស់។

យ៉ាងណាមិញ ស្ត្រីតាំងពីដើមរៀងមកបានដើរតួនាទីជាតួអង្គដ៏សំខាន់ក្នុងការកសាងសន្តិភាពនៅថ្នាក់មូលដ្ឋាន តាមរយៈការសម្រុះសម្រួលវិវាទមូលដ្ឋាន ការផ្តល់សេវាចាំបាច់នានាក្នុងគ្រាមានវិបត្តិ និងការពង្រឹងភាព

ធន់នៅក្នុងសហគមន៍របស់ពួកគេ។

ជាក់ស្តែងនៅប្រទេសលីបេរីយ៉ា ការងារកសាងសន្តិភាពរបស់ស្ត្រី បានដើរតួយ៉ាងសំខាន់ក្នុងការបញ្ចប់សង្គ្រាមស៊ីវិលដែលអូសបន្លាយជាយូរនៅក្នុងប្រទេសនោះ២។ ស្ថាប័នជាច្រើនដូចជា Women of Liberia Mass Action for Peace បានប្រើមធ្យោបាយធ្វើបាតុកម្មអហិង្សា និងការតស៊ូមតិ ដើម្បីដាក់សម្ពាធលើភាគីជម្លោះឱ្យចូលរួមចរចាសន្តិភាព ដែលនៅទីបំផុតបានរួមចំណែកឱ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាព Accra ក្នុងឆ្នាំ២០០៣។

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ តំណាងឱ្យការផ្លាស់ប្តូរយ៉ាងទូលំទូលាយលើការយល់ឃើញជាសកលអំពីសន្តិភាពនិងសន្តិសុខ។ ជាប្រពៃណី សន្តិសុខត្រូវបានឱ្យនិយមន័យចេញពីក្របខណ្ឌយោធា ដោយផ្តោតលើអធិបតេយ្យភាពរបស់រដ្ឋ និងបូរណភាពទឹកដី។

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ធ្វើឱ្យមានការផ្លាស់ប្តូរពីការយល់ដឹងដ៏ចង្អៀតនេះ ទៅជាការបង្កើតឱ្យមាន ក្របខ័ណ្ឌសន្តិសុខមនុស្ស ដែលផ្តល់អាទិភាពដល់សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់បុគ្គលនិងសហគមន៍។ គេសម្គាល់ឃើញថា អសន្តិសុខសម្រាប់ស្ត្រីនៅក្នុងតំបន់ជម្លោះ ជារឿយៗផ្តើមឡើងពីវិសមភាពយេនឌ័រ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្អែកលើយេនឌ័រ និងការរើសអើងជាប្រព័ន្ធ ដែលបញ្ហាទាំងនេះទាមទារឱ្យមានដំណោះស្រាយគ្រប់ជ្រុងជ្រោយ និងដំណោះស្រាយដែលគិតគូរពីភាពប្រទាក់ក្រឡាគ្នានៃបញ្ហាទាំងនេះ។

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មានសារៈសំខាន់មិនត្រឹមតែក្នុងបរិបទជម្លោះនោះទេ តែរបៀបវារៈនេះបានដាក់ចេញនូវផែនទីចង្អុលផ្លូវសម្រាប់ការរួមបញ្ចូលទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយសន្តិសុខជាតិនិងតំបន់ បេសកកម្មរក្សាសន្តិភាព និងក្របខ័ណ្ឌការអភិវឌ្ឍន៍។ ប្រទេសជាង១០០ បានអនុម័តផែនការសកម្មភាពថ្នាក់ជាតិ (NAP) ដើម្បីអនុវត្តគោលការណ៍ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅកម្រិតថ្នាក់ជាតិរបស់ខ្លួន៣។ ផែនការទាំងនេះមានវិសាលភាព និងផលជះខុសៗគ្នា ដែលឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាប្រឈម និងអាទិភាពផ្សេងៗគ្នាក្នុងបរិបទនីមួយៗ។ ឧទាហរណ៍ ផែនការឆ្នាំ២០២៣-២០៣៣ របស់ប្រទេសហ្វីលីពីនសំដៅពង្រឹងកិច្ចសហការរបស់រដ្ឋាភិបាលជាមួយស្ថាប័នសង្គមស៊ីវិល និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងដំណើរការសន្តិភាពនៅមូលដ្ឋាន រីឯផែនការសកម្មភាពថ្នាក់ជាតិ ឆ្នាំ២០២៤ របស់ប្រទេសកូឡុំប៊ីផ្តោតលើយុត្តិធម៌អន្តរកាលបែបបរិយាបន្ន និងការការពារជនរងគ្រោះចេញពីអំពើហិង្សាផ្អែកលើយេនឌ័រ [៤,៥]។

ទោះជាមានការវិវឌ្ឍទៅមុខគួរឱ្យកត់សម្គាល់ ក៏របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅតែជួបបញ្ហាប្រឈមធំៗជាច្រើន។ នៅទូទាំងពិភពលោក តំណាងស្ត្រីក្នុងថ្នាក់ដឹកនាំនៅមានភាគរយតិចតួចនៅឡើងក្នុងដំណើរការស្វែងរកសន្តិភាពបែបផ្លូវការ (តិចជាង១០% នៃអ្នកចរចាកិច្ចព្រមព្រៀងសន្តិភាព) [៦]។ ទោះជាការពិតដែលថា៖

“ការស្រាវជ្រាវបានបង្ហាញថា ប្រទេសដែលមានកម្រិតសមភាពយេនឌ័រកាន់តែខ្ពស់ ទំនងជាអាចដោះស្រាយជម្លោះដោយអហិង្សា ហើយទំនងជាមិនប្រើប្រាស់កម្លាំងយោធា ដើម្បីដោះស្រាយជម្លោះអន្តរជាតិឡើយ...។ ផ្ទុយទៅវិញ ប្រទេសដែលមានគម្លាតយេនឌ័រខ្លាំង មានភាពទោរទន់ក្នុងការពាក់ព័ន្ធនឹងជម្លោះក្នុងប្រទេស និងក្រៅប្រទេសច្រើន” [៧,៨] ។

គម្លាតក្នុងការអនុវត្តនៅតែបន្តកើតមាន ជាពិសេសនៅតាមរដ្ឋដែលមានភាពផុយស្រួយផ្នែកសន្តិភាព និងរងផលប៉ះពាល់ដោយជម្លោះ ដែលជារឿយៗធនធាន និងឆន្ទៈនយោបាយនៅមានកម្រិត។ លើសពីនេះ ការកើនឡើងនៃលទ្ធិផ្តាច់ការនិងហិង្សាជ្រុលនិយមក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានបង្កការគំរាមកំហែងដល់សិទ្ធិស្ត្រី និងលំហសេរីភាពសង្គមស៊ីវិល ដែលបានបង្កជាឱនភាពដល់សមិទ្ធផលកើតចេញពីក្របខ័ណ្ឌ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) [៩] ។

ទោះជាយ៉ាងណា ក៏របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅតែជាយន្តការដ៏សំខាន់ក្នុងការជំរុញឱ្យមានសមភាពយេនឌ័រ និងការកសាងសន្តិភាពប្រកបដោយចីរភាព។ ការផ្តោតកាន់តែខ្លាំងលើភាពប្រទាក់ក្រឡាគ្នា (ការទទួលស្គាល់ពីរបៀបដែលកត្តាផ្សេងៗ ដូចជាកត្តាជនជាតិ ឋានៈសេដ្ឋកិច្ចសង្គម ឬពិការភាព ដែលប្រសព្វជាមួយអត្តសញ្ញាណយេនឌ័រ ក្នុងការបង្កើតជាបទពិសោធន៍នៃការរងគ្រោះ ខុសគ្នា ពីម្នាក់ទៅម្នាក់) បានអនុញ្ញាតឱ្យមានការប្រើប្រាស់វិធីសាស្ត្រកាន់តែមានបរិយាបន្នក្នុងកិច្ចការសន្តិសុខនិងការកសាងសន្តិភាព។

តាមបទពិសោធន៍របស់ស្ត្រីនិងក្មេងស្រី ជាពិសេស អ្នកមកពីសហគមន៍ងាយរងគ្រោះ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ប្រឆាំងនឹងបញ្ហារចនាសម្ព័ន្ធនៃអំណាចដែលបន្តធ្វើឱ្យកើតមានជម្លោះនិងវិសមភាព។

ការអនុម័តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មិនមែនត្រឹមតែជានិមិត្តរូបជោគជ័យប៉ុណ្ណោះទេ ថែមទាំងជាសក្ខីភាពបញ្ជាក់ពីឥទ្ធិពលនៃការតស៊ូមតិ និងសារៈសំខាន់ដ៏ចំបាច់ក្នុងការបញ្ជ្រាបនូវទស្សនៈយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីរក្សាសន្តិភាពនិងសន្តិសុខសកល។

*សេចក្តីសម្រេចជាបន្តបន្ទាប់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិពាក់ព័ន្ធនឹង សេចក្តីសម្រេច លើរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ លេខ១៣២៥ រួមមាន៖*

- *សេចក្តីសម្រេចលេខ១៨២០ ចុះថ្ងៃទី១៩ មិថុនា ២០០៨*
- *សេចក្តីសម្រេចលេខ១៨៨៨ ចុះថ្ងៃទី៣០ កញ្ញា ២០០៩*
- *សេចក្តីសម្រេចលេខ១៨៨៩ ចុះថ្ងៃទី៣០ កញ្ញា ២០១០*
- *សេចក្តីសម្រេចលេខ១៩៦០ ចុះថ្ងៃទី១៦ ធ្នូ ២០១០*
- *សេចក្តីសម្រេចលេខ២១០៦ ចុះថ្ងៃទី២៤ មិថុនា ២០១៣*
- *សេចក្តីសម្រេចលេខ២១២២ ចុះថ្ងៃទី១៨ តុលា ២០១៣*
- *សេចក្តីសម្រេចលេខ២២៤២ ចុះថ្ងៃទី១៣ តុលា ២០១៥*
- *សេចក្តីសម្រេចលេខ២៤៦៧ ចុះថ្ងៃទី២៣ មេសា ២០១៩*
- *សេចក្តីសម្រេចលេខ២៤៩៣ ចុះថ្ងៃទី២៩ តុលា ២០១៩។*

# ១.២. គោលគំនិតស្នូលនិងការអនុវត្តស្របនឹងក្របខ័ណ្ឌសកល

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បង្កើតឡើងដោយទទួលស្គាល់ថា **សន្តិភាពប្រកបដោយចីរភាពនឹងមិនអាចសម្រេចបានបើគ្មានការជាមួយពីសំណាក់ស្ត្រីឱ្យបានពេញលេញ** និងការទទួលស្គាល់ពីបទពិសោធន៍សង្គ្រាមដែលមនុស្សម្នាក់ៗទទួលបានខុសៗគ្នា ដោយសារកត្តាយេនឌ័ររបស់ពួកគេ។

របៀបវារៈនេះបានកំណត់ឡើងវិញនូវកិច្ចការសន្តិសុខបែបប្រពៃណី ដោយផ្លាស់ប្តូរពីការផ្តោតលើគោលគំនិតក្នុងការពង្រឹងតែសមត្ថភាពយោធារបស់រដ្ឋ ទៅជាការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខមនុស្ស ដែលផ្តោតលើសិទ្ធិ និងសុខុមាលភាពរបស់បុគ្គលម្នាក់ៗ ជាពិសេសស្ត្រី និងក្មេងស្រីមកពីអត្តសញ្ញាណចម្រុះគ្រប់រូប។

ខ្លឹមសារគោលរបស់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ គឺដោះស្រាយបញ្ហាវិសមភាពបែបរចនាសម្ព័ន្ធដែលបង្កជម្លោះ និងការផាត់ចេញ ខណៈពេលដែលបន្តធ្វើការលើកកម្ពស់ការកសាងសន្តិភាពប្រកបដោយបរិយាបន្ន និងចីរភាព។

## គោលគំនិតស្នូលរបស់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ

### ១.សន្តិសុខមនុស្សជាគ្រឹះនៃសន្តិភាព៖

ខុសពីទស្សនៈសន្តិសុខបែបប្រពៃណី ដែលផ្តល់អាទិភាពដល់អធិបតេយ្យភាពជាតិ និងអំណាចយោធាតែមួយមុខ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ សង្កត់ធ្ងន់លើសន្តិសុខមនុស្សផងដែរ ដោយដោះស្រាយការគំរាមកំហែងផ្នែកសេដ្ឋកិច្ច បរិស្ថាន និងការគំរាមកំហែងផ្ទាល់ខ្លួនចំពោះបុគ្គល និងសហគមន៍។ ស្ត្រី និងក្មេងស្រី ដែលជារឿយៗប្រឈមនឹងភាពងាយរងគ្រោះផ្សេងៗបែបប្រឡាក់ក្រឡាគ្នាក្នុងអំឡុងពេលមានវិបត្តិ គឺជាចំណុចសំខាន់ក្នុងក្របខ័ណ្ឌនេះ។ ការធានាសុវត្ថិភាព ស្វ័យភាព និងការចូលរួមរបស់ពួកគេអាចបង្កើតលក្ខខណ្ឌសម្រាប់សន្តិភាពយូរអង្វែង។

### ២.យុត្តិធម៌ប្រកបដោយចីរភាព៖

យុត្តិធម៌ប្រកបដោយចីរភាពមានសារៈសំខាន់ណាស់ចំពោះ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដែលមិនត្រឹមតែដោះស្រាយគ្រោះថ្នាក់ភ្លាមៗនៃអំពើហិង្សាប៉ុណ្ណោះទេ ថែមទាំងដោះស្រាយវិសមភាពជាប្រព័ន្ធក្នុងសង្គមដែលបង្កឱ្យមានអំពើហិង្សានោះផងដែរ។

វិធីសាស្ត្រនេះមានបំណងកសាងទំនាក់ទំនងឡើងវិញ ស្តារសេចក្តីថ្លៃថ្នូរដល់អ្នករស់រានមានជីវិត និងធ្វើបរិវត្តកម្មប្រព័ន្ធគាបសង្កត់ ដើម្បីទប់ស្កាត់អំពើហិង្សានាពេលអនាគត។ ឧទាហរណ៍ យន្តការស្វែងរកការពិតនិងការផ្សះផ្សា ដែលរួមបញ្ចូលសំឡេងរបស់ស្ត្រីនៅប្រទេសកូឡុំប៊ី[10] ។

## ៣. ការគិតគូរពីអន្តរប្រសព្វក្នុងការកសាងសន្តិភាព៖

អន្តរប្រសព្វទទួលស្គាល់ថា បទពិសោធន៍នៃជម្លោះ និងសន្តិភាពត្រូវបានកំណត់ដោយអត្តសញ្ញាណត្រួតគ្នា ដូចជាជាតិសាសន៍ ស្ថានភាពសេដ្ឋកិច្ចសង្គម អត្តសញ្ញាណយេនឌ័រ ពិការភាព និងអាយុ ជាដើម។

គោលគំនិតនេះធានាថាយុទ្ធសាស្ត្រ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ រួមបញ្ចូលស្ត្រីទាំងអស់ ជាពិសេសស្ត្រីមានអត្តសញ្ញាណចម្រុះផ្សេងៗមកពីសហគមន៍ងាយរងគ្រោះ។ឧទាហរណ៍ ការរួមបញ្ចូលស្ត្រីជនជាតិដើម និងជនជាតិភាគតិចនៅក្នុងដំណើរការសន្តិភាពក្នុងមូលដ្ឋាន រំលេចនូវទស្សនវិស័យដ៏មានតម្លៃនេះ ដែលជារឿយៗត្រូវបានគេមើលរំលងនៅក្នុងក្របខ័ណ្ឌធំៗ។

## 4. ភាពជាម្ចាស់ការ និងការធ្វើមូលដ្ឋានីយកម្ម៖

របៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ធ្វើការទទួលស្គាល់តួនាទីដ៏សំខាន់នៃការដឹកនាំរបស់ស្ត្រីនៅមូលដ្ឋានក្នុងការកសាងសន្តិភាព។ បណ្តាញ និងស្ថាប័នដឹកនាំដោយស្ត្រីនៅមូលដ្ឋាន តែងតែជាអ្នកឆ្លើយតបមុនគេ នៅក្នុងសហគមន៍រងផលប៉ះពាល់ពីជម្លោះ ដោយចូលរួមក្នុងការសម្រុះសម្រួលទំនាស់ និងការផ្តល់ការគាំទ្រផ្នែកសង្គម។ ការគាំទ្រការងាររបស់ពួកគេ មិនត្រឹមតែបង្កើនភាពស្របច្បាប់ក្នុងដំណើរការសន្តិភាពប៉ុណ្ណោះទេ ថែមទាំងធានាបានថា ដំណោះស្រាយនោះត្រូវនឹងវប្បធម៌ តម្រូវការ និងមាននិរន្តភាពទៀតដែរ។

## ៥. យន្តការគណនេយ្យភាពដែលឆ្លើយតបនឹងយេនឌ័រ៖

ការដាក់រដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យទទួលខុសត្រូវ ចំពោះការអនុវត្តការប្តេជ្ញាចិត្តចំពោះ របៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ គឺជាមូលដ្ឋានគ្រឹះនៃរបៀបវារៈនេះ។ យន្តការដូចជាផែនការសកម្មភាពជាតិ (NAP) របាយការណ៍ស្រមោលនៃអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) និងការត្រួតពិនិត្យឯករាជ្យដោយសង្គមស៊ីវិល អាចជួយបង្កើនតម្លាភាព និងពង្រឹងការអនុវត្ត។

## 6. សន្តិភាពប្រកបដោយចីរភាព៖

សន្តិភាពប្រកបដោយចីរភាព គឺលើសពីការបញ្ចប់នៃសង្គ្រាមឬបញ្ឈប់ការប្រើប្រាស់អំពើហិង្សាដោយផ្ទាល់ (ដែលជាទូទៅហៅថា សន្តិភាពអវិជ្ជមាន) និងធ្វើការដោះស្រាយឫសគល់នៃទំនាស់ ដោយជំនះប្រព័ន្ធនៃការរំលោភបំពាន វិសមភាព និងការផាត់ចេញ។ វាមានគោលបំណងក្នុងការកសាងឡើងវិញនូវទំនាក់ទំនង ស្ថាប័ន និងបទដ្ឋានសង្គម តាមរយៈការផ្សព្វផ្សាយភាពយុត្តិធម៌ បរិយាបន្ន និងភាពធន់។

ទស្សនៈនេះស្របទៅនឹងទស្សនដែលអ្នកសិក្សាពីសន្តិភាពហៅថា សន្តិភាពវិជ្ជមាន ដែលទទួលស្គាល់ពីតម្រូវការនៃការផ្លាស់ប្តូរបែបរចនាសម្ព័ន្ធយ៉ាងស៊ីជម្រៅ ដើម្បីការពារការកើតឡើងវិញនៃសង្គ្រាមនាពេលអនាគតជាជាងការផ្តោតទៅលើស្ថិរភាពរយៈពេលខ្លី។ វិធីសាស្ត្រនេះផ្តោតទៅលើការចូលរួម និងភាពជាអ្នកដឹកនាំរបស់ក្រុមងាយរងគ្រោះ ជាពិសេសស្ត្រី ជនជាតិភាគតិច សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ជាដើម ក្នុងការសម្រេចបាននូវលទ្ធផលដែលមានស្ថិរភាព និងយុត្តិធម៌។

# និយមន័យទាក់ទងនឹងសន្តិភាព

ការស្វែងយល់ពីភាពខុសគ្នាទៅលើប្រភេទនៃកិច្ចការងារសន្តិភាព គឺជាគន្លឹះនៃការដឹកនាំការងារសន្តិភាព និងសន្តិសុខ។ ទោះបីជាពាក្យទាំងនេះត្រូវបានប្រើជាញឹកញាប់ជំនួសគ្នាក៏ដោយ វាក៏មានអត្ថន័យ និងការអនុវត្តផ្សេងៗគ្នាដែរ។

**ការរក្សាសន្តិភាព (Peacekeeping)៖**

ការរក្សាសន្តិភាព សំដៅដល់ការបញ្ជូនកងកម្លាំងរក្សាសន្តិភាពអន្តរជាតិ ក្រោមការគ្រប់គ្រងចាត់ចែងដោយអង្គការសហប្រជាជាតិ ដើម្បីជួយរក្សាបទឈប់បាញ់ និងការពារការកើតឡើងវិញនៃអំពើហិង្សា នៅក្នុងតំបន់ដែលរងផលប៉ះពាល់ពីជម្លោះ។ ការរក្សាសន្តិភាពនេះ មានការចូលរួមពីកងទ័ព និងកងកម្លាំងប៉ូលីស ក្រោមការឃ្លាំមើលយ៉ាងតឹងរ៉ឹង អព្យាក្រឹត និងមិនប្រើកម្លាំង លើកលែងតែក្នុងករណីការពារខ្លួន។ ខណៈពេលដែលដំណើរការនៃការរក្សាសន្តិភាពមានសារៈសំខាន់ក្នុងការធ្វើឱ្យមានស្ថិរភាព វិធីសាស្ត្រនៅមានកម្រិតនៅឡើយ ដោយសារវាពុំបានផ្តោតលើការដោះស្រាយឫសគល់នៃជម្លោះនោះទេ។

**ការបង្កើតសន្តិភាព (Peacemaking)៖**

ការបង្កើតសន្តិភាព គឺជាកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការចរចា និងជំរុញឱ្យមានការបញ្ចប់ជម្លោះ ដែលរួមមានការចរចាតាមបែបការទូត ការចរចាកម្រិតថ្នាក់ដឹកនាំ និងដំណើរការសន្ទនាជាផ្លូវការ ក្នុងគោលបំណងដើម្បីបញ្ឈប់ការបាញ់បោះ ឬឈានដល់កិច្ចព្រមព្រៀងនយោបាយណាមួយ។ ការបង្កើតសន្តិភាពភាគច្រើនត្រូវបានដឹកនាំដោយតួអង្គជាតិ ឬអន្តរជាតិ ប៉ុន្តែក៏អាចមើលរំលងសំឡេងសហគមន៍ដែរ ប្រសិនបើមិនបានតាក់តែងឲ្យមានបរិយាបន្ន។

**ការកសាងសន្តិភាព (Peacebuilding)៖**

ការកសាងសន្តិភាព ផ្តោតលើការដោះស្រាយបញ្ហាចាក់ស្រេះនៃជម្លោះ ដើម្បីបង្កើតឱ្យមានសន្តិភាពយូរអង្វែង។ វាមានសកម្មភាពជាច្រើនដូចជាការស្វែងរកយុត្តិធម៌និងការផ្សះផ្សា ការអប់រំ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ល។ ដែលមានគោលបំណងធ្វើបរិវត្តកម្មលើទំនាក់ទំនង ស្ថាប័ន និងវិសមភាពនៃរចនាសម្ព័ន្ធ។ ការកសាងសន្តិភាព ជាទូទៅត្រូវបានជំរុញដោយសហគមន៍មូលដ្ឋាន ហើយកើតមានមុន ក្នុងកំឡុងពេល និងក្រោយជម្លោះហិង្សា។

**ដំណើរការសន្តិភាព (Peace Processes)៖**

«ដំណើរការសន្តិភាព» សំដៅទៅលើគំនិតផ្តួចផ្តើមជាលំដាប់ទូទៅ ដែលមានគោលបំណងដោះស្រាយជម្លោះ និងបង្កើតសន្តិភាពប្រកបដោយចីរភាព។ ដំណើរការទាំងនេះរួមមាន៖ ការចរចាផ្លូវការ កិច្ចព្រមព្រៀងសន្តិភាព និងយន្តការអនុវត្ត ប៉ុន្តែក៏រួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងមិនផ្លូវការ និងនៅកម្រិតមូលដ្ឋានផងដែរ។ ទោះបីជា «ដំណើរការសន្តិភាព» អាចបង្ហាញថា ជាព្រឹត្តិការណ៍ ឬពេលវេលាមួយក៏ដោយ ប៉ុន្តែជាក់ស្តែងវាមានភាពស្មុគស្មាញ និងមិនតាមលំដាប់លំដោយទេ ដែលអាចមានទាំងភាពរអាក់រអួល និងការរីកចម្រើន។

# ភាពស្របគ្នានៃក្របខ័ណ្ឌសកល

## ១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)៖

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្តល់នូវ **ក្របខ័ណ្ឌបំពេញបន្ថែម**ដល់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីដោះស្រាយឫសគល់ជាប្រព័ន្ធនៃវិសមភាព និងទំនាស់។ គោលដៅទី៥ (សមភាពយេនឌ័រ) បង្ហាញគោលបំណងយ៉ាងច្បាស់ក្នុងការលុបបំបាត់រាល់ទម្រង់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ចំណែកគោលដៅទី១៦ (សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ) បង្ហាញពីសារៈសំខាន់នៃការសម្រេចចិត្តប្រកបដោយបរិយាបន្ននិងភាពជានីតិរដ្ឋ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសបញ្ជាក់អំពីទំនាក់ទំនងយេនឌ័រ ការអភិវឌ្ឍ និងការកសាងសន្តិភាព។

## ២ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) និងអនុសាសន៍ទូទៅលេខ៣០៖

អនុសញ្ញា លុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ CEDAW ជាពិសេសអនុសាសន៍ទូទៅលេខ៣០ គឺជាក្របខ័ណ្ឌច្បាប់ដ៏សំខាន់ដែលគាំទ្ររបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ។ អនុសញ្ញានេះ នាំមកនូវការគិតគូរពីគោលការណ៍សិទ្ធិមនុស្សនៅក្នុងបរិបទរងផលប៉ះពាល់ដោយជម្លោះ ដែលក្នុងនោះមានបទប្បញ្ញត្តិចែងពីការចូលរួមរបស់ស្ត្រីក្នុងការទប់ស្កាត់និងស្តារស្ថានភាពក្រោយទំនាស់។ អនុសញ្ញានេះក៏សង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវរបស់រដ្ឋសម្រាប់ការដោះស្រាយការរើសអើងជារចនាសម្ព័ន្ធនិងលើកកម្ពស់ប្រព័ន្ធយុត្តិធម៌យេនឌ័រ។

## ៣ សេចក្តីប្រកាសនិងវេទិកាសម្រាប់ផែនការសកម្មភាពទីក្រុងប៉េកាំង (១៩៩៥)៖

សេចក្តីប្រកាសនិងវេទិកាសម្រាប់ផែនការសកម្មភាពទីក្រុងប៉េកាំង (១៩៩៥)៖ ក្រមខណ្ឌនេះបានត្រួសត្រាយផ្លូវសម្រាប់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដោយកំណត់យកស្ត្រីនិងទំនាស់ប្រដាប់អាវុធជាចំណុចគួរឱ្យព្រួយបារម្ភ។ ក្របខ័ណ្ឌក៏បានអំពាវនាវឱ្យបង្កើនភាពជាតំណាងរបស់ស្ត្រីក្នុងការដោះស្រាយទំនាស់ ការទម្លាក់អាវុធ និងការស្តារឡើងវិញក្រោយជម្លោះ។ រយៈពេល៣០ឆ្នាំកន្លងមកនេះ វេទិកាសម្រាប់ផែនការសកម្មភាពទីក្រុងប៉េកាំងនៅតែជាឧបករណ៍តស៊ូមតិដ៏សំខាន់សម្រាប់ផ្សាភ្ជាប់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ទៅនឹងរបៀបវារៈសមភាពយេនឌ័រ ផ្សេងៗទៀត។

## ៤ ក្របខ័ណ្ឌមនុស្សធម៌និងជនភៀសខ្លួន៖

ក្របខ័ណ្ឌមនុស្សធម៌ ដូចជា កិច្ចព្រមព្រៀងជាសកលស្តីពីជនភៀសខ្លួននិងធម្មនុញ្ញមនុស្សធម៌ និងស្តង់ដាអប្បបរមាក្នុងការឆ្លើយតបបញ្ហាមនុស្សធម៌ ឬដែលគេស្គាល់ជាភាសាអង់គ្លេសថា Global Compact on Refugees and Sphere Standards និងស្ថាប័នផ្សេងទៀត ដូចជាទីភ្នាក់ងារទទួលបន្ទុកអំពើហិង្សាផ្អែកលើយេនឌ័រ (GBV AoR) បានជួយបំពេញបន្ថែមរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈការដោះស្រាយផលប៉ះពាល់ផ្អែកលើយេនឌ័រនៃការផ្លាស់ទីលំនៅដោយបង្ខំនិងវិបត្តិផ្សេងៗ។ ក្របខ័ណ្ឌទាំងនោះពង្រឹងឡើងវិញនូវតម្រូវការការពារ និងការចូលរួមរបស់ស្ត្រីនិងក្មេងស្រីក្នុងការឆ្លើយតបបញ្ហាមនុស្សធម៌ ដោយធានាថាតម្រូវការជាក់លាក់របស់ពួកគេបានបំពេញ ហើយសំឡេងពួកគេបានយកទៅពិចារណា[១១]។

## ៥ ការធ្វើសមាហរណកម្មក្របខ័ណ្ឌសិទ្ធិមនុស្សទូលំទូលាយផ្សេងទៀត៖

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មានចំណុចប្រសព្វនឹងអត្ថបទសិទ្ធិមនុស្សជាសកលជាច្រើន ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)។ ទំនាក់ទំនងនេះផ្តល់ជាមូលដ្ឋានរួមសម្រាប់ការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងស្ថានភាពជម្លោះ គ្រោះមហន្តរាយ និងស្ថានភាពគ្រាអាសន្នផ្សេងៗទៀត លើកកម្ពស់សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ស្ត្រីនិងក្មេងស្រី និងមានបំណងលើកកម្ពស់សមភាពក្នុងគ្រប់ផ្នែកនៃកិច្ចការសន្តិភាពនិងសន្តិសុខ។

*នៅកម្រិតអន្តរជាតិនៃដំណើរការសន្តិភាពពិភពលោក ការស្រាវជ្រាវបានរកឃើញថា នៅពេលដែលស្ត្រីត្រូវបានរួមបញ្ចូលនៅក្នុងដំណើរការសន្តិភាព មានការកើនឡើង ២០% នៃការព្រមព្រៀងដែលអាចបន្តបានយ៉ាងហោចណាស់ ២ ឆ្នាំ ហើយមានការកើនឡើង ៣៥% នៃការព្រមព្រៀងដែលអាចបន្តបានយ៉ាងហោចណាស់ ១៥ ឆ្នាំ។*

# ១.៣. រចនាសម្ព័ន្ធសកលនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ តំណាងឱ្យក្របខ័ណ្ឌមួយដែលមានការវិវត្ត និងទំនាក់ទំនងគ្នាទៅវិញទៅមក នៃការប្តេជ្ញាចិត្តជាអន្តរជាតិ បទដ្ឋាន និងការអនុវត្ត ដែលមានបំណងលើកកម្ពស់សមភាពយេនឌ័រនិងសន្តិភាពប្រកបដោយចីរភាព។ កើតចេញពីសេចក្តីសម្រេច ឯកសារគ្រឹះ និងយន្តការផ្សេងៗ រចនាសម្ព័ន្ធនេះ ពង្រឹងការឆ្លើយតបជាសកលចំពោះការរួមបញ្ចូលស្ត្រីនៅក្នុងកិច្ចការសន្តិភាពនិងសន្តិសុខ។



# សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥៖ ជោគជ័យគ្រឹះមួយដ៏សំខាន់

អនុម័តនៅឆ្នាំ២០០០ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ បានរៀបចំមូលដ្ឋានគ្រឹះសម្រាប់របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដោយបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងការទប់ស្កាត់និងដោះស្រាយទំនាស់ ការចរចាសន្តិភាព ការកសាងសន្តិភាព និងការស្តារឡើងវិញក្រោយជម្លោះ។

ប្រការនេះទាមទារឱ្យមានការរួមបញ្ចូលទស្សនៈទានយេនឌ័រក្នុងដំណើរការសន្តិភាពនិងសន្តិសុខ ដោយសង្កត់ធ្ងន់លើកិច្ចការពារស្ត្រីនិងក្មេងស្រីចេញពីអំពើហិង្សា និងសារៈសំខាន់នៃការចូលរួមសម្រេចចិត្តយ៉ាងសកម្មរបស់ពួកគេ។

សេចក្តីសម្រេចលេខ១៣២៥ ក៏ដើរតួនាទីសំខាន់សម្រាប់ការបង្កើតសេចក្តីសម្រេចជាបន្តបន្ទាប់ទៀតផងដែរ ដែលបានតម្រង់ទិសការរីកលូតលាស់នៃក្របខ័ណ្ឌបទដ្ឋាននេះ។ សេចក្តីសម្រេចទាំងនេះបានគូសបញ្ជាក់ពីភាពចាំបាច់របស់រដ្ឋជាសមាជិកក្នុងការអនុម័តផែនការសកម្មភាពថ្នាក់ជាតិ (NAP) ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តជាសកលនេះទៅជាសកម្មភាពពិតប្រាកដ និងឆ្លើយតបទៅនឹងបរិបទជាក់លាក់នៅកំរិតថ្នាក់ប្រទេស។ នេះជាការបោះជំហានឆ្ពោះទៅរកវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានគណនេយ្យភាពជាងមុន ក្នុងការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ។

# ការវិវត្តនៃក្របខ័ណ្ឌបទដ្ឋានសកល

ការអនុម័តសេចក្តីសម្រេចទាក់ទងនឹង របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ជាបន្តបន្ទាប់បានធ្វើឱ្យរបៀបវារៈនេះ កាន់តែមានវិសាលភាពទូលំទូលាយ និងស៊ីជម្រៅ។

សេចក្តីសម្រេចទាំងនេះបានដោះស្រាយបញ្ហាប្រឈមជាក់ស្តែងរបស់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នានា រួមមាន អំពើហិង្សាផ្លូវភេទដែលកើតមានក្នុងស្ថានភាពជម្លោះ ការពង្រឹងភាពអង់អាចផ្នែក សេដ្ឋកិច្ចដល់ស្ត្រី និងការការពារស្ត្រីនិងក្មេងស្រី ដែលភៀសខ្លួន។

សេចក្តីសម្រេចនីមួយៗបានរួមចំណែកដល់ការកែលម្អគោលការណ៍នៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដោយធានាថា រចនាសម្ព័ន្ធរបស់របៀបវារៈនៅតែមានចាមរន្ត និងឆ្លើយតបទៅនឹងបញ្ហាប្រឈមជាសកលដែលកំពុងកើតមាន។

ឧទាហរណ៍ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៨២០ បានទទួលស្គាល់យ៉ាងច្បាស់ថា អំពើហិង្សាផ្លូវភេទ ជាយុទ្ធសាស្ត្រនៃសង្គ្រាម និងអំពាវនាវឱ្យមានវិធានការដោះស្រាយនិទណ្ឌភាពជាក់លាក់។ សេចក្តីសម្រេចរបស់ UNSCR លេខ២១២២ ផ្តោតលើភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការកសាងសន្តិភាព រីឯសេចក្តីសម្រេច UNSCR លេខ២៤៦៧ បានបញ្ចូលវិធីសាស្ត្រដែលផ្តោតសំខាន់លើសុវត្ថិភាពនិងសុខុមាលភាពនៃជនរងគ្រោះ ដើម្បីរកយុត្តិធម៌ និងការពារជនរងគ្រោះ។

ជារួម សេចក្តីសម្រេចទាំងនេះ ប្រៀបបានជាសសរទ្រូទ្រង់ ក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយសម្រាប់ជួយឱ្យរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដំណើរការទៅបាន។

បន្ថែមពីលើសេចក្តីសម្រេចទាំងនេះ គំនិតផ្តួចផ្តើមថ្មីៗ ដូចជា កិច្ចព្រមព្រៀងរវាង របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និងសកម្មភាពមនុស្សធម៌ (WPS-HA Compact) ដែលបានបង្កើតឡើងនៅឆ្នាំ២០២១ នៅក្នុងវេទិកាសមភាពយេនឌ័រតជំនាន់ (Generation Equality Forum) មានបំណងពង្រឹងការប្តេជ្ញាចិត្ត និងយន្តការគណនេយ្យភាព ដោយបញ្ជ្រាបបន្ថែមទៀតនូវគោលការណ៍របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងកិច្ចខិតខំប្រឹងប្រែងមនុស្សធម៌និងការអភិវឌ្ឍ [១២]។

# ផែនការសកម្មភាពថ្នាក់ជាតិ៖ ផ្សារភ្ជាប់ថ្នាក់សកលទៅនឹងមូលដ្ឋាន

យន្តការដ៏សំខាន់បំផុតមួយនៃរចនាសម្ព័ន្ធ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ គឺផែនការសកម្មភាពជាតិ (NAP) ដែលជាឧបករណ៍មួយអនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើមូលដ្ឋានីយកម្មនិងអនុវត្តរបៀបវារៈនេះ។ ប្រទេសជាង១០០បានអនុម័តផែនការសកម្មភាពជាតិ NAP ដោយប្រែក្លាយគោលការណ៍នៃ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ឱ្យស្របតាមបរិបទនយោបាយ សង្គម និងវប្បធម៌រៀងៗខ្លួនរបស់ពួកគេ [១៣]។ ផែនការទាំងនេះជារឿយៗផ្តល់អាទិភាពលើវិស័យ ដូចជា ការកសាងសមត្ថភាពភ្នាក់ងារសន្តិសុខ យន្តការយុត្តិធម៌អន្តរកាល (TJ) និងការពង្រឹងស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាយេនឌ័រ។

ឧទាហរណ៍ ផែនការសកម្មភាពជាតិរបស់ប្រទេសកូតឌីវ័រ (Côte d’Ivoire) បានរំលេចគំនិតផ្តួចផ្តើមទាក់ទងនឹងកិច្ចការពារ រីឯផែនការសកម្មភាពជាតិ របស់ប្រទេសហ្គាណា ផ្តល់អាទិភាពលើការដោះស្រាយចំណុចប្រសព្វនៃជម្លោះ និងការជម្លៀសដោយបង្ខំតាមរយៈទស្សនៈទាន យេនឌ័រ [១៤]។

ភាពចម្រុះគ្នានៃផែនការសកម្មភាពថ្នាក់ជាតិ ឆ្លុះបញ្ចាំងពីភាពបត់បែននៃរចនាសម្ព័ន្ធ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដែលរចនាឡើងដើម្បីសម្របសម្រួលនូវតម្រូវការជាក់ស្តែងក្នុងតំបន់និងបរិបទប្រទេសផ្សេងៗ។

# យន្តការត្រួតពិនិត្យ និងគណនេយ្យភាពសកល

រចនាសម្ព័ន្ធរបស់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ក៏បានបញ្ចូលយន្តការដ៏រឹងមាំផងដែរក្នុងការតាមដានវឌ្ឍនភាព និងធានាបាននូវគណនេយ្យភាព។ របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និង អំពើហិង្សាផ្លូវភេទពាក់ព័ន្ធនឹងជម្លោះ (CRSV) បានផ្តល់នូវការត្រួតពិនិត្យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងការអនុវត្តជាសកល ដោយគូសបញ្ជាក់ទាំងភាពជោគជ័យ និងគម្លាតដែលនៅមាន [១៥]។

លើសពីនេះ អង្គការសង្គមស៊ីវិលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យការប្តេជ្ញាចិត្តនៃ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នេះ ដោយដាក់ចេញជារបាយការណ៍បន្ថែម សំដៅធ្វើយ៉ាងណាឱ្យរដ្ឋាភិបាលមានទទួលខុសត្រូវចំពោះផែនការសកម្មភាពថ្នាក់ជាតិរបស់ខ្លួន [១៦]។

លើសពីនេះ ស្ថាប័នអង្គការសហប្រជាជាតិដើម្បីស្ត្រី (UN Women) ដែលជាអង្គភាពធ្វើសកម្មភាពដើម្បីសមភាពយេនឌ័រ បានពង្រីកការសម្របសម្រួល និងការកៀរគរការគាំទ្របន្ថែមនៅក្នុងប្រព័ន្ធស្ថាប័នរបស់អង្គការសហប្រជាជាតិ។ តាមរយៈការងាររបស់ខ្លួន UN Women គាំទ្ររដ្ឋជាសមាជិកក្នុងការអនុវត្តការប្តេជ្ញាចិត្តលើរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ និងផ្តល់អ្នកជំនាញបច្ចេកទេសដើម្បីបញ្ជ្រាបទស្សនៈទានយេនឌ័រទៅក្នុងប្រតិបត្តិការរក្សាសន្តិភាព កម្មវិធីអភិវឌ្ឍន៍ និងការបង្កើតគោលនយោបាយនានា[១៧]។

# បញ្ហាប្រឈម និងទិសដៅ

ទោះបីជារបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បង្ហាញពីការរីកចម្រើនយ៉ាងខ្លាំងក៏ដោយ ក៏មិនបានន័យថា មិនមានបញ្ហាប្រឈមនោះទេ។

គម្លាតហិរញ្ញប្បទានដែលនៅបន្តកើតមាន ការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិមិនមានតុល្យភាព និងកម្រិតការចូលរួមរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន ក្នុងដំណើរការបង្កើតគោលនយោបាយ នៅតែជាបញ្ហាកង្វល់ដែលបន្តកើតមាន។

បន្ថែមពីនេះ ដោយសារតែការលេចឡើងនូវទម្រង់ថ្មីនៃអសន្តិសុខនិងជម្លោះ ដូចជាសង្គ្រាមតាមអ៊ីនធឺណិត និងជម្លៀសដោយបង្ខំដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវតែបន្តមានភាពបត់បែនដើម្បីសម្របខ្លួនទៅនឹងបរិបទថ្មីនេះ។

ភាពខ្លាំងនៃរចនាសម្ព័ន្ធរបៀបវារៈនេះអាស្រ័យលើសមត្ថភាពរបស់វាក្នុងការរក្សាឱ្យបាននូវភាពបត់បែន និងការឆ្លើយតបទៅនឹងបញ្ហាប្រឈមថ្មីៗដែលកំពុងកើតមាន ហើយនៅតែអាចរក្សាបាននូវគោលការណ៍ស្នូលរបស់ខ្លួន។

ខួប២៥ឆ្នាំ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ នៅក្នុងឆ្នាំ ២០២៥នេះ ជាពេលវេលាសកលមួយ ដើម្បីឆ្លុះបញ្ចាំង និងធ្វើឱ្យរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មានភាពរស់រវើកឡើងវិញ ទោះបីជាមានការកើនឡើងនៃការព្រួយបារម្ភលើជម្លោះ សន្តិភាព និងបញ្ហាសន្តិសុខសកលដោយសារតែប្រព័ន្ធនិងយន្តការនានានៃសណ្តាប់ធ្នាប់អន្តរជាតិដែលឈរលើគោលការណ៍ច្បាប់ ខ្លួនឯងកំពុងរងការគំរាមកំហែងនាពេលបច្ចុប្បន្ន [១៨,១៩] ។



# ១.៤. សសរស្តម្ភប្រសព្វគ្នាទាំង៤ នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ

១

ការទប់ស្កាត់

ការការពារ

## ៣ ការសង្គ្រោះ និងការស្តារឡើងវិញ

## ៤ ការចូលរួម



**របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដែលមាននៅក្នុងសេចក្តីសម្រេច UNSCR 1325 និងសេចក្តីសម្រេចជាបន្តបន្ទាប់ទៀត មានចំណុចបួនសំខាន់ ដែលជាសសរស្តម្ភប្រសព្វគ្នា៖**

**១. ការទប់ស្កាត់**

**២. ការការពារ**

**៣. ការសង្គ្រោះនិងការស្តារឡើងវិញ**

**៤. ការចូលរួម**

សសរស្តម្ភទាំងនេះរៀបចំឡើងដើម្បីធានាថា ទស្សនវិស័យ តម្រូវការ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រីមកពីគ្រប់អត្តសញ្ញាណត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពនិងសន្តិសុខសកល។

ផ្នែកនេះឈ្វេងយល់ពីសសរស្តម្ភនីមួយៗយ៉ាងលម្អិត ដោយបញ្ជាក់ពីសារៈសំខាន់ជាសកល និងទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយរបស់ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ។

# សសរស្តម្ភទី

# ការទប់ស្កាត់

ការទប់ស្កាត់ គឺជាមូលដ្ឋានគ្រឹះនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដែលមានគោលបំណងដោះស្រាយឫសគល់នៃជម្លោះ និងការពារការរីករាលដាលនៃអំពើហិង្សាតាមរយៈវិធានការបែបបុរេសកម្ម និងប្រកបដោយបរិយាបន្ន។

ចំណុចស្នូលនៃសសរស្តម្ភនេះ គឺជាការទទួលស្គាល់វិសមភាពបែបរចនាសម្ព័ន្ធ ដូចជា ការរើសអើងយេនឌ័រ ការផាត់ចេញពីការធ្វើសេចក្តីសម្រេចចិត្ត និងការផ្តាច់សិទ្ធិសេដ្ឋកិច្ច គឺជាញឹកញាប់ជំរុញឱ្យមានអំពើហិង្សា និងអស្ថេរភាព។

ដូច្នេះ យុទ្ធសាស្ត្រទប់ស្កាត់ គឺផ្តោតលើការដោះស្រាយឧបសគ្គជាប្រព័ន្ធ ដូចជាការលើកកម្ពស់សមភាពយេនឌ័រ ការពង្រឹងនីតិរដ្ឋ និងលើកកម្ពស់អភិបាលកិច្ចប្រកបដោយបរិយាបន្ន។

ចំណុចសំខាន់នៃការទប់ស្កាត់នោះ គឺការជឿថាការដោះស្រាយកត្តាជំរុញឱ្យមានវិសមភាពជាប្រព័ន្ធ គឺការបង្កើតលក្ខខណ្ឌសម្រាប់សន្តិភាពប្រកបដោយនិរន្តរភាព។

ប្រការនេះ តម្រូវឱ្យមានការទទួលស្គាល់ និងការផ្លាស់ប្តូរអំណាចមិនស្មើគ្នា ដែលបានធ្វើឱ្យស្ត្រីនិងក្រុមដែលត្រូវបានផាត់ចេញផ្សេងទៀតក្លាយជាងាយរងគ្រោះ។ ឧទាហរណ៍ ការផ្តោតលើការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ស្ត្រី មិនត្រឹមតែបង្កើនស្វ័យភាពរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេចេញពីការកេងប្រវ័ញ្ច និងការរំលោភបំពានផងដែរ។

លើសពីនេះ កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់នេះត្រូវតែមានការដោះស្រាយភាពងាយរងគ្រោះដែលលក្ខណៈប្រសព្វគ្នា ដោយធានាថាស្ត្រីមកពីមជ្ឈដ្ឋានចម្រុះផ្សេងៗ ផ្នែកសង្គម សេដ្ឋកិច្ច ជាតិសាសន៍ ពិការភាព ល។ សុទ្ធតែទទួលបានឱកាស និងធនធានស្មើគ្នា។

នៅទូទាំងពិភពលោក គំនិតផ្តួចផ្តើមក្នុងការទប់ស្កាត់បានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពសហគមន៍ដែលមានសំឡេងស្ត្រីជាស្នូល។

ឧទាហរណ៍ នៅប្រទេសកូឡុំប៊ី អង្គការមូលដ្ឋានដឹកនាំដោយស្ត្រីបានដើរតួនាទីសំខាន់នៅក្នុងការចរចាបទឈប់បាញ់គ្នា និងការតស៊ូមតិក្នុងការបញ្ជ្រាបទស្សនៈទានយេនឌ័រទៅក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងសន្តិភាព។ បទប្បញ្ញត្តិទាំងនេះ បានសង្កត់ធ្ងន់ទៅលើបញ្ហា ដូចជា សិទ្ធិកាន់កាប់ដីធ្លី អំពើហិង្សាផ្អែកលើ

យេនឌ័រ (GBV) និងការដាក់បញ្ចូលសមាសភាពស្ត្រីទៅក្នុងការងារអភិបាលកិច្ចនៅក្រោយជម្លោះ។ ឧទាហរណ៍នេះ បង្ហាញពីរបៀបទប់ស្កាត់មិនមែនគ្រាន់តែអំពីការបញ្ចប់ជម្លោះរយៈពេលខ្លីនោះទេ ប៉ុន្តែក៏បង្ហាញពីការលើកកម្ពស់សន្តិភាពប្រកបដោយនិរន្តរភាពផងដែរ តាមរយៈការបំប្លែងរចនាសម្ព័ន្ធសង្គមដែលអូសបន្លាយវិសមភាព [២០]។

ការអប់រំ គឺជាធាតុផ្សំដ៏សំខាន់មួយទៀតក្នុងការទប់ស្កាត់។ ការរួមបញ្ចូលសមភាពយេនឌ័រ និងការអប់រំសន្តិភាពទៅក្នុងកម្មវិធីសិក្សាជាតិ ផ្តល់លទ្ធភាពដល់យុវជនក្នុងការប្រឈមនឹងបទដ្ឋាន និងអាកប្បកិរិយារើសអើងនានា។

ឧទាហរណ៍ កម្មវិធី Generations for Peace នៅប្រទេសអ៊ូហ្គង់ដា បានធ្វើការស្និទ្ធជាមួយសហគមន៍ដោយជោគជ័យ ក្នុងការជម្រុញឱ្យមានកិច្ចសន្ទនាស្តីពីអំពីអំពើហិង្សាយេនឌ័រ និងការលើកទឹកចិត្តយុវជនដើម្បីក្លាយជាអ្នកតស៊ូមតិសម្រាប់ការរួមរស់ជាមួយគ្នាដោយសន្តិភាព [២១]។

ដូចគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងការទទួលបានការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីក្នុងបរិបទក្រោយជម្លោះ ដូចជានៅប្រទេសសៀរ៉ាឡេអូនបានរួមចំណែកកាត់បន្ថយហានិភ័យនៃអំពើហិង្សាជាថ្មី ដោយធ្វើឱ្យសង្គមមានបរិយាបន្ន និងសមធម៌បន្ថែមទៀត [២២]។

ការទប់ស្កាត់ក៏ពឹងផ្អែកលើការធានាឱ្យមានតំណាងរបស់ស្ត្រីនៅក្នុងប្រព័ន្ធគិតគូរជាមុន និងយន្តការការពារជម្លោះ។ ការសិក្សាបានបង្ហាញថា ជារឿយៗ ស្ត្រីជាមនុស្សដំបូងគេដែលរកឃើញសញ្ញានៃការកើនឡើងអំពើហិង្សានៅក្នុងសហគមន៍របស់ពួកគេ ជាហេតុធ្វើឱ្យការរួមបញ្ចូលរបស់ពួកគេនៅក្នុងដំណើរការទាំងនេះមានសារៈសំខាន់។

នៅប្រទេសកេនយ៉ា បណ្តាញដឹកនាំដោយស្ត្រីបានដើរតួយ៉ាងសំខាន់ក្នុងការរាយការណ៍ពីការរំលោភសិទ្ធិមនុស្ស និងភាពតានតឹងក្នុងតំបន់តាមរយៈការសន្ទនា និងការសម្របសម្រួល។ គំនិតផ្តួចផ្តើមទាំងនេះបង្ហាញពីតម្លៃនៃការប្រើចំណេះដឹង និងបទពិសោធន៍របស់ស្ត្រី ដើម្បីកសាងភាពធន់នឹងជម្លោះ [២៣]។

ជាងនេះទៅទៀត សសរស្តម្ភការទប់ស្កាត់ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការដោះស្រាយទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ កង្វះធនធាន និងជម្លោះ។

ការរេចរិលបរិស្ថាន ធ្វើឱ្យប៉ះពាល់ដល់ស្ត្រី និងក្មេងស្រី ជាពិសេសនៅតំបន់ជនបទនិងតំបន់ដែលមានប្រាក់ចំណូលទាប ធ្វើឱ្យវិសមភាពដែលមានស្រាប់កាន់តែដុនដាប និងជំរុញការប្រកួតប្រជែងដណ្តើមធនធានកម្រ។

ដូច្នេះយុទ្ធសាស្ត្រទប់ស្កាត់ត្រូវតែប្រកាន់យកនូវវិធីសាស្ត្រ ដែលគិតគូរពីយេនឌ័រសម្រាប់សកម្មភាពអាកាសធាតុ ដោយធានាថា ស្ត្រីបានរួមបញ្ចូលក្នុងដំណើរការធ្វើការសម្រេចចិត្ត ដែលទាក់ទងនឹងការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងទឹក និងការត្រៀមសម្រាប់គ្រោះមហន្តរាយ។ ឧទាហរណ៍ គម្រោងដាំដើមឈើឡើងវិញ ដែលដឹកនាំដោយស្ត្រីនៅតំបន់ Sahel នៃទ្វីបអាហ្វ្រិក បានរួមចំណែកមិនត្រឹមតែដល់ការស្តារបរិស្ថានប៉ុណ្ណោះទេ ថែមទាំងជួយកាត់បន្ថយភាពតានតឹងរវាងសហគមន៍ ជុំវិញការប្រើប្រាស់ធនធានផងដែរ [២៤]។

ចុងក្រោយទៅ ភាពជោគជ័យនៃសសរស្តម្ភការទប់ស្កាត់អាស្រ័យលើការចេះរួមបញ្ចូលស្ត្រីប្រកបដោយអត្ថន័យទៅក្នុងគ្រប់ទិដ្ឋភាពនៃការកសាងសន្តិភាពនិងអភិបាលកិច្ច។ ដូចដែលបានបង្ហាញតាមឧទាហរណ៍ជាសកល ការទប់ស្កាត់មិនមែនគ្រាន់តែសំដៅលើការកាត់បន្ថយហានិភ័យនៃអំពើហិង្សានោះទេ ប៉ុន្តែផ្តោតលើការបង្កើតសង្គមមួយដែលផ្តល់អាទិភាពដល់សមភាព យុត្តិធម៌ និងសន្តិសុខរបស់មនុស្ស។

# សសរស្តម្ភទី ២

# ការការពារ

សសរស្តម្ភការពារផ្តោតលើការការពារស្ត្រីនិងក្មេងស្រីពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានទៅក្នុងស្ថានភាពជម្លោះ និងក្រោយជម្លោះ។ ការការពារនេះសង្កត់ធ្ងន់លើតម្រូវការដើម្បីធានាការទទួលបានយុត្តិធម៌ ការគាំទ្រផ្លូវចិត្ត និងការថែទាំសុខភាពជាពិសេសសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ។

វិធានការការពារពង្រីកទៅដល់សុវត្ថិភាពផ្លូវកាយភ្លាមៗ ដោយផ្តោតលើកំណែទម្រង់ជាប្រព័ន្ធ ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់ស្ត្រីអ្នកការពារសិទ្ធិមនុស្ស និងដោះស្រាយភាពងាយរងគ្រោះជាពិសេសរបស់ស្ត្រីនិងក្មេងស្រីភៀសខ្លួន។

កិច្ចខិតខំប្រឹងប្រែងទាំងនេះមានសារៈសំខាន់ក្នុងការលើកកម្ពស់សន្តិភាពប្រកបដោយចីរភាព និងបរិយាបន្នសម្រាប់ជនរងគ្រោះ ក្នុងការទទួលបានការគាំទ្រ ទាមទារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពួកគេមកវិញ។

ជាលក្ខណៈសកល ការអនុវត្តរបស់ក្របខ័ណ្ឌការពារជារឿយៗពឹងផ្អែកលើការអភិវឌ្ឍគោលនយោបាយដូចជាផែនការសកម្មភាពជាតិ ។

ផែនការទាំងនេះ គឺជាឧបករណ៍សំខាន់ក្នុងការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដោយគូសបញ្ជាក់វិធានការជាក់លាក់ ដើម្បីការពារស្ត្រីនិងក្មេងស្រីនៅក្នុងបរិបទដែលរងផលប៉ះពាល់ដោយជម្លោះ។

ឧទាហរណ៍ ផែនការសកម្មភាពជាតិ NAP របស់ប្រទេសសៀរ៉ាឡេអូន គឺជាករណីគួរឱ្យកត់សម្គាល់នៅក្នុងការរួមបញ្ចូលការបណ្តុះបណ្តាលស្តីពីសន្តិសុខដែលគិតគូរពីយេនឌ័រដល់កងកម្លាំងរក្សាសន្តិភាព មន្ត្រីអនុវត្តច្បាប់ និងយន្តការការពារសហគមន៍។ វិធានការទាំងនេះបានបង្កើតមធ្យោបាយបន្ថែមទៀតសម្រាប់ការការពារប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបក្របខ័ណ្ឌដែលទទួលស្គាល់ និងដោះស្រាយស្ថានភាពជាក់ស្តែងនៃការរស់នៅរបស់ស្ត្រី [២៥]។

នៅប្រទេសលីបេរីយ៉ា ការបង្កើតអង្គភាពជំនាញនៅក្នុងកងកម្លាំងនគរបាលបានបង្ហាញពីសក្តានុពលនៃអន្តរាគមន៍ជាក់លាក់ ដើម្បីបង្កើនលទ្ធភាពទទួលបានយុត្តិធម៌ និងគណនេយ្យភាពរបស់ជនរងគ្រោះ។ អង្គភាពទាំងនេះបានបង្កើនការយល់ដឹង និងការឆ្លើយតបចំពោះអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ (SGBV) ទោះបីជាបញ្ហាប្រឈម ដូចជាប្រព័ន្ធតុលាការដែល

មានកម្រិត និងការរើសអើងជាដើម នៅបន្តមាន[២៦]។

ទោះយ៉ាងណាក៏ដោយ ការការពារមិនមែនមានត្រឹមតែការឆ្លើយតបភ្លាមៗនោះទេ វាទាមទារឱ្យមានបុរេសកម្ម និងវិធីដោះស្រាយប្រសព្វគ្នា ដែលគិតគូរដល់ភាពងាយរងគ្រោះត្រួតស៊ីគ្នារបស់បុគ្គល ដោយផ្អែកលើកត្តា ដូចជា ជាតិសាសន៍ អាយុ ពិការភាព ទំនោរផ្លូវភេទ និងស្ថានភាពសេដ្ឋកិច្ចសង្គមផងដែរ។

ឧទាហរណ៍ ស្ត្រីនិងក្មេងស្រីភៀសខ្លួន ប្រឈមនឹងហានិភ័យខ្ពស់ទៅនឹងអំពើហិង្សានៅក្នុងជំរំជនភៀសខ្លួន ឬការតាំងទីលំនៅក្រៅផ្លូវការ ដែលជាកន្លែងខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងខ្វះខាតធនធានប្រើប្រាស់ ធ្វើឱ្យដុនដាបដល់ភាពងាយរងគ្រោះរបស់ពួកគេ។

ដូច្នេះវិធានការការពារត្រូវដោះស្រាយវិសមភាពបែបរចនាសម្ព័ន្ធទាំងនេះ ដោយធានាថាតម្រូវការរបស់ស្ត្រីភៀសខ្លួនត្រូវបានដាក់បញ្ចូលនៅក្នុងការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងជំរំ និងការបែងចែកធនធាន។

នៅ**ប្រទេសបង់ក្លាដែស** មានជំរំជនភៀសខ្លួនរ៉ូហ៊ីងយ៉ានៅ Cox’s Bazaar។ គំនិតផ្តួចផ្តើមដឹកនាំដោយស្ត្រីអ្នកស្ម័គ្រចិត្តមិនត្រឹមតែបានពង្រឹងសុវត្ថិភាពប៉ុណ្ណោះទេ ថែមទាំងបានបណ្តុះអារម្មណ៍នៃភាពជន់នឹងសហគមន៍ផងដែរ។

នៅប្រទេសបង់ក្លាដែស មានជំរំជនភៀសខ្លួនជនជាតិរ៉ូហ៊ីងយ៉ានៅតំបន់ Cox’s Bazaar។ គំនិតផ្តួចផ្តើមដឹកនាំដោយស្ត្រីអ្នកស្ម័គ្រចិត្តមិនត្រឹមតែបានពង្រឹងសុវត្ថិភាពប៉ុណ្ណោះទេ ថែមទាំងបានបណ្តុះអារម្មណ៍នៃភាពជន់នឹងសហគមន៍ផងដែរ។

សិទ្ធិទទួលបានការថែទាំសុខភាពផ្លូវភេទនិងបន្តពូជគឺជាសមាសធាតុសំខាន់មួយទៀតនៃសសរស្តម្ភការពារ។ គេបានដឹងជាយូរមកហើយថា ជម្លោះធ្វើឱ្យឧបសគ្គមានស្រាប់កាន់តែធ្ងន់ធ្ងរឡើងក្នុងការទទួលបានការថែទាំសុខភាព ដែលធ្វើឱ្យប៉ះពាល់ដល់ស្ត្រី និងក្មេងស្រី។

សសរស្តម្ភការពារ ក៏គូសបញ្ជាក់អំពីតម្រូវការបង្កើតបរិយាកាសអំណោយផលសម្រាប់ស្ត្រីអ្នកការពារសិទ្ធិមនុស្ស (WHRDs) ដែលជារឿយៗប្រឈមមុខនឹងអំពើហិង្សានិងការគាបសង្កត់ដោយសារសកម្មភាពទាមទារសិទ្ធិរបស់ពួកគេ។

នៅក្នុងបរិបទដូចជាប្រទេសកូឡុំប៊ីនិងហ្វីលីពីន ស្ត្រីអ្នកការពារសិទ្ធិមនុស្ស (WHRDs) ដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លី និងយុត្តិធម៌បរិស្ថានបានប្រឈមមុខនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ទាំងការបៀតបៀនរហូតដល់អំពើហិង្សាលើរាងកាយ ២៧។

វិធានការការពារសម្រាប់អ្នកការពារទាំងនេះត្រូវតែលើសពីសន្តិសុខបុគ្គល គ្របដណ្តប់លើកំណែទម្រង់ជាប្រព័ន្ធដើម្បីដោះស្រាយនិទណ្ឌភាព និងធានានូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងសកម្មជនសិទ្ធិមនុស្ស។

ការពង្រឹងបណ្តាញតស៊ូមតិអន្តរជាតិនិងបណ្តាញសាមគ្គីភាពក៏អាចផ្តល់ឱ្យ ស្ត្រីអ្នកការពារសិទ្ធិមនុស្ស (WHRDs) អ្នកកាសែតឯករាជ្យ និងតួអង្គសង្គមស៊ីវិលដទៃទៀត នូវវេទិកាដ៏សំខាន់ដើម្បីបន្លឺសំឡេងរបស់ពួកគេនិងស្វែងរកកិច្ចការពារ។

ជាងនេះទៅទៀត សសរស្តម្ភការពារបានគូសបញ្ជាក់ពីសារៈសំខាន់នៃការរួមបញ្ចូលវិធីសាស្ត្រផ្អែកលើសហគមន៍ទៅក្នុងក្របខ័ណ្ឌការពារគ្រប់ជ្រុងជ្រោយ។ អង្គការស្ត្រីក្នុងមូលដ្ឋានតែងតែនាំមុខគេក្នុងការកំណត់អត្តសញ្ញាណ និងដោះស្រាយគម្លាតនៃការការពារ ដោយការប្រើប្រាស់ចំណេះដឹងលើបរិបទមូលដ្ឋានរបស់ពួកគេ ដើម្បីអនុវត្តដំណោះស្រាយដែលមានប្រសិទ្ធភាព និងត្រូវនឹងវប្បធម៌មូលដ្ឋាន។

ឧទាហរណ៍ នៅប្រទេសម៉ាឡាវី ក្រុមស្ត្រីបានបង្កើតកន្លែងសុវត្ថិភាពសម្រាប់អ្នកទទួលរងអំពើហិង្សា មិនត្រឹមតែផ្តល់កន្លែងស្នាក់នៅប៉ុណ្ណោះទេ តែថែមទាំងផ្តល់ជំនួយផ្នែកច្បាប់និងការបណ្តុះបណ្តាលវិជ្ជាជីវៈទៀតផង។ គំនិតផ្តួចផ្តើមទាំងនេះបង្ហាញពីសក្តានុពលដ៏មានឥទ្ធិពលនៃវិធានការការពារដែលផ្តោតលើភាពជាម្ចាស់ និងការពង្រឹងអំណាចរបស់សហគមន៍ [២៨]។

## សសរស្តម្ភទី

# ការសង្គ្រោះ និង ការស្តារឡើងវិញ

ការអប់រំក៏ជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះ និងស្តារឡើងវិញផងដែរ ដោយធានាថាកុមារ ជាពិសេសក្មេងស្រី អាចបន្តការសិក្សាអប់រំ ទោះជាមានការរំខានដោយសារជម្លោះ ឬគ្រោះមហន្តរាយក៏ដោយ។ សាលារៀនផ្តល់នូវអារម្មណ៍ស្ថិរភាព និងក្តីសង្ឃឹមសម្រាប់អនាគត និងកាត់បន្ថយហានិភ័យនៃការរៀបអាពាហ៍ពិពាហ៍វ័យក្មេង និងការកេងប្រវ័ញ្ចក្រោមទម្រង់ផ្សេងៗទៀតផងដែរ។

នៅប្រទេសអ៊ុយក្រែន គេបង្កើតមជ្ឈមណ្ឌលសិក្សាបណ្តោះអាសន្នដើម្បីធានាថាកុមារ ជាពិសេសក្មេងស្រី កុមារមានពិការភាព និងកុមារផ្លាស់ទីលំនៅដោយបង្ខំ អាចទទួលបានការអប់រំ និងសកម្មភាពក្រៅកម្មវិធីសិក្សាផ្សេងៗ [២៩]។

កិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះនិងការស្តារឡើងវិញក៏ត្រូវដោះស្រាយឧបសគ្គផ្លូវច្បាប់និងស្ថាប័នផងដែរ ដែលជារឿយៗ ជាកត្តារារាំងស្ត្រីទទួលបានសិទ្ធិនិងយុត្តិធម៌។ កំណែទម្រង់ច្បាប់ក្រោយជម្លោះមានសារៈសំខាន់នៅក្នុងការធានាថាស្ត្រីអាចទាមទារកម្មសិទ្ធិទ្រព្យសម្បត្តិ ទទួលបានសំណង ហើយជនបង្កហិង្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

ឧទាហរណ៍ នៅប្រទេសកូឡុំប៊ី ក្រុមគាំពារស្ត្រីបានកៀរគរការគាំទ្រដោយជោគជ័យក្នុងការដាក់បញ្ចូលកម្មវិធីសំណងដែលគិតគូរពីយេនឌ័រទៅក្នុងកិច្ចព្រមព្រៀងសន្តិភាព ដើម្បីធានាថាស្ត្រីបាត់បង់ដី ឬទទួលរងអំពើហិង្សាអាចស្វែងរកដំណោះស្រាយបាន។ វិធានការទាំងនេះមិនត្រឹមតែគាំទ្រការស្តារឡើងវិញរបស់បុគ្គលប៉ុណ្ណោះទេ តែថែមទាំងលើកកម្ពស់គណនេយ្យភាពសង្គម និងសមភាពយេនឌ័រផងដែរ [៣០]។

សរុបមក ការសង្គ្រោះនិងការស្តារឡើងវិញមិនមែនគ្រាន់តែធ្វើឱ្យស្ថានការណ៍ត្រឡប់ទៅស្ថានភាពដើមវិញនោះទេ តែថែមទាំងបង្ហាញពីឱកាសជំរុញឱ្យមានការផ្លាស់ប្តូរ។ ដំណើរការស្តារឡើងវិញ អាចបង្ហាញពីវិសមភាពនៃរចនាសម្ព័ន្ធ បង្កើតភាពធន់ និងបង្កើតសង្គមគ្មានការរើសអើងតាមការផ្តល់តម្លៃដល់សំឡេងស្ត្រី និងទទួលស្គាល់សមត្ថភាពរបស់ពួកគេ។

ការសង្គ្រោះនិងការស្តារឡើងវិញជួយដោះស្រាយនូវតម្រូវការបន្ទាន់ និងរយៈពេលវែងសម្រាប់ស្ត្រីនិងក្មេងស្រីនៅបរិបទក្រោយជម្លោះនិងវិបត្តិ ដោយធានាថាពួកគេទទួលបានការអប់រំ ការថែទាំសុខភាព ជីវភាពរស់នៅសមរម្យ សំណងផ្លូវច្បាប់ និងការគាំទ្រផ្លូវចិត្ត។

សសរស្តម្ភនេះមិនត្រឹមតែផ្តោតលើការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតលើការស្តារប្រព័ន្ធសង្គមឡើងវិញ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីឱ្យដើរតួនាទីសំខាន់ក្នុងដំណើរការស្តារឡើងវិញ។

ការគូសបញ្ជាក់ពីសារៈសំខាន់នៃវិធីសាស្ត្រដែលផ្តោតលើជនរងគ្រោះ ដែលទទួលស្គាល់តួនាទីភាពជាម្ចាស់ដល់ស្ត្រីក្នុងការកសាងជីវិត និងសហគមន៍របស់ពួកគេឡើងវិញ ខណៈកំពុងដោះស្រាយឧបសគ្គជាប្រព័ន្ធដែលអាចរារាំងការស្តារឡើងវិញរបស់ពួកគេ។ ដូច្នេះកិច្ចខិតខំប្រឹងប្រែងសង្គ្រោះនិងស្តារឡើងវិញ គឺមានសារៈសំខាន់ណាស់ ព្រោះវាជាស្ពានផ្សារភ្ជាប់គ្នារវាងសកម្មភាពមនុស្សធម៌និងការអភិវឌ្ឍរយៈពេលវែង។

បន្ទាប់ពីវិបត្តិ មិនថាដោយសារគ្រោះធម្មជាតិ ឬជម្លោះប្រដាប់អាវុធនោះទេ ស្ត្រីតែងតែដើរតួនាទីជាអ្នកដឹកនាំនៅក្នុងសហគមន៍របស់ពួកគេ ដោយជួយរៀបចំការចែកចាយជំនួយ ផ្តល់ការថែទាំ និងផ្តល់អនុសាសន៍សម្រាប់ដំណើរការស្តារឡើងវិញ ដែលឆ្លុះបញ្ចាំងពីតម្រូវការជាក់លាក់របស់ពួកគេ។

ឧទាហរណ៍ ក្នុងអំឡុងពេលនៃកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ ក្រោយរលកយក្សស៊ូណាមិនៅក្រុង Aceh ក្នុងប្រទេសឥណ្ឌូណេស៊ី អង្គការដែលដឹកនាំដោយស្ត្រីបានតស៊ូដើម្បីទទួលបានតួនាទីសំខាន់ក្នុងការចែកចាយជំនួយសង្គ្រោះ ការកសាងលំនៅឋាន ឡើងវិញ និងការផ្តល់អនុសាសន៍សម្រាប់គោលនយោបាយត្រៀមទប់ទល់គ្រោះមហន្តរាយ ដែលពិចារណាទៅលើភាពងាយរងគ្រោះដែលកើតឡើងដោយសារកត្តាយេនឌ័រ។ គំនិតផ្តួចផ្តើមរបស់ពួកគេមិនត្រឹមតែដោះស្រាយតម្រូវការចំពោះមុខប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមូលដ្ឋានគ្រឹះសម្រាប់ភាពធន់យូរអង្វែង ដោយធានាបានថាសំឡេងស្ត្រីត្រូវបានយកចិត្តទុកដាក់ក្នុងរបៀបវារៈនៃការស្តារឡើងវិញ [៣១]។

ការទទួលបានការថែទាំសុខភាព គឺជាកត្តាធាតុផ្សំដ៏សំខាន់នៃការសង្គ្រោះ និងការស្តារឡើងវិញ ជាពិសេសសម្រាប់ស្ត្រីនិងក្មេងស្រី ដែលធ្លាប់ឆ្លងកាត់អំពើហិង្សាផ្លូវភេទឬរបួសផ្សេងៗទៀតក្នុងអំឡុងពេលមានជម្លោះឬគ្រោះមហន្តរាយ។

ការផ្តល់សេវាសុខភាពផ្លូវភេទនិងបន្តពូជ ការប្រឹក្សានិងការគាំទ្រសុខភាពផ្លូវចិត្ត មានភាពចាំបាច់ធ្វើឱ្យជនរងគ្រោះមានភាពធូរស្បើយ និងកសាងជីវិតពួកគេឡើងវិញ។

ការស្តារឡើងវិញក្រោយគ្រោះរញ្ជួយដីនៅប្រទេសនេប៉ាល់ មានគ្លីនិកចល័តជាច្រើនត្រូវបានដាក់ពង្រាយទៅដល់តំបន់ជនបទ ដើម្បីផ្តល់សេវាថែទាំផ្ទៃពោះដល់ស្ត្រី សេវារៀបចំផែនការគ្រួសារ និងការគាំទ្រសម្រាប់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ ។

គ្លីនិកចល័តទាំងនេះធានាបានថា កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ បានរួមបញ្ចូលនិងឆ្លើយតបនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះ ដោះស្រាយឧបសគ្គផ្សេងៗ ដូចជាកត្តាចម្ងាយផ្លូវ និងការរើសអើង [៣២]។

ការស្តារឡើងវិញនូវជីវភាពរស់នៅ គឺជាកត្តាសំខាន់មួយទៀតនៃការសង្គ្រោះនិងការស្តារឡើងវិញ ដោយសារឯករាជ្យភាពសេដ្ឋកិច្ច តែងតែកំណត់នូវសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងដំណើរការស្តារឡើងវិញកាន់តែទូលំទូលាយ។ កម្មវិធីស្តារឡើងវិញដែលរួមបញ្ចូលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងលទ្ធភាពទទួលបានឥណទានអាចផ្តល់អំណាចដល់ស្ត្រីដើម្បីកសាងជីវភាពរបស់ពួកគេឡើងវិញ និងរួមចំណែកដល់ការស្តារសហគមន៍របស់ពួកគេ។

នៅប្រទេសរវ៉ាន់ដា ក្រុមសហករណ៍ស្ត្រីដែលបានបង្កើតឡើងបន្ទាប់ពីការដួលរលំនៃរបបប្រល័យពូជសាសន៍បានដើរតួនាទីយ៉ាងសំខាន់ មិនត្រឹមតែជំរុញការកសាងសេដ្ឋកិច្ចឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែក៏ជំរុញការផ្សះផ្សា និងសាមគ្គីភាពក្នុងសង្គមផងដែរ។ កិច្ចសហការទាំងនេះបង្ហាញថា ការស្តារសេដ្ឋកិច្ចឡើងវិញអាចជាមធ្យោបាយធ្វើឱ្យប្រសើរឡើង និងកាន់តែរឹងមាំនៅពេលដែលស្ត្រីចូលរួមកាន់តែសកម្ម ៣៣ ។

# សសរស្តម្ភទី ៤

# ការចូលរួម

សសរស្តម្ភនៃការចូលរួម មានបំណងពង្រីកតួនាទីដឹកនាំ និងការសម្រេចចិត្តរបស់ស្ត្រីនៅក្នុងដំណើរការសន្តិភាពនិងសន្តិសុខ ដោយទទួលស្គាល់ការរួមចំណែកសំខាន់ៗរបស់ពួកគេក្នុងការរកដំណោះស្រាយជាក់លាក់និងយូរអង្វែងបាន។ តាមភស្តុតាង បង្ហាញថា កិច្ចព្រមព្រៀងសន្តិភាពដែលសម្រេចបានតាមការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រីទំនងជានឹងអាចរក្សាបានស្ថិតស្ថេរក្នុងរយៈពេលវែង។

សសរស្តម្ភនេះ មិនត្រឹមតែផ្តល់អាទិភាពដល់ការចូលរួមរបស់ស្ត្រីក្នុងការចរចាសន្តិភាពជាផ្លូវការប៉ុណ្ណោះទេ ថែមទាំងភាពជាតំណាងរបស់ខ្លួនសម្រាប់ការគ្រប់គ្រងអភិបាលកិច្ចវិស័យសន្តិសុខនិងប្រតិបត្តិការសន្តិភាពពហុភាគីផងដែរ។ ការធានាឱ្យមានការចូលរួមពីសំណាក់ស្ត្រី គឺជាទិដ្ឋភាពគ្រឹះសំខាន់ក្នុងការសម្រេចបានសមភាពយេនឌ័រ និងសន្តិភាពប្រកបដោយចីរភាព។

ជាលក្ខណៈសកល ប្រទេសលីបេរីយ៉ា គឺជាឧទាហរណ៍លេចធ្លោដែលបង្ហាញពីភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការកសាងសន្តិភាព។ បន្ទាប់ពីសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ ចលនាមហាជនដើម្បីសន្តិភាពរបស់ស្ត្រីនៅប្រទេសលីបេរីយ៉ា បានកៀរគរប្រមូលផ្តុំស្ត្រីរាប់ពាន់នាក់ ដើម្បីដាក់សម្ពាធលើភាគីជម្លោះឱ្យចូលរួមក្នុងកិច្ចសន្ទនា។ ការខិតខំប្រឹងប្រែងរបស់ពួកគេបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ចប់ជម្លោះ និងជំរុញឱ្យមានកិច្ចព្រមព្រៀងសន្តិភាពក្រុង Accra (Accra Comprehensive Peace Agreement)។ ក្រៅពីការចរចា ស្ត្រីទាំងនេះបន្តមានឥទ្ធិពលលើរបៀបវារៈពាក់ព័ន្ធនឹងការស្តារប្រទេសឡើងវិញ ជំរុញការគាំទ្រគោលនយោបាយដែលដោះស្រាយតម្រូវការរបស់ជនរងគ្រោះ និងផ្តល់អាទិភាពលើសមភាពយេនឌ័រ។ ការផ្លាស់ប្តូរក្រោយជម្លោះដ៏មានឥទ្ធិពលរបស់ប្រទេសលីបេរីយ៉ា រួមមាន ការជាប់ឆ្នោតប្រធានាធិបតីស្ត្រីដំបូងរបស់ទ្វីបអាហ្វ្រិក គឺលោកស្រី Ellen Johnson Sirleaf ដែលបានគូសបញ្ជាក់ពីសក្តានុពលនៃចលនាដឹកនាំរបស់ស្ត្រីក្នុងការគូសវាសឡើងវិញនូវគន្លងដឹកនាំជាតិ [៣៤]។

សសរស្តម្ភនៃការចូលរួម មានវិសាលភាពលើសពីដំណើរការនយោបាយផ្លូវការ ដោយរួមបញ្ចូលការដឹកនាំរបស់ស្ត្រីក្នុងថ្នាក់មូលដ្ឋាន និងការដឹកនាំក្រៅផ្លូវការ ដើម្បី

ពង្រឹងភាពធន់ក្នុងសហគមន៍និងការស្តារឡើងវិញ។ ស្ត្រីជាញឹកញយឈរនៅជួរមុខនៃគំនិតផ្តួចផ្តើមអភិវឌ្ឍសហគមន៍ ដោយការចូលរួមរៀបចំកិច្ចសន្ទនាសហគមន៍ គ្រប់គ្រងធនធាន និងដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងឡើងវិញបន្ទាប់ពីវិបត្តិ។

ឧទាហរណ៍ នៅប្រទេសហ្វីលីពីន អង្គការស្ត្រីនៅតំបន់ជម្លោះនៃកោះមីនដាណាវ បានដើរតួយ៉ាងសំខាន់ក្នុងការសម្រុះសម្រួលទំនាស់មូលដ្ឋាន និងទាមទារឱ្យមានបទប្បញ្ញត្តិដែលគិតគូរពីយេនឌ័រនៅក្នុងដំណើរការស្វែងរកសន្តិភាព Bangsamoro។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្ហាញឱ្យឃើញថា ការចូលរួមរបស់ស្ត្រីមិនសំដៅត្រឹមតែក្នុងចំណោមតស្សូរជនទេ ប៉ុន្តែនៅកម្រិតសហគមន៍ផងដែរ ដែលមូលដ្ឋានគ្រឹះនៃសន្តិភាពប្រកបដោយចីរភាពត្រូវបានបណ្តុះឡើង [៣៥]។

ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសន្តិសុខ គឺជាសមាសធាតុសំខាន់មួយទៀតក្នុងសសរស្តម្ភនេះ។ ជាទូទៅ កិច្ចខិតខំប្រឹងប្រែងដើម្បីជ្រើសរើសនិងរក្សាទុកស្ត្រីនៅក្នុងកងកម្លាំងប៉ូលិស យោធា និងបេសកកម្មរក្សាសន្តិភាពមានសន្ទុះកើនឡើង ដែលជាភស្តុតាងបង្ហាញថាស្ត្រីមានទស្សនៈ និងគោលវិធីរួមមួយក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកសន្តិសុខ។

ឧទាហរណ៍ ការដាក់ពង្រាយកងរក្សាសន្តិភាពទាំងអស់ជាស្ត្រី នៅក្នុងប្រទេសលីបេរីយ៉ា (ពីប្រទេសឥណ្ឌា) បានគូសបញ្ជាក់ពីប្រសិទ្ធភាពនៃការបញ្ចូលទស្សនៈយេនឌ័រទៅក្នុងគ្រប់ទម្រង់នៃកិច្ចការសន្តិសុខ ដើម្បីកសាងទំនុកចិត្តជាមួយសហគមន៍មូលដ្ឋាន និងដោះស្រាយបញ្ហានានាដូចជាអំពើហិង្សាផ្លូវភេទ។ គំនិតផ្តួចផ្តើមទាំងនេះ បញ្ជាក់ពីតម្រូវការក្នុងការបញ្ចូលស្ត្រីទៅក្នុងវិស័យដែលជាប្រពៃណីត្រូវបានគ្រប់គ្រងដោយបុរស ដើម្បីបង្កើតស្ថាប័នសន្តិសុខមួយដែលមានស្ថិរភាពនិងគណនេយ្យភាព [៣៦]។

កិច្ចខិតខំបង្កើនការចូលរួម ក៏ទាមទារផងដែរនូវការដោះស្រាយឧបសគ្គជាប្រព័ន្ធ ដែលរារាំងភាពជាអ្នកដឹកនាំរបស់ស្ត្រី ដូចជាការរើសអើងយេនឌ័រ កង្វះលទ្ធភាពទទួលបានការអប់រំ និងបទដ្ឋានសង្គម-វប្បធម៌ ដែលកម្រិតតួនាទីជាសាធារណៈរបស់ស្ត្រី។

កម្មវិធី កសាងសមត្ថភាពជាក់លាក់អាចផ្តល់ភាពអស់អាចដល់ស្ត្រី ដោយផ្តល់ជាជំនាញ និងធនធានដែលត្រូវការដើម្បីចូលរួមធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ នៅប្រទេសរវ៉ាន់ដា គំនិតផ្តួចផ្តើមក្រោយរបបប្រល័យពូជសាសន៍ បានផ្តល់អាទិភាពដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ដែលធ្វើឱ្យប្រទេសនេះសម្រេចបាននូវអត្រាតំណាងរាស្ត្រជាស្ត្រីក្នុងរដ្ឋសភា ខ្ពស់បំផុតមួយក្នុងចំណោមប្រទេសដទៃទៀតក្នុងសកលលោក។

កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានជះឥទ្ធិពលជំរុញឱ្យមានការចូលរួមរបស់ស្ត្រីក្នុងវិស័យផ្សេងៗ និងជំរុញគោលនយោបាយជាតិទៅមុខ ដែលឆ្លុះបញ្ចាំងពីអាទិភាពដែលគិតគូរពីយេនឌ័រ។

ទស្សនៈទានអន្តរប្រសព្វ មានសារៈសំខាន់សម្រាប់សសរស្តម្ភការចូលរួមនេះ ដោយទទួលស្គាល់ថាបទពិសោធន៍ឆ្លងកាត់ និងឱកាសរបស់ស្ត្រី ត្រូវបានកំណត់ដោយអត្តសញ្ញាណប្រសព្វគ្នា ដូចជា ជាតិសាសន៍ អាយុ ពិការភាព និងស្ថានភាពសេដ្ឋកិច្ច-សង្គម។ ទស្សនៈទាននេះអាចធានាថា កិច្ចខិតខំបង្កើនការចូលរួមរបស់ស្ត្រី មានបរិយាបន្នដោយមិនទុកក្រុមងាយរងគ្រោះណាមួយចោលនោះទេ ហើយអាចសម្របតាមបរិបទចម្រុះផ្សេងៗ។ ឧទាហណ៍ ស្ត្រីជនជាតិដើមនៅប្រទេសក្វាតេម៉ាឡា ជាក្រុមស្ថិតនៅជួរមុខនៃយុទ្ធនាការតស៊ូមតិទាមទារសិទ្ធិដីធ្លី និងយុត្តិធម៌ សម្រាប់ភាពឃោរឃៅក្នុងសម័យសង្គ្រាម ដោយប្រការនេះបង្ហាញថា សសរស្តម្ភនៃការចូលរួម អាចជាផ្លូវឆ្ពោះទៅកាន់ការដោះស្រាយភាពអយុត្តិធម៌សង្គម [៣៧]។

សរុបមក សសរស្តម្ភនៃការចូលរួម មានន័យលើសពីការធានាឱ្យស្ត្រីមានភាពជាតំណាង តែជាការបង្កើតកន្លែងមួយដែលសំឡេងរបស់ស្ត្រីត្រូវបានយកចិត្តទុកដាក់ ឱ្យតម្លៃ និងរួមបញ្ចូលក្នុងការសម្រេចចិត្ត។ តាមរយៈការផ្តល់អាទិភាពដល់ការចូលរួមរបស់ស្ត្រី ឃើញថា ដំណើរការសន្តិភាពនិងសន្តិសុខកាន់តែមានសមធម៌ បរិយាបន្ន និងឆ្លុះបញ្ចាំងពីតម្រូវការចម្រុះនៃសង្គមច្រើនជាងមុន ដែលជាមូលដ្ឋានគ្រឹះនៃសន្តិភាពប្រកបដោយចីរភាព។

*“គួរឱ្យសោកស្តាយ យោងតាមការសិក្សាសកលរបស់ UN Women ២០១៥ បង្ហាញថា មានភាគរយស្ត្រីតិចតួចប៉ុណ្ណោះដែលបានចូលរួមក្នុងដំណើរការស្វែងរកសន្តិភាព។ លទ្ធផលវិជ្ជមានក្រោមការដឹកនាំដ៏សកម្មរបស់ស្ត្រី និងការចូលរួមក្នុងដំណើរការសន្តិភាព បានបញ្ជាក់យ៉ាងច្បាស់តាមទិន្នន័យជាក់ស្តែង។ ទោះយ៉ាងណាក៏ដោយ ឧបសគ្គមួយចំនួនផ្នែកឡូជីស្ទិច ហិរញ្ញវត្ថុ និងវប្បធម៌ ដែលរារាំងការចូលរួមពេញលេញរបស់ស្ត្រីនៅតែបន្តកើតមាននៅឡើយ”* [៣៨]។



# ភាពប្រទាក់ក្រឡាគ្នានៃសសរស្តម្ភ

ខណៈសសរស្តម្ភនីមួយៗផ្តោតលើផ្នែកខុសៗគ្នា ភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមករបស់សសរស្តម្ភទាំងនេះ មានភាពចាំបាច់សម្រាប់ការអនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ជារួម។

ឧទាហរណ៍ ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព ពឹងផ្អែកលើការចូលរួមដ៏មានអត្ថន័យ ដូចគ្នានឹងវិធានការការពារផងដែរ ត្រូវមានការចូលរួមពីការសង្គ្រោះនិងការស្តារឡើងវិញ។

ទំនាក់ទំនងទាំងនេះឆ្លុះបញ្ចាំងពីគោលដៅកាន់តែទូលាយនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីបង្កើតសន្តិភាពប្រកបដោយនិរន្តរភាពនិងបរិយាបន្ន ដែលដោះស្រាយទាំងវិសមភាពជាប្រព័ន្ធ និងតម្រូវការជាបន្ទាន់របស់ស្ត្រីនិងក្មេងស្រីមកពីគ្រប់អត្តសញ្ញាណ។

ការពិនិត្យមើលកិច្ចការងារសន្តិភាពនិងសន្តិសុខ ចេញពីជ្រុងនៃសសរស្តម្ភទាំងបួននៃ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បង្ហាញពីក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយ ដែលទទួលស្គាល់ស្ត្រីថាជាភ្នាក់ងារសកម្ម ជាជាងគ្រាន់តែជាអ្នកទទួលផល ក្នុងការតម្រង់ទិសសន្តិភាពសកល។

ផ្នែកបន្ទាប់ទៀតនៃសៀវភៅណែនាំនេះ នឹងឈ្វេងយល់កាន់តែស៊ីជម្រៅទៅក្នុងការអនុវត្តជាក់ស្តែងនៃសសរស្តម្ភទាំងនេះនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ក៏ដូចជាភាពជាប់ពាក់ព័ន្ធនៅក្នុងបរិបទប្រទេសកម្ពុជា។



# ១.៥. យុវជន សន្តិភាព និង សន្តិសុខ

របៀបវារៈយុវជន សន្តិភាព និងសន្តិសុខ (YPS) ដែលបានលើកឡើងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ២២៥០ នៅឆ្នាំ២០១៥ បានផ្តោតការយកចិត្តទុកដាក់ជាសកលចំពោះសារៈសំខាន់នៃតួនាទីរបស់យុវជនក្នុងការកសាងសន្តិភាព ការដោះស្រាយជម្លោះ និងការស្តារឡើងវិញក្រោយជម្លោះ។

របៀបវារៈយុវជន សន្តិភាព និងសន្តិសុខ (YPS) មិនត្រឹមតែចាត់ទុកយុវវ័យជាជនរងគ្រោះនៃជម្លោះប៉ុណ្ណោះទេ តែក៏ជាចលករនៃការផ្លាស់ប្តូរដ៏សំខាន់មួយ ដែលមានទស្សនៈនិងសមត្ថភាពពិសេសក្នុងការជំរុញឱ្យមានសន្តិភាពផងដែរ។ សសរស្តម្ភសំខាន់ៗនៃរបៀបវារៈនេះ មានភាពស្របគ្នាទៅនឹងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ និងផ្តោតលើការចូលរួមរបស់យុវជន ការការពារ ការទប់ស្កាត់ និងភាពជាដៃគូក្នុងដំណើរការសន្តិភាព និងសន្តិសុខ។

ទោះជាយ៉ាងណា ការអនុវត្តនៅតែមានភាពយឺតយ៉ាវដោយសារ ឧបសគ្គជាប្រព័ន្ធ ជាច្រើន ដូចជាមូលនិធិមិនគ្រប់គ្រាន់ និចលភាពស្ថាប័ន និងផ្នត់គំនិតរើសអើងសង្គម ដែលជារឿយៗមិនបានរាប់បញ្ចូលយុវជនក្នុងតួនាទីសម្រេចចិត្តទេ។

ពិតប្រាកដណាស់ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ក៏របៀបវារៈនេះនៅជួបបញ្ហាប្រឈមចម្បងៗជាច្រើន ក្នុងការសម្រេចបាននូវសមិទ្ធផលនៅកម្រិតស្ថាប័ន ដូចដែលរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បានសម្រេចចាប់តាំងពីមានសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCR) លេខ១៣២៥ ឆ្នាំ២០០០ មក។

ខណៈពេលដែលរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ គូសបញ្ជាក់ពីសារៈសំខាន់នៃការដាក់បញ្ចូលយុវជនក្នុងដំណើរការសម្រេចចិត្តនិងសន្តិភាព គេមើលឃើញថា អវត្តមាននៃយន្តការផ្លូវការ និងការប្តេជ្ញាចិត្តផ្នែកនយោបាយនៅកម្រិតទាប បានរាំងនូវការសម្រេចជោគជ័យពេញលេញរបស់របៀបវារៈនេះ។

ផ្ទុយទៅវិញ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ កើតចេញពីការគាំទ្រនិងការតស៊ូមតិសាធារណៈអស់ជាច្រើនទសវត្សរ៍ និងការបង្កើតផែនការសកម្មភាពជាតិ ដែលបានបង្ហាញផ្លូវសម្រាប់ប្រតិបត្តិការជាក់ស្តែង។ អវត្តមាននៃរចនាសម្ព័ន្ធនិងយន្តការអនុវត្តបែបនេះក្នុងរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ ធ្វើឱ្យបែកខ្ញែករវាងភាពនៃការអនុវត្តរបៀបវារៈនេះនៅទូទាំងតំបន់ និងរដ្ឋជាសមាជិក។

អង្គការសង្គមស៊ីវិលនិងបណ្តាញដឹកនាំដោយយុវជនបានដើរនៅជួរមុខក្នុងការជំរុញលើកកម្ពស់របៀបវារៈនេះនៅជុំវិញពិភពលោក ជាទូទៅ ជួយបំពេញចន្លោះខ្វះខាតរបស់រដ្ឋាភិបាលនិងស្ថាប័នផ្សេងៗទៀត [៣៩]។

ពីកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពនៅមូលដ្ឋានក្នុងតំបន់ជម្លោះ ទៅយុទ្ធនាការតស៊ូមតិជាអន្តរជាតិ អង្គការទាំងនេះបានគូសបញ្ជាក់ពីបទពិសោធន៍ដ៏រស់រវើករបស់យុវជន និងបានបង្ហាញពីសមត្ថភាពរបស់ពួកគេក្នុងការរួមចំណែកដល់ការកសាងសន្តិភាពប្រកបដោយនិរន្តរភាព។

ឧទាហរណ៍ នៅប្រទេសជាច្រើន ដូចជា ប្រទេសនីហ្សេរីយ៉ា [៤០] និងកូឡុំប៊ី [៤១] អង្គការយុវជននិងគំនិតផ្តួចផ្តើមដឹកនាំដោយយុវជនបានសម្រុះសម្រួលជម្លោះនៅមូលដ្ឋានដោយជោគជ័យ ចូលរួមក្នុងដំណើរការយុត្តិធម៌អន្តរកាល និងតស៊ូមតិសម្រាប់ការដាក់បញ្ចូលបទប្បញ្ញត្តិជាក់លាក់សម្រាប់យុវជនទៅក្នុងកិច្ចព្រមព្រៀងសន្តិភាព។

យ៉ាងណាក៏ដោយ ការខិតខំប្រឹងប្រែងរបស់

ពួកគេជារឿយៗក៏ជួបបញ្ហារាំងស្ទះដោយកត្តាកង្វះខាតធនធាន ការចូលរួមជានិមិត្តរូបប៉ុណ្ណោះពីសំណាក់អ្នកបង្កើតគោលនយោបាយ និងកង្វះភាពជាតំណាងនៅក្នុងរចនាសម្ព័ន្ធនយោបាយ។

ចំណុចសំខាន់មួយនៃភាពប្រសព្វគ្នារវាងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និង របៀបវារៈ យុវជន សន្តិភាព និងសន្តិសុខ គឺការដោះស្រាយវិសមភាពជាប្រព័ន្ធ ដែលធ្វើឱ្យជម្លោះហិង្សានិងការផាត់ចេញបន្តកើតមាន។ បទពិសោធន៍ពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដូចជា សារៈសំខាន់នៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCRs) ផ្សេងៗជាបន្តបន្ទាប់ដែលបន្តពង្រឹងនិងពង្រីករបៀបវារៈនេះ គឺអាចជាតម្រុយនិងមេរៀនសម្រាប់ពង្រឹងគន្លងនាពេលអនាគតរបស់ក្របខ័ណ្ឌរបៀបវារៈ យុវជន សន្តិភាព និងសន្តិសុខ។

ឧទាហរណ៍ ការទាមទារឱ្យមានសេចក្តីសម្រេចបន្ថែមទៅលើសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ **(UNSCR) លេខ២២៥០** អាចផ្តោតលើការពង្រឹងយន្តការគណនេយ្យភាព តម្រូវឱ្យមានការរួមបញ្ចូលយុវជនទៅក្នុងផែនការសកម្មភាពថ្នាក់ជាតិ និងបង្កើនធនធានហិរញ្ញវត្ថុសម្រាប់គំនិតផ្តួចផ្តើមសន្តិភាពផ្តោតលើយុវជន។

ភាពមានកម្រិតនៃការដាក់បញ្ចូលរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ ទៅក្នុងគោលនយោបាយជាតិ និងថ្នាក់តំបន់ នៅតែជាឧបសគ្គ។ ខណៈប្រទេសមួយចំនួនដូចជា ហ្វាំងឡង់[៤២] បានអនុម័តយុទ្ធសាស្ត្រជាតិដើម្បីលើកកម្ពស់គោលការណ៍របៀបវារៈយុវជន សន្តិភាព និងសន្តិសុខ រដ្ឋជាច្រើនទៅមិនទាន់មានវិធានការជាក់លាក់សម្រាប់ការអនុវត្តនៅឡើយ។

ភាពខុសគ្នានេះឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ពីបញ្ហាប្រឈម ដូចជា កង្វះឆន្ទៈនយោបាយនិងសមត្ថភាពស្ថាប័នក្នុងការផ្តល់អាទិភាពដល់យុវជនក្នុងក្របខ័ណ្ឌការងារសន្តិភាពនិងសន្តិសុខ។

លើសពីនេះទៅទៀត អន្តរប្រសព្វនៃភាពងាយរងគ្រោះ ដូចជាកត្តាយេនឌ័រ ជនជាតិភាគតិច និងស្ថានភាពសេដ្ឋកិច្ច-សង្គម កាន់តែធ្វើឱ្យក្រុមយុវជនដែលមកពីមជ្ឈដ្ឋានទាំងនេះបាត់ឱកាស ដែលនេះបង្ហាញពីសារៈសំខាន់នៃវិធីសាស្ត្រអន្តរាគមន៍បែបអន្តរប្រសព្វ ដែលទទួលស្គាល់និងដោះស្រាយបញ្ហាអត្តសញ្ញាណដ៏ស្មុគស្មាញទាំងនេះ។

ការជំរុញរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ ទាមទារវិធីសាស្ត្ររួមមួយ ដែលពង្រឹងភាពជាដៃគូរឹងមាំជាងមុនរវាងរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលដឹកនាំដោយយុវជន។

ការផ្លាស់ប្តូរផ្នត់គំនិតក៏ចាំបាច់ផងដែរ ដូចជា ពីការមើលឃើញយុវជនជាអ្នកទទួលផលអសកម្មនៅក្នុងកិច្ចខិតខំកសាងសន្តិភាព ទៅជាការទទួលស្គាល់ពួកគេថាជាតួអង្គសំខាន់ក្នុងការតម្រង់ទិសវិថីសន្តិភាពប្រកបដោយនិរន្តរភាព។

តាមរយៈការដោះស្រាយគម្លាតដែលមានស្រាប់ និងមេរៀនពីរបៀបវារៈ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក្របខ័ណ្ឌរបៀបវារៈយុវជន សន្តិភាព និងសន្តិសុខ មានសក្តានុពលក្នុងការផ្លាស់ប្តូរគោលនយោបាយសន្តិភាពនិងសន្តិសុខ និងធានាថាសំឡេងរបស់យុវជន ជាពិសេសយុវនារី ក្មេងស្រី និងយុវជនដែលមកពីក្រុមងាយរងគ្រោះ ត្រូវបានចាត់ទុកជាចម្បងក្នុងដំណើរការសម្រេចចិត្ត។និងការកសាងមេរៀនពីរបៀបវារៈ WPS ក្របខ័ណ្ឌ YPS មានសក្តានុពលក្នុងការផ្លាស់ប្តូរគោលនយោបាយសន្តិភាព និង សន្តិសុខ និងធានាថាសំឡេងរបស់យុវជន ជាពិសេសយុវនារី ក្មេងស្រី និងយុវជនដែលខ្វះខាត ស្ថិតនៅចំណុចស្នូលនៃដំណើរការក្នុងការសម្រេចចិត្ត។

# ១.៦. បញ្ហាថ្មីៗដែលកំពុងលេចឡើង

របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅតែមានថាមវន្តបន្តវិវឌ្ឍភាព ដើម្បីដោះស្រាយបញ្ហាប្រឈមជាសកលដែលកំពុងតែលេចរូបរាងថ្មី និងរួមបញ្ចូលវិធីសាស្ត្រច្នៃប្រឌិតនានា ។

ផ្នែកនេះនឹងឈ្វេងយល់អំពីប្រធានបទសំខាន់ៗចំនួនបួន ដែលកំណត់គន្លងនាពេលបច្ចុប្បន្ននិងអនាគតនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នោះគឺ សន្តិសុខមនុស្ស សន្តិភាពពេញលេញ គណនេយ្យភាព និងការរាយការណ៍។

## សន្តិសុខមនុស្ស៖ ការកែសម្រួលឡើងវិញនូវទស្សនៈសន្តិភាពនិងការអភិវឌ្ឍ

គោលគំនិតបែបប្រពៃណីនៃសន្តិសុខ ជាទូទៅផ្តោតលើអធិបតេយ្យភាពរបស់រដ្ឋនិងការការពារជាតិ។ ទោះយ៉ាងណាក៏ដោយ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ បានកំណត់ក្នុងន័យជំរុញការគាំទ្រគោលគំនិតនៃសន្តិសុខមនុស្សជាតិ ឱ្យកាន់តែទូលំទូលាយ ដោយផ្តល់អាទិភាពលើសុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់បុគ្គល។

ការផ្លាស់ប្តូរគំរូនៃទស្សនៈសន្តិសុខនេះ ទទួលស្គាល់ថាសន្តិសុខមិនត្រឹមតែជាអវត្តមាននៃសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងសន្តិសុខចេញពីភាពភ័យខ្លាច ការចង់បាន និងភាពមិនថ្លៃថ្នូរ។

បញ្ហាប្រឈមនៃសន្តិសុខមនុស្សមានលក្ខណៈយេនឌ័ររួមផ្សំ។ ស្ត្រីនិងក្មេងស្រី ជារឿយៗប្រឈមនឹងការកើនឡើងនៃភាពងាយរងគ្រោះដោយសារតែការជម្លៀសដោយបង្ខំ អស្ថិរភាពសេដ្ឋកិច្ច និងវិសមភាពជាប្រព័ន្ធ។ ឧទាហរណ៍៖ ជម្លៀសដោយបង្ខំ ដែលបណ្តាលមកពីបញ្ហាអាកាសធាតុនៅតំបន់ប៉ាស៊ីហ្វិកមានផលប៉ះពាល់ខ្លាំងមកលើស្ត្រីដែលងាយរងគ្រោះនឹងការបាត់បង់សិទ្ធិប្រើប្រាស់ដីធ្លី បញ្ហាជីវភាពរស់នៅ និងប្រព័ន្ធគាំពារសង្គមអំឡុងពេលមានវិបត្តិបរិស្ថាន។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះទាមទារការរួមបញ្ចូលយុទ្ធសាស្ត្រឆ្លើយតបយេនឌ័រក្នុងការបន្សាំអាកាសធាតុ និងមធ្យោបាយកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR) ។

ជាងនេះទៅទៀត សន្តិសុខមនុស្សគូសបញ្ជាក់ពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃការគំរាមកំហែងជាសកល ដូចជាជំងឺរាតត្បាត ការវាយប្រហារតាមអ៊ីនធឺណិត និងជម្លោះធនធាន។ ការគំរាមកំហែងទាំងនេះ ទាមទារវិធីសាស្ត្រចម្រុះ ដែលផ្តោតលើការចូលរួមរបស់ស្ត្រីក្នុងការធ្វើការសម្រេចចិត្ត ចាប់តាំងពីកម្រិតថ្នាក់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសហគមន៍ រហូតដល់វេទិកាអភិបាលកិច្ចសុខភាពអន្តរជាតិ។

## សន្តិភាពពេញលេញ៖ លើសពីបទឈប់បាញ់និងសន្ធិសញ្ញា

របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ កៀរគងការគាំទ្រឱ្យមានសន្តិភាពពេញលេញ ដែលមានលើសពីការបញ្ឈប់អំពើហិង្សា ដើម្បីដោះស្រាយឫសគល់ជម្លោះ និងជំរុញឱ្យមាននិរន្តរភាព រួមទាំងការអភិវឌ្ឍ។ វិធីសាស្ត្រនេះរួមបញ្ចូលការពង្រឹងអំណាចសេដ្ឋកិច្ច ការរួបរួមសង្គម និងការកសាងយុត្តិធម៌ប្រកបដោយចីរភាព ដោយទទួលស្គាល់ថា សន្តិភាពអាចស្ថិតស្ថេរបាន នៅពេលដែលវាដោះស្រាយបាននូវវិសមភាពជាប្រព័ន្ធ។

សន្តិភាពពេញលេញក៏រួមបញ្ចូលទស្សនៈយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការស្តារឡើងវិញក្រោយជម្លោះ

ផងដែរ។ ឧទាហរណ៍ កម្មវិធីសំណងនៅ **ប្រទេសកូឡុំប៊ី** បានរួមបញ្ចូលវិធានការជាក់លាក់ទាក់ទងនឹងយេនឌ័រ ដើម្បីគាំទ្រស្ត្រីដែលទទួលរងអំពើហិង្សាផ្លូវភេទអំឡុងពេលជម្លោះ។ វិធានការទាំងនេះមានគោលបំណងស្ដារឡើងវិញនូវសេចក្ដីថ្លៃថ្នូរ និងជាផ្លូវសម្រាប់សមាហរណកម្មសេដ្ឋកិច្ច និងសង្គម ដែលបង្ហាញពីរបៀបដែលវិធីសាស្ត្របែបពេញលេញមេះអាចបង្កើតបានលទ្ធផលយូរអង្វែងសម្រាប់សហគមន៍រងផលប៉ះពាល់។

គោលគំនិតនៃសន្តិភាពពេញលេញមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងជាមួយនឹង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDGs ជាពិសេសគោលដៅទី៥ (សមភាពយេនឌ័រ) និងគោលដៅទី១៦ (សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ)។

## គណនេយ្យភាព៖ ការដាក់ឱ្យប្រព័ន្ធនិងតួអង្គមានការទទួលខុសត្រូវ

គណនេយ្យភាព គឺជាមូលដ្ឋានគ្រឹះនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដែលធានាថាការប្ដេជ្ញាចិត្តចំពោះសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចស្ត្រីបានទទួលលទ្ធផលជាក់ស្ដែង។

ចំណុចនេះតម្រូវឱ្យមានយន្តការដ៏រឹងមាំដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពថ្នាក់ជាតិ ក្របខ័ណ្ឌថ្នាក់តំបន់ និងសេចក្ដីសម្រេចអន្តរជាតិ។

កត្តាសំខាន់មួយ គឺថវិកាឆ្លើយតបនឹងយេនឌ័រ ដែលបែងចែកធនធានហិរញ្ញវត្ថុដល់កម្មវិធីជំរុញគោលដៅរបៀបវារៈ WPSនេះ។ ប្រទេសជាច្រើន ដូចជា រវ៉ាន់ដា បានបង្ហាញពីរបៀបបែងចែកថវិកាយេនឌ័រ ដែលអាចបង្កើនគណនេយ្យភាព តាមការប្រើប្រាស់មូលនិធិពង្រឹងសេដ្ឋកិច្ចស្ត្រី ការអប់រំ និងសុខភាពក្នុងបរិបទនៃការស្ដារឡើងវិញក្រោយជម្លោះ។

គណនេយ្យភាពក៏ពាក់ព័ន្ធការដោះស្រាយបញ្ហានិទណ្ឌភាពពាក់ព័ន្ធអំពើហិង្សាផ្អែកលើយេនឌ័រផងដែរ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានបង្កើតគំរូភាពមួយ ដោយកាត់ទោសបទល្មើសអំពើហិង្សាផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម ដែលការណ៍នេះបានធ្វើសារយ៉ាងច្បាស់ថា អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាការរំលោភបំពានច្បាប់អន្តរជាតិ។

ទោះយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមាន រួមមាន ការមិនរាយការណ៍ ក្របខ័ណ្ឌផ្លូវច្បាប់មិនគ្រប់គ្រាន់ និងលទ្ធភាពទទួលបានយុត្តិធម៌នៅមានកម្រិតសម្រាប់អ្នករស់នៅក្នុងតំបន់ជម្លោះ។

លើសពីនេះ គណនេយ្យភាពត្រូវរាប់បញ្ចូលទាល់តួអង្គមិនមែនរដ្ឋ និងអង្គការអន្តរជាតិនានាផងដែរ។ ទីភ្នាក់ងារមនុស្សធម៌ត្រូវតែគោរពគោលការណ៍ មិនបង្កគ្រោះថ្នាក់ (Do No Harm) និងធានាថា ការអន្តរាគមន៍របស់ខ្លួនមិនបន្តបង្កើតឱ្យមានវិសមភាពដែលមានស្រាប់។

របាយការណ៍ដែលមានតម្លាភាព និងយន្តការត្រួតពិនិត្យ មានសារៈសំខាន់ណាស់ក្នុងការកំណត់ឱ្យតួអង្គទាំងនេះមានការទទួលខុសត្រូវចំពោះឥទ្ធិពលរបស់ពួកគេលើក្រុមងាយរងគ្រោះ។

## ការរាយការណ៍៖ ការផ្សារភ្ជាប់គម្លាតរវាងគោលនយោបាយនិងការអនុវត្ត

របាយការណ៍មានប្រសិទ្ធភាព គឺជាចំណុចសំខាន់សម្រាប់ផ្សារភ្ជាប់គម្លាតរវាងការប្ដេជ្ញាចិត្តថ្នាក់លើ និងការពិតជាក់ស្ដែងនៅថ្នាក់ក្រោមក្នុងមូលដ្ឋាន។ របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គឺជាយន្តការសំខាន់សម្រាប់តាមដានវឌ្ឍនភាព បញ្ជាក់ពីភាពជោគជ័យ និងកំណត់គម្លាតនៃការអនុវត្ត។ របាយការណ៍ទាំងនេះបង្ហាញភស្តុតាងស៊ីជម្រៅដែលផ្ដល់ព័ត៌មានពីការកែប្រែគោលនយោបាយ និងការបែងចែកធនធាន។

ទោះយ៉ាងណាក៏ដោយ របាយការណ៍ជារឿយៗមានភាពរាំងស្ទះដោយការប្រមូលទិន្នន័យមិនស៊ីសង្វាក់គ្នា ការខ្វះខាតស្ថិតិដែលគិតគូរពីយេនឌ័រ និងការចូលរួមមានកម្រិតរបស់សង្គមស៊ីវិល។ ការដោះស្រាយគម្លាតទាំងនេះ ទាមទារឱ្យមានការពង្រឹងសមត្ថភាពមូលដ្ឋានសម្រាប់ការប្រមូលនិងការវិភាគទិន្នន័យ។ ជាពិសេស វិធីសាស្ត្រដែលសហគមន៍សហការរៀបចំឧបករណ៍ត្រួតពិនិត្យ អាចពង្រឹងគុណភាពនិងភាពពាក់ព័ន្ធនឹងរបាយការណ៍។

ភាពរីកចម្រើនបច្ចេកវិទ្យាថ្មីៗក៏ផ្តល់ឱកាសកែលម្អរបាយការណ៍ផងដែរ។ ឧទាហរណ៍ ថ្នាលឌីជីថលអាចជួយសម្រួលការប្រមូលទិន្នន័យជាក់ស្តែងស្តីពីជម្លោះពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស ដែលអាចជួយដល់ការអន្តរាគមន៍ទាន់ពេលវេលា។

ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់បច្ចេកវិទ្យាត្រូវតែមកជាមួយនឹងកិច្ចការពារ ដើម្បីការពារឯកជនភាព និងសុវត្ថិភាពរបស់ជនងាយរងគ្រោះ។

## ការទទួលស្គាល់និងឆ្លើយតបនឹងការងារថែទាំ៖

បញ្ហាលេចឡើងចុងក្រោយនេះ គឺការថែទាំដែលជាញឹកញយនៅតែត្រូវគេមើលរំលង តែវាជាទិដ្ឋភាពជាក់ស្តែងនៅមូលដ្ឋានដែលទ្រទ្រង់សន្តិភាព សន្តិសុខ និងសមភាពយេនឌ័រ ដោយសារតែស្ត្រីនិងអ្នក មានអត្តសញ្ញាណយេនឌ័រចម្រុះដែលរស់នៅក្នុងបរិបទរងផលប៉ះពាល់ដោយជម្លោះនិងបរិបទផុយស្រួយ បន្តទទួលបន្ទុកការងារថែទាំមិនមានកម្រៃ ឬបានកម្រៃតិច។

ការណ៍នេះ កម្រិតការចូលរួមពេញលេញរបស់ពួកគេក្នុងការកសាងសន្តិភាព អភិបាលកិច្ច និងការស្តារសេដ្ឋកិច្ចឡើងវិញ ខណៈដែលអវត្តមានគោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធ ដែលគិតគូរពីការថែទាំ បន្តបង្កើតវិសមភាពយេនឌ័រ និងរារាំងកិច្ចខិតខំប្រឹងប្រែងដើម្បីកសាងភាពធន់ និងសន្តិភាពប្រកបដោយចីរភាព។

មានការឯកភាពលេចឡើងនាពេលថ្មីៗនេះ ដែលថារបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវតែពង្រីកការផ្តោតរបស់ខ្លួនទៅលើការទទួលស្គាល់សារៈសំខាន់នៃការថែទាំ ក្នុងការពង្រឹងការងារសន្តិភាពនិងសន្តិសុខ។ ការងារថែទាំ (មិនថាបានកម្រៃឬមិនមានកម្រៃ ជាផ្លូវការ ឬមិនផ្លូវការ) គឺជាគន្លឹះ ដែលជាញឹកញាប់ត្រូវបានមើលរំលងក្នុងការងារកសាងភាពធន់និងសន្តិសុខ។

***"ក្នុងការស្ទង់មតិឆ្នាំ ២០២០ អ្នកជំនាញផ្នែកកសាងសន្តិភាព និងអភិវឌ្ឍន៍ទូទាំងសកលលោក ដែលមានតួនាទីថែទាំ និងបានចូលរួមក្នុងការស្ទង់មតិនេះ ចំនួន ៩២% បាននិយាយថាការងារថែទាំបានប៉ះពាល់ដល់ការងារវិជ្ជាជីវៈរបស់ពួកគេក្នុងវិស័យនេះ ខណៈដែល ៨០% និយាយថាតួនាទី ថែទាំបានរារាំងដល់ការរីកចម្រើនក្នុងអាជីព និងកាត់បន្ថយឱកាសក្នុងការឡើងតំណែង។"*** ៤៣

ការសិក្សាស្រាវជ្រាវដែលនឹងចេញផ្សាយដោយ អង្គការនារីដើម្បីសន្តិភាព និងសាកលវិទ្យាល័យ Monash បានបង្ហាញថា របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដែលឆ្លើយតបនឹងយេនឌ័រ ត្រូវតែគិតគូរពីឥទ្ធិពលនៃការងារថែទាំ មកលើស្ត្រីដែលអាចរារាំង ការចូលរួមរបស់ពួកគេក្នុងដំណើរការកសាងសន្តិភាព អភិបាលកិច្ច និងស្ថាប័នសន្តិសុខ។" ១

កង្វះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៃការថែទាំ (ដូចជាសេវាថែទាំកុមារក្នុងតម្លៃសមរម្យ ការឈប់សម្រាកមាតុភាពនិងបិតុភាព និងការគាំពារសង្គម) មិនត្រឹមតែធ្វើឱ្យមានវិសមភាពយេនឌ័រដុនដាបប៉ុណ្ណោះទេ ថែមទាំងកម្រិតសមត្ថភាពរបស់ស្ត្រីនិងក្រុមដែលមានអត្តសញ្ញាណយេនឌ័រចម្រុះផងដែរក្នុងការចូលរួមទប់ស្កាត់ជម្លោះ និងក្នុងកិច្ចខំប្រឹងប្រែងដោះស្រាយ និងស្តារឡើងវិញឱ្យបានពេញលេញ។

លើសពីនេះទៅទៀត បន្ទុកនៃការថែទាំ គឺកាន់តែធ្ងន់ធ្ងរនៅក្នុងស្ថានភាពវិបត្តិ ដែលជម្លៀសដោយបង្ខំ ភាពមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ច និងការបំផ្លិចបំផ្លាញសុខភាពនិងសេវាសង្គម បង្កឱ្យមានវិសមភាពយេនឌ័រកាន់តែខ្លាំង។

ក្របខ័ណ្ឌសន្តិសុខសកលត្រូវដាក់បញ្ចូលគោលនយោបាយឆ្លើយតបនឹងការថែទាំ ដែលធានាឱ្យមានការបែងចែកឡើងវិញប្រកបដោយសមធម៌នូវការងារការថែទាំដែលថាវាមិនមែនតួនាទីផ្តាច់មុខរបស់ស្ត្រីតែម្នាក់នោះទេ ធ្វើការពង្រឹងការគាំពារសង្គម និងចាត់ទុកការថែទាំ ជាធាតុចូលដ៏សំខាន់មួយនៃសន្តិភាព និងស្ថិរភាព។

ការរួមបញ្ចូលការថែទាំទៅក្នុង របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដើរទន្ទឹមគ្នាជាមួយក្របខ័ណ្ឌសកល ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅទី៥ (SDG5) (សមភាពយេនឌ័រ) និង គោលដៅទី៨ (SDG8) (ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច) ពង្រឹងឡើងវិញនូវសេចក្តីត្រូវការសម្រាប់គោលនយោបាយ ដែលគាំទ្រទាំងយុត្តិធម៌សេដ្ឋកិច្ចនិងនិរន្តរភាពនៃសន្តិភាព។



# ជំពូកទី ២

## បរិបទថ្នាក់តំបន់

ផែនការសកម្មភាព និងយុទ្ធសាស្ត្រថ្នាក់តំបន់ មានសារៈសំខាន់ក្នុងការប្រែក្លាយរបៀបវារៈសកលរបស់របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ទៅជាក្របខ័ណ្ឌដែលអាចអនុវត្តបាន ស្របតាមបរិបទជាក់ស្តែងក្នុងថ្នាក់តំបន់។ ផែនការសកម្មភាពថ្នាក់តំបន់ (RAP) មានគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាសមាជិក និងគោលនយោបាយសុខដុមរមនា និងដើម្បីដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងសន្តិភាព និងសន្តិសុខឆ្លងដែន ស្របពេលដែលឆ្លុះបញ្ចាំងពីអាទិភាពជាក់ស្តែងក្នុងតំបន់។



# យុទ្ធសាស្ត្រ និងផែនការសកម្មភាព ថ្នាក់តំបន់៖

ក្របខ័ណ្ឌលទ្ធផលនៃទ្វីបអាហ្វ្រិក សម្រាប់ការត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅទ្វីបអាហ្វ្រិក (២០១៨-២០២៨)

ផែនការសកម្មភាពថ្នាក់តំបន់របស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ស្តីពី របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ (២០២២)

ផែនការសកម្មភាពថ្នាក់តំបន់ របស់ សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកកណ្តាល (ECCAS) សម្រាប់ការអនុវត្តសេចក្តីសម្រេចលេខ ១៣២៥ និងសេចក្តីសម្រេចពាក់ព័ន្ធរបស់ក្រុមប្រឹក្សាសន្តិសុខ (២០២០-២០២៤)

សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច (ECOWAS) នាយកដ្ឋានកិច្ចការនយោបាយ សន្តិភាព និងសុវត្ថិភាព (PAPS)៖ គោលការណ៍ណែនាំស្តីពី WPS (២០២០)

ផែនការសកម្មភាពស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់សហភាពអឺរ៉ុប (EU) (២០១៩-២០២៤)

ផែនការសកម្មភាពថ្នាក់តំបន់នៃសន្និសីទអន្តរជាតិស្តីពីតំបន់បឹងធំ (ICGLR) សម្រាប់ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ (២០១៨-២០២៣)

ផែនការសកម្មភាពប្រតិបត្តិនៃសម្ព័ន្ធរដ្ឋអារ៉ាប់ (LAS) ដើម្បីការពារស្ត្រីនៅក្នុងតំបន់អារ៉ាប់៖ សន្តិភាព និងសន្តិសុខ (២០១៥-២០៣០)

គោលនយោបាយសន្តិភាព និងសន្តិសុខរបស់ស្ត្រី នៃអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (ណាតូ) (២០២៤)

អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ស្តីពីការអនុវត្តរបៀបវារៈ WPS នៅក្នុងតំបន់ OSCE (២០២០)

ផែនការសកម្មភាពថ្នាក់តំបន់របស់វេទិកាតំបន់ប៉ាស៊ីហ្វិក (PIF) (២០១២-២០១៥)

យុទ្ធសាស្ត្រតំបន់នៃសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (SADC) ស្តីពី របៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ (២០១៨-២០២២)

ក្របខ័ណ្ឌតំបន់នៃសហគមន៍អាហ្វ្រិកខាងកើត (EAC) ស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ (២០១៥-២០១៩)

អាជ្ញាធរអន្តររដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍ (IGAD) នៅក្នុងផែនការសកម្មភាពតំបន់អាហ្វ្រិកខាងកើត ស្តីពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ (២០០០) និង១៨២០ (២០០៨) (២០២៣-២០៣០)។

***ប្រភពឯកសារ៖*** WPS Focal Points Network https://wpsfocalpointsnetwork.org/regional-action-plans

# ២.១ ការអនុវត្ត របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងថ្នាក់តំបន់មួយចំនួន

## តំបន់អឺរ៉ុប

សហភាពអឺរ៉ុប (EU) គឺជាអ្នកដឹកនាំបង្កើតរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ តាមរយៈក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ ដោយប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនក្នុងនាមជាតួអង្គសកលមួយ។ យុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបស្តីពី របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ បានអនុម័តក្នុងឆ្នាំ២០១៨ និងអមជាមួយផែនការសកម្មភាពថ្នាក់តំបន់ (២០១៩-២០២៤) ដែលរួមបញ្ចូលគោលការណ៍របៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងសកម្មភាព និងគោលនយោបាយសន្តិសុខ។ ក្របខ័ណ្ឌទាំងនេះ សង្កត់ធ្ងន់លើការចូលរួមរបស់ស្ត្រីក្នុងការចរចាសន្តិភាព ការដោះស្រាយអំពើហិង្សាផ្លូវភេទ ដែលកើតមានក្នុងជម្លោះ និងការធានាឱ្យមានការឆ្លើយតបផ្នែកមនុស្សធម៌លើបញ្ហាយេនឌ័រ [៤៤]។

យន្តការរបស់សហភាពអឺរ៉ុប រួមមានការផ្តល់មូលនិធិដល់គំនិតផ្តួចផ្តើមទាក់ទងនឹងរបៀបវារៈនេះ នៅតំបន់ដែលងាយរងគ្រោះ និងមានផលប៉ះពាល់ពីជម្លោះ និងការអនុវត្តវិធីសាស្ត្រដែលគិតគូរយេនឌ័រ នៅក្នុងបេសកកម្មនៃសន្តិសុខទូទៅ និងគោលនយោបាយការពារ (CSDP)។ ឧទាហរណ៍ សហភាពអឺរ៉ុបចូលរួមគាំទ្រយ៉ាងសកម្មលើគំនិតផ្តួចផ្តើមក្នុងការផ្សះផ្សាដែលដឹកនាំដោយស្ត្រីនៅ តំបន់បាល់កង់ខាងលិច [៤៥]។

ទោះយ៉ាងណាក៏ដោយ មានការរិះគន់ទៅលើភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុវត្តសម្រាប់រដ្ឋជាសមាជិក និងតម្រូវការឱ្យមានវិធានការគណនេយ្យភាពកាន់តែរឹងមាំឡើង [៤៦]។

# តំបន់អាហ្វ្រិក

របៀបវារៈ ស្ដីពី ស្ត្រី សន្តិភាព និងសន្តិសុខ នៅអាហ្វ្រិក «មានប្រវត្តិនិងប្រភពដើមនៅក្នុងសេចក្ដីប្រកាស Windhoek ឆ្នាំ ២០០០ ដែលឈានទៅដល់ការបង្កើត និងអនុម័តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥» [៤៧]។

ចាប់តាំងពីពេលនោះមក តំបន់អាហ្វ្រិកមានការរីកចម្រើនក្នុងវិស័យនេះ ដោយផ្ដល់ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ក្នុងការបង្កើតយន្តការស្ថាប័នសម្រាប់ការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ។

រដ្ឋជាសមាជិកចំនួនជាងសាមសិបបានបង្កើតផែនការសកម្មភាពថ្នាក់ជាតិ ដើម្បីអនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ខណៈដែលក្របខ័ណ្ឌតំបន់ផ្សេងទៀត ក៏បានដឹកនាំដោយសហភាពអាហ្វ្រិក (AU) ផងដែរ។

ឧទាហរណ៍ ពិធីសារ Maputo បានផ្ដល់ជាមូលដ្ឋានគ្រប់ជ្រុងជ្រោយសម្រាប់សិទ្ធិស្ត្រី រួមទាំងការចូលរួមក្នុងដំណើរការនយោបាយ និងសមភាពសង្គម។

សហភាពអាហ្វ្រិក (AU) ក៏បានបន្តអនុម័ត ក្របខ័ណ្ឌលទ្ធផលនៃទ្វីបអាហ្វ្រិក (CRF) សម្រាប់ការត្រួតពិនិត្យ និងការរាយការណ៍ពីការអនុវត្តរបៀបវារៈស្ដីពី ស្ត្រី សន្តិភាព និងសន្តិសុខ នៅទ្វីបអាហ្វ្រិក (២០១៨-២០២៨)។ ក្របខ័ណ្ឌ CRF ដើរតួជាឧបករណ៍ដើម្បីបង្កើនគណនេយ្យភាពក្នុងចំណោមរដ្ឋសមាជិកដោយតាមដានការវិវឌ្ឍជាប្រព័ន្ធនៅក្នុងការអនុវត្តការប្ដេជ្ញាចិត្តនៃរបៀបវារៈនេះ។

អង្គការអនុតំបន់ក៏បានធ្វើសកម្មភាពយ៉ាងផុសផុលផងដែរ ក្នុងការអនុវត្តគោលការណ៍ របៀបវារៈស្ដីពី ស្ត្រី សន្តិភាព និងសន្តិសុខ ។

ឧទាហរណ៍ សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច (ECOWAS) បានអនុវត្តផែនការសកម្មភាពថ្នាក់តំបន់។ នៅឆ្នាំ២០២១ សេចក្ដីណែនាំគ្រប់ជ្រុងជ្រោយនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) ដែលមានគោលបំណងគាំទ្ររដ្ឋជាសមាជិកក្នុងការរួមបញ្ចូលគោលការណ៍ WPS ទៅក្នុងគោលនយោបាយ និងកម្មវិធីជាតិ ដែលផ្ដល់នូវវិធីសាស្ត្រថ្នាក់តំបន់ដ៏សម្បូរបែបមួយក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព និងសន្តិសុខ [៤៨]។

# ទ្វីបអាមេរិក

នៅទូទាំងទ្វីបអាមេរិក ទោះបីជាខ្វះការបង្កើតផែនការសកម្មភាពថ្នាក់តំបន់ក៏ដោយ ក៏អង្គការក្នុងតំបន់បានខិតខំប្រឹងប្រែងដើម្បីដាក់បញ្ចូលគោលការណ៍នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងរបៀបវារៈទូទៅនៃសិទ្ធិមនុស្ស និងការអភិវឌ្ឍដែរ។

អង្គការនៃរដ្ឋអាមេរិក (OAS) តាមរយៈគណៈកម្មការស្ត្រីអន្តរអាមេរិក (CIM) មានសកម្មភាពយ៉ាងផុសផុលក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រី។

គណៈកម្មការស្ត្រីអន្តរអាមេរិក (CIM) បានធ្វើការយ៉ាងខ្លាំងដើម្បីដាក់បញ្ចូលគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងបញ្ហាសន្តិភាព និងសន្តិសុខ [៤៩]។

ទន្ទឹមគ្នានឹងអង្គការនៃរដ្ឋអាមេរិក (OAS) និងគណៈកម្មការស្ត្រីអន្តរអាមេរិក (CIM) ក្រុមប្រឹក្សាការពារជាតិអន្តរអាមេរិក (IADB) ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅអាមេរិក។ ប្រតិបត្តិការក្រោមឱវាទអង្គការនៃរដ្ឋអាមេរិក (OAS) ក្រុមប្រឹក្សាការពារជាតិអន្តរអាមេរិក (IADB) បានបង្កើតកម្មវិធី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីជាការគាំទ្រដល់រដ្ឋជាសមាជិកក្នុងការអនុវត្តគោលការណ៍ របៀបវារៈនេះ។

កម្មវិធីនេះដំណើរការដោយមានការសហការជាមួយដៃគូផ្សេងៗ រួមទាំង គណៈកម្មការស្ត្រីអន្តរអាមេរិក (CIM) ដើម្បីដាក់បញ្ចូលយេនឌ័រទៅក្នុងវិស័យការពារជាតិ និងសន្តិសុខទូទាំងតំបន់ [៥០]។

# តំបន់ប៉ាស៊ីហ្វិក

វេទិកាកោះប៉ាស៊ីហ្វិក (PIF) ជាយន្តការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ លើកកម្ពស់សមភាពយេនឌ័រ និងសន្តិសុខមនុស្សជាតិនៅទូទាំងតំបន់។

ការទទួលស្គាល់ភាពងាយរងគ្រោះរបស់តំបន់ប៉ាស៊ីហ្វិក (ដូចជាផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ អត្រាខ្ពស់នៃការរំលោភបំពានយេនឌ័រ និងជម្លោះអន្តរសហគមន៍) ផែនការសកម្មភាពក្នុងតំបន់ប៉ាស៊ីហ្វិកស្តីពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ (២០១២-២០១៥) ចែងពីក្របខ័ណ្ឌសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ។

ខណៈដែលបច្ចុប្បន្ននេះ រយៈពេលជិតដប់ឆ្នាំហើយក៏ដោយ ក៏ផែនការសកម្មភាពថ្នាក់តំបន់ បានចាក់គ្រឹះយ៉ាងរឹងមាំក្នុងការដាក់បញ្ចូលគោលការណ៍ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅទូទាំងតំបន់ និងបន្តបំផុសគំនិតនៃកិច្ចខិតខំប្រឹងប្រែងតាមរយៈគំនិតផ្តួចផ្តើមថ្នាក់ជាតិ។

ផែនការសកម្មភាពថ្នាក់តំបន់ ផ្តោតលើការកសាងភាពធន់តាមរយៈការដាក់បញ្ចូលការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការជំរុញវឌ្ឍនភាពការចូលរួមរបស់ស្ត្រីក្នុងដំណើរការសន្តិភាព និងដោះស្រាយឫសគល់នៃបញ្ហាអសន្តិសុខ។ គំនិតផ្តួចផ្តើមតំបន់នេះបានបំពេញបន្ថែមដោយការអភិវឌ្ឍន៍ផែនការសកម្មភាពថ្នាក់ជាតិ ដោយរដ្ឋជាសមាជិក ដើម្បីធានាថាគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានអនុវត្តនៅថ្នាក់ជាតិ។

ឧទាហរណ៍ ផែនការសកម្មភាពថ្នាក់ជាតិទី២របស់ប្រទេសទីម័រខាងកើត ផ្តល់អាទិភាពដល់វិធីសាស្ត្រដោះស្រាយបញ្ហាយេនឌ័រក្នុងការឆ្លើយតបគ្រោះមហន្តរាយ និងការកសាងសន្តិភាព ឆ្លុះបញ្ចាំងពីឥទ្ធិពលរបស់ផែនការសកម្មភាពថ្នាក់តំបន់ (RAP) [៥១]។

លើសពីនេះ វេទិកាកោះប៉ាស៊ីហ្វិក (PIF) បានផ្តល់អាទិភាពដល់មូលដ្ឋាន វិធីសាស្ត្រជំរុញដោយសហគមន៍ក្នុងការកសាងសន្តិភាព ទទួលស្គាល់តួនាទីសំខាន់របស់បណ្តាញស្ត្រីក្នុងការរក្សាភាពស្អិតរមួតក្នុងសង្គម។ ឧទាហរណ៍ វេទិកាបានគាំទ្រគំនិតផ្តួចផ្តើមការពង្រីកសំឡេងរបស់ស្ត្រីក្នុងដំណើរការនៃការសម្រេចចិត្ត នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយភាពតានតឹងអន្តរសហគមន៍ [៥២]។

# សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍៖

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) បានបោះជំហានយ៉ាងសំខាន់ក្នុងការរួមបញ្ចូលរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងក្របខ័ណ្ឌថ្នាក់តំបន់របស់ខ្លួន ដោយការអនុម័តផែនការសកម្មភាពតំបន់អាស៊ានស្តីពីរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ( RPA-WPS) ក្នុងឆ្នាំ២០២២ ដែលជាព្រឹត្តិការណ៍ដ៏សំខាន់មួយ។ ផែនការសកម្មភាពតំបន់ នេះ ចែងពីមូលដ្ឋានគ្រឹះក្នុងការជំរុញភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការលើកកម្ពស់វិធីសាស្ត្រប្រកបដោយបរិយាបន្នក្នុងការកសាងសន្តិភាព និងសន្តិសុខ។

បន្ថែមពីលើផែនការសកម្មភាពថ្នាក់តំបន់ កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើមូលដ្ឋានីយកម្មនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣២៥ ក្នុងតំបន់បានចូលរួមដោយមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងស្ថាប័នក្នុងតំបន់។

ប្រទេសកម្ពុជា ក្នុងនាមជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ បានដើរតួនាទីជាអ្នកដឹកនាំដ៏សំខាន់ក្នុងដំណើរការក្នុងថ្នាក់តំបន់នេះ៖

*«កម្ពុជា គឺជាសមាជិកដំបូងមួយនៃក្រុមប្រឹក្សាអាស៊ានស្តីពី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដែលបានធ្វើការពេញទំហឹងក្នុងការដឹកនាំការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ (RPA-WPS)... កម្ពុជាបន្តធ្វើជាប្រធានក្រុមប្រឹក្សាអាស៊ានស្តីពី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពថ្នាក់តំបន់នេះ ក៏ដូចជាការដឹកនាំការរៀបចំគោលការណ៍ណែនាំ និងកញ្ចប់ឧបករណ៍សម្រាប់រដ្ឋសមាជិកអាស៊ាន ដើម្បីធ្វើមូលដ្ឋានីយកម្ម ផែនការសកម្មភាពថ្នាក់តំបន់ ស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ បន្ថែមទៀតក្នុងបរិបទជាតិរបស់ពួកគេ ដោយមានការគាំទ្រពី UN Women»* [៩៣]។

គោលការណ៍ណែនាំនិងកញ្ចប់ឧបករណ៍អាស៊ានស្តីពី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គូសបញ្ជាក់ពីសារៈសំខាន់ ចំពោះការប្តេជ្ញាចិត្តក្នុងការដាក់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងសកម្មភាពកម្រិតសហគមន៍។

ផែនការសកម្មភាពថ្នាក់តំបន់ ក៏មានឥទ្ធិពលលើយន្តការមួយចំនួន ដូចជាគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) និងវិទ្យាស្ថានអាស៊ានសម្រាប់សន្តិភាព និងការផ្សះផ្សា (ASEAN-IPR) ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាសមាជិក។

យន្តការទាំងនេះ មានគោលបំណងពង្រឹងសមត្ថភាពរដ្ឋជាសមាជិកក្នុងការអនុវត្តគោលការណ៍នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ខណៈពេលកំពុងដោះស្រាយបញ្ហាប្រឈមផ្នែកសន្តិសុខក្នុងតំបន់ ដូចជាការជម្លៀសដែលបណ្តាលមកពីអាកាសធាតុ និងឧក្រិដ្ឋកម្មឆ្លងដែន។

បើទោះជាមានការរីកចម្រើនទាំងនេះក៏ដោយ ក៏ការអនុវត្តនៅតែមិនស្មើគ្នាក្នុងបណ្តាប្រទេសអាស៊ានដែលធនធាននៅមានកម្រិត និងឆន្ទៈផ្សេងៗគ្នា ដែលជាហេតុបង្ហាញឱ្យឃើញពីឧបសគ្គនានា។

ក្រុមអ្នកតស៊ូមតិ រួមទាំងក្រុមអ្នកធ្វើការលើការងារសិទ្ធិស្ត្រីនៅទូទាំងថ្នាក់តំបន់ បន្តជំរុញឱ្យមានយន្តការគណនេយ្យភាពកាន់តែខ្លាំង ដើម្បីធានាថា ផែនការសកម្មភាពថ្នាក់តំបន់ ត្រូវបានប្រែក្លាយជាអត្ថប្រយោជន៍ជាក់ស្តែងសម្រាប់ស្ត្រី និងសហគមន៍ដែលងាយរងគ្រោះ។

*“របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ មានសារៈសំខាន់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ [ប៉ុន្តែ] ការជំរុញវឌ្ឍនភាព របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវការការចូលរួមច្រើនលើសពីការប្តេជ្ញាចិត្តក្នុងថ្នាក់តំបន់។ យើងត្រូវបង្កើតផែនការសកម្មភាពថ្នាក់ជាតិ ដើម្បីធានាថា ការប្តេជ្ញាចិត្តក្នុងតំបន់បានប្រែក្លាយជាសកម្មភាពជាក់ស្តែងនៅថ្នាក់ជាតិ និងនៅមូលដ្ឋាន។ ក្នុងនាមជាប្រទេសនាំមុខគេក្នុងការអភិវឌ្ឍផែនការសកម្មភាពតំបន់អាស៊ានស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និងក្នុងគំនិតផ្តួចផ្តើមធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនេះ កម្ពុជាប្តេជ្ញាចិត្តធ្វើឱ្យកិច្ចខំប្រឹងប្រែងថ្នាក់តំបន់នេះអាចក្លាយជាការពិតសម្រាប់ស្ត្រី និងក្មេងស្រីគ្រប់រូបនៅអាស៊ាន» លោកជំទាវកិត្តិ បណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារីនៃប្រទេសកម្ពុជា។*

# ២.២. តួនាទីនៃការតស៊ូមតិថ្នាក់សកល និងតំបន់

## ថ្នាក់សកល

ការតស៊ូមតិថ្នាក់សកលបានដើរតួយ៉ាងសំខាន់សម្រាប់ការរៀបចំក្របខ័ណ្ឌរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងថ្នាក់តំបន់ ដោយបានផ្តល់ជាកម្លាំងចលករសម្រាប់ការធ្វើមូលដ្ឋានីយកម្ម និងប្រតិបត្តិការប្តេជ្ញាចិត្តអន្តរជាតិ និងសេចក្តីសម្រេចផ្សេងៗ។

សកម្មភាពទាំងនេះ ដឹកនាំដោយក្រុមចម្រុះ ដូចជា បណ្តាញសកលនៃស្ត្រីអ្នកកសាងសន្តិភាព (GNWP) សម្ព័ន្ធស្ត្រីសម្រាប់ភាពជាអ្នកដឹកនាំកិច្ចការសន្តិសុខ (WASL) និង សម្ព័ន្ធអន្តរជាតិស្ត្រីដើម្បីសន្តិភាពនិងសេរីភាព (WILPF)។ ចលនាទាំងនេះបង្កើតវេទិកាសម្រាប់ការផ្លាស់ប្តូរគំនិត ពង្រីកសំឡេងរបស់ស្ត្រី និងធ្វើឱ្យរដ្ឋមានការទទួលខុសត្រូវចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន។

ពួកគេក៏ឈានមុខចំពោះការតស៊ូមតិសម្រាប់ការពង្រីករបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ផងដែរ តាមរយៈសេចក្តីសម្រេចបន្ថែមរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងអនុសាសន៍ទូទៅ។ ឧទាហរណ៍ កិច្ចខិតខំប្រឹងប្រែងតស៊ូមតិបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអនុម័តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCRs) លេខ១៨២០ ១៨៨៨ និងលេខ១៩៦០ ដោយដោះស្រាយជម្លោះទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងអនុសាសន៍ទូទៅនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ទាំងឡាយនៃការរើសអើងប្រឆាំងនឹងស្ត្រី (អនុសញ្ញា ស៊ីដរ ឬ CEDAW) លេខ៣០ ដែលពង្រឹងការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដោយភ្ជាប់កាតព្វកិច្ចសិទ្ធិស្ត្រីក្រោមអនុសញ្ញាស៊ីដរ (CEDAW) ជាមួយនឹងក្របខ័ណ្ឌសន្តិភាព និងសន្តិសុខ។

ឧទាហរណ៍ សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលខាងក្រោមនៅខែតុលា ឆ្នាំ២០២៤ បានចោទសួរយ៉ាងខ្លាំងដល់មេដឹកនាំពិភពលោកដែលបរាជ័យក្នុងការដើរតាមការសន្យារបស់ខ្លួនក្នុងការរក្សាសន្តិភាព និងសន្តិសុខ ដោយអំពាវនាវឱ្យមានសកម្មភាពផ្លាស់ប្តូរ និងការទទួលខុសត្រូវ ដើម្បីផ្តល់អាទិភាពដល់យុត្តិធម៌ សមធម៌ និងដំណោះស្រាយជម្លោះដោយអហិង្សា៖

*«ក្នុងនាមជាអ្នកកសាងសន្តិភាពស្ត្រី និងសមាជិកនៃសហគមន៍របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ យើងបានបោះជំហានឈានទៅមុខ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសរបស់យើង ស្របពេលជាមួយនឹងការផ្តល់តម្លៃដល់ប្រព័ន្ធពហុភាគី និងយន្តការដោះស្រាយជម្លោះដោយអហិង្សា។*

*ប៉ុន្តែយើងមានការខកចិត្តនឹងការនិយាយផ្សេងធ្វើផ្សឹងរបស់រដ្ឋាភិបាលមួយចំនួន ដែលអះអាងថាជាជើងឯកសន្តិភាព ប៉ុន្តែបែរជាទទួលប្រាក់ចំណេញពីការលក់អាវុធដែលប្រើប្រាស់ក្នុងអំពើឃោរឃៅរាប់មិនអស់ទៅវិញ។ យើងខកចិត្តនឹងការមានស្តង់ដាពីរ ដែលអាចឱ្យរដ្ឋាភិបាលកាន់អំណាចបំភាន់ភ្នែកច្បាប់អន្តរជាតិ រំលោភបំពានបទដ្ឋាន និងមធ្យោបាយរួមរស់ដោយស្មើភាពគ្នារវាង ប្រជាជននិងរដ្ឋ។ យើងខកចិត្តនឹងការសន្យាខ្យល់ចំពោះសន្តិភាព យុត្តិធម៌ និងសមធម៌។*

*យើងអំពាវនាវឱ្យមេដឹកនាំពិភពលោក អង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកទទួលស្គាល់បរាជ័យនៃ “ការធ្វើតាមទម្លាប់”។ យើងត្រូវការការផ្លាស់ប្តូរបែបបទធ្វើការ ដែលដាក់សន្តិភាពជាគោលដៅនិងជាដំណើរការយុទ្ធសាស្ត្រផងដែរ។ អំពើហិង្សាមិនមែនមិនអាចបញ្ចៀសបានទេ។ ហិង្សាគឺជាជម្រើស និងយុទ្ធសាស្ត្រតែប៉ុណ្ណោះ។*

*ការដឹកនាំពិតប្រាកដដើម្បីសន្តិភាព និងការរួមរស់ដោយស្មើភាពគ្នា ទាមទារភាពក្លាហានក្នុងការសន្ទនា មិនមែនបាញ់ប្រហារនោះទេ។ នេះមិនមែនជារឿងស្រមើស្រមៃមិនអាចធ្វើបានោះទេ។ វាជាការងារលំបាកដែលអ្នកកសាងសន្តិភាពធ្វើរាល់ថ្ងៃ ហើយជាញឹកញាប់យកជីវិតទៅប្រថុយ»។*

ដកស្រង់ចេញពីសេចក្តីថ្លែងការណ៍រួមរបស់សម្ព័ន្ធស្ត្រីដើម្បីភាពជាអ្នកដឹកនាំសន្តិសុខ (WASL) «២៤ឆ្នាំក្រោយពីសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ UNSCR លេខ១៣២៥៖ ស្ត្រី សង្គ្រាម និងអសន្តិសុខ» [៥៤]។

ឧទាហរណ៍សំខាន់មួយទៀតនៃបណ្តាញតស៊ូមតិជាសកល គឺក្រុមការងារអង្គការក្រៅរដ្ឋាភិបាលធ្វើការលើរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដែលជាសម្ព័ន្ធនៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិឈានមុខគេ ដែលទាមទារឱ្យមានការអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងក្រុមប្រឹក្សាសន្តិសុខ។

ចំណុចសំខាន់នៃការងាររបស់ពួកគេ គឺការតស៊ូមតិនៅអង្គការសហប្រជាជាតិ ដែលអង្គការក្រៅរដ្ឋាភិបាលស្តីពីស្ត្រី (NGOWG) ជំរុញឱ្យមានការប្តេជ្ញាចិត្តកាន់តែខ្លាំង ចំពោះសមភាពយេនឌ័រក្នុងដំណើរការសន្តិភាព បេសកកម្មរក្សាសន្តិភាព និងការឆ្លើយតបជំនួយមនុស្សធម៌។ ក្រុមនេះចូលរួមដោយផ្ទាល់ជាមួយក្រុមប្រឹក្សាសន្តិសុខ ដោយផ្តល់អ្នកជំនាញក្នុងការវិភាគ និងការណែនាំអំពីគោលនយោបាយថា តើបញ្ហា របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ គួរដោះស្រាយដោយពិភាក្សាជាក់លាក់ក្នុងប្រទេស និងការពិភាក្សាដេញដោលតាមប្រធានបទរបៀបណា?

ក្រុមនេះរមែងដាក់ចេញនូវផែនការសកម្មភាពប្រចាំខែ (MAPs) ដោយផ្តល់ជំហានជាក់លាក់សម្រាប់អង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិក ដើម្បីពង្រឹងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាតិ (UNSCR) លេខ១៣២៥ និងសេចក្តីសម្រេច របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ បន្តបន្ទាប់ទៀត។ ប្រការនេះក៏ជួយសម្រួលដល់ការចូលរួមដោយផ្ទាល់របស់អ្នកកសាងសន្តិភាពស្ត្រីនៅក្នុងការពិភាក្សារបស់អង្គការសហប្រជាជាតិផងដែរ ដោយបង្កើតលំហសម្រាប់មេដឹកនាំសង្គមស៊ីវិលមកពីតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ ក្នុងការចែករំលែកបទពិសោធន៍របស់ពួកគេ និងតម្រង់ទិសការបង្កើតគោលនយោបាយថ្នាក់សកល។

### ថ្នាក់តំបន់៖

ការតស៊ូមតិក្នុងថ្នាក់តំបន់ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រែក្លាយការប្តេជ្ញាចិត្តរបស់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទៅជាសកម្មភាព ខណៈដែលធ្វើការដោះស្រាយបញ្ហាប្រឈម និងឱកាសជាក់លាក់ក្នុងតំបន់។

ចលនាទាំងនេះ ជារឿយៗផ្សាភ្ជាប់នូវគម្លាតរវាងការប្តេជ្ញាចិត្តជាសកល ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSCRs) និងការអនុវត្តនៅថ្នាក់ជាតិ ការបង្កើតវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍគោលនយោបាយ និងការទទួលខុសត្រូវ។ នៅទូទាំងពិភពលោក ចលនាទាំងនេះបានរួមចំណែកដល់ការកំណត់ក្របខ័ណ្ឌ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ និងជំរុញឱ្យមានការផ្លាស់ប្តូរ។

នៅអាហ្វ្រិក បណ្តាញជាច្រើន ដូចជា Femmes Africa Solidarité (FAS) បានលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីក្នុងដំណើរការសន្តិភាព និងការដោះស្រាយជម្លោះ។ តាមរយៈការតស៊ូមតិ និងការចូលរួមជាមួយស្ថាប័នអន្តរជាតិ (FAS) បានឈ្នះពានលើការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UN-SCR) លេខ ១៣២៥ និងសេចក្តីសម្រេចក្រោយៗមកទៀតនៅទូទាំងទ្វីប ជាពិសេសការលើកកម្ពស់ការចូលរួមរបស់ស្ត្រីកាន់តែច្រើននៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព។

នៅអាមេរិកឡាទីន គណៈកម្មាធិការតំបន់អាមេរិកឡាទីននិងការ៉ាប៊ីនសម្រាប់ការការពារសិទ្ធិស្ត្រី (CLADEM) បានបង្រួបបង្រួមអង្គការសិទ្ធិស្ត្រីនៅទូទាំងតំបន់ ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងបរិបទសន្តិភាព និងសន្តិសុខ។ ការតស៊ូមតិរបស់គណៈកម្មាធិការតំបន់អាមេរិកឡាទីន និងការ៉ាប៊ីនសម្រាប់ការការពារសិទ្ធិស្ត្រី (CLADEM) ផ្តោតលើការលើកស្ទួយយន្តការយុត្តិធម៌អន្តរកាល ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាយេនឌ័រ និងការពង្រឹងលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងសិទ្ធិស្ត្រី។

នៅតំបន់ប៉ាស៊ីហ្វិក សម្ព័ន្ធហ្វេមីនីស្ត ដូចជាបណ្តាញស្ត្រីអ្នកសម្រុះសម្រួលស្ត្រីតំបន់ប៉ាស៊ីហ្វិក (PWMN) បានផ្តល់អាទិភាពលើគំនិតផ្តួចផ្តើមក្នុងការជំរុញការកសាងសន្តិភាពសហគមន៍ ធ្វើយ៉ាងណាឱ្យសំឡេងរបស់ស្ត្រីក្លាយជាចំណុចចម្បងនៃការសម្រុះសម្រួល និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ជម្លោះ។

## តំបន់អាស៊ាន៖

ចលនាតស៊ូមតិក្នុងតំបន់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ចូលរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។ ខណៈដែលគំនិតផ្តួចផ្តើមដឹកនាំដោយរដ្ឋជាសមាជិកដែលជារឿយៗផ្តោតលើការប្តេជ្ញាចិត្តកម្រិតគោលនយោបាយ បណ្តាញតស៊ូមតិស្ត្រី សម្ព័ន្ធ និងយុទ្ធនាការមូលដ្ឋានធ្វើការដើម្បីធានាថា ការប្តេជ្ញាចិត្តទាំងនេះប្រែក្លាយទៅជាសកម្មភាពជាក់ស្តែងប្រកបដោយអត្ថន័យ។

ឧទាហរណ៍សំខាន់មួយ គឺកិច្ចប្រជុំស្ត្រីអាស៊ីអាគ្នេយ៍ស្តីពីអាស៊ាន (ស្គាល់ជាទូទៅថាជា Women's Caucus) ដែលឈានមុខគេក្នុងការតស៊ូមតិសម្រាប់ការបង្កើតគោលនយោបាយដែលគិតគូរពីយេនឌ័រក្នុងថ្នាក់តំបន់។ កិច្ចប្រជុំនេះបានអំពាវនាវជាបន្តបន្ទាប់ដើម្បីពង្រឹងយន្តការគណនេយ្យភាពឱ្យកាន់តែមានភាពរឹងមាំក្នុងតំបន់អាស៊ាន ដើម្បីធានាថាគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ បានប្រតិបត្តិនៅទូទាំងរដ្ឋជាសមាជិក។ កិច្ចខិតខំប្រឹងប្រែងរួមទាំងការពិគ្រោះយោបល់ថ្នាក់តំបន់ ការសង្ខេបគោលនយោបាយ និងការចូលរួមជាយុទ្ធសាស្ត្រជាមួយអ្នកបង្កើតគោលនយោបាយ បានជំរុញឱ្យមើលឃើញពីបញ្ហា ដូចជាអំពើហិង្សាយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការស្តារឡើងវិញក្រោយជម្លោះ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ[៩៥]។

ដូចគ្នានេះដែរ សម្ព័ន្ធហ្វេមីនីស្ត ដូចជា វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពី ស្ត្រី ច្បាប់ និងការអភិវឌ្ឍ (APWLD) បានប្រើប្រាស់វេទិកាថ្នាក់តំបន់ ដើម្បីទាមទារឱ្យមានកំណែទម្រង់ផ្នែករចនាសម្ព័ន្ធ។ ការតស៊ូមតិរបស់ APWLD បង្ហាញពីទំនាក់ទំនងគ្នាទៅវិញទៅមកនៃសេដ្ឋកិច្ចសង្គម និងសិទ្ធិនយោបាយរបស់ស្ត្រី ក៏ដូចជា យុត្តិធម៌អាកាសធាតុ ក្នុងការសម្រេចបាននូវសន្តិភាពប្រកបដោយនិរន្តរភាព [៩៦]។

យ៉ាងណាមិញ ចលនាទាំងនេះប្រឈមមុខនឹងបញ្ហាចម្បងៗ។ បរិយាកាសតំបន់សម្រាប់ការចូលរួមរបស់សង្គមស៊ីវិល ដូចជាវេទិកាតំបន់អាស៊ាន នៅតែមានកម្រិតត្រឹមរចនាសម្ព័ន្ធរដ្ឋ ដែលធ្វើឱ្យបាត់សំឡេងចម្រុះផ្សេងទៀត។ លើសពីនេះទៀត ការកើនឡើងនៃការគ្រប់គ្រងបែបផ្តាច់ការនៅទូទាំងរដ្ឋជាសមាជិកមួយចំនួន បានកាត់បន្ថយការរៀបចំ និងការតស៊ូមតិរៀបចំដោយស្ត្រី ធ្វើឱ្យមានការរួមតូចលំហស៊ីវិលសម្រាប់ការងារដែលទាក់ទងនឹងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ [៩៧]។

ទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ ក៏ចលនាហ្វេមីនីស្តក្នុងតំបន់នៅតែបន្តសម្របខ្លួននិងបង្កើតគំនិតថ្មីៗ។ យុទ្ធនាការតស៊ូមតិតាមប្រព័ន្ធឌីជីថល កិច្ចខិតខំប្រឹងប្រែងសាមគ្គីភាពឆ្លងប្រទេស និងភាពជាដៃគូជាមួយបណ្តាញស្ត្រីអន្តរជាតិ បានផ្តល់មធ្យោបាយថ្មីសម្រាប់ការផ្លាស់ប្តូរ។

**គន្លឹះសម្រាប់ពិចារណា៖**

**នៅទូទាំងពិភពលោក ៦៤%នៃកិច្ចព្រមព្រៀងសន្តិភាពទំនងជាមិនបរាជ័យទេនៅពេលដែលមានការចូលរួមពីតំណាងសង្គមស៊ីវិល![៩៨]**

# ២.៣. បញ្ហាប្រឈម និងឱកាស ក្នុងថ្នាក់តំបន់

ការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅអាស៊ីអាគ្នេយ៍បង្ហាញពីបញ្ហាប្រឈមចម្បងៗ ព្រមទាំងឱកាស។ ភាពចម្រុះផ្នែកនយោបាយ វប្បធម៌ និងសេដ្ឋកិច្ចសង្គម ក្នុងតំបន់កំណត់ពីរបៀបដែលគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ត្រូវបានបកស្រាយ និងអនុវត្ត។ ខណៈដែលក្របខ័ណ្ឌថ្នាក់តំបន់ ដូចជាផែនការសកម្មភាពតំបន់របស់អាស៊ានស្តីពី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ចែងពីមូលដ្ឋានគ្រឹះក្នុងការប្រែក្លាយការប្តេជ្ញាចិត្តទាំងនេះទៅជាលទ្ធផលជាក់ស្តែង បានបង្ហាញអោយឃើញពីបញ្ហាប្រឈមមួយចំនួន។

## បញ្ហាប្រឈម៖

បញ្ហាប្រឈមចម្បងមួយ គឺភាពខុសគ្នានៃអាទិភាពនយោបាយក្នុងចំណោមរដ្ឋជាសមាជិក ជាពិសេសតំបន់អាស៊ីអាគ្នេយ៍ គឺជាជម្រកនៃវិសាលភាពដ៏ធំទូលាយនៃប្រព័ន្ធនយោបាយ។

ភាពខុសគ្នានេះ អាចនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នាក្នុងការអនុម័តគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។ ឧទាហរណ៍ ស្របពេលដែលរដ្ឋមួយចំនួនបានអភិវឌ្ឍយ៉ាងរឹងមាំនូវផែនការសកម្មភាពថ្នាក់ជាតិ ដែលរួមបញ្ចូលការប្តេជ្ញាចិត្តក្នុងការអនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ រដ្ឋខ្លះទៀតបែរជាខ្វះខាតសូម្បីតែក្របខ័ណ្ឌគោលនយោបាយជាមូលដ្ឋាន ដែលត្រូវដោះស្រាយបញ្ហាប្រឈមស្តីពីសន្តិភាព និងសន្តិសុខ ដែលទាក់ទងនឹងកត្តាយេនឌ័រ។

បញ្ហាប្រឈមចម្បងមួយទៀត គឺ យន្តការគណនេយ្យភាពក្នុងក្របខ័ណ្ឌថ្នាក់តំបន់នៅមានកម្រិត។ ទោះបីជាអាស៊ានបានបោះជំហានក្នុងការបញ្ចូលគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក៏ដោយ សមត្ថភាពក្នុងការអនុវត្តរបស់រដ្ឋនៅមានកម្រិតនៅឡើយ។

ប្រការនេះច្រើនតែបណ្តាលឱ្យមានគម្លាតរវាងការ ប្តេជ្ញាចិត្តថ្នាក់គោលនយោបាយ និងការអនុវត្តជាក់ស្តែងនៅថ្នាក់មូលដ្ឋាន ដែលមិនបានរួមបញ្ចូលស្ត្រីនិងក្មេងស្រី ជាពិសេស ក្រុមដែលមកពីអត្តសញ្ញាណចម្រុះក្នុងដំណើរការកសាងសន្តិភាព។

ការរួមតូចលំហសង្គមស៊ីវិលនៅក្នុងតំបន់ធ្វើឱ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរឡើង។ អង្គការសង្គមស៊ីវិល ជាពិសេសក្រុមហ្វេមីនីស្តប្រឈមនឹងការកើនឡើងនៃការរឹតបន្តឹងលើសកម្មភាពរបស់ពួកគេ [៥៩]។ សកម្មភាពចាប់ពិរុទ្ធ និងការប្រើប្រាស់ប្រព័ន្ធច្បាប់បានរារាំងការចូលរួមរបស់សកម្មជនសិទ្ធិស្ត្រីក្នុងការតស៊ូមតិលើការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ។ នេះជាក្តីបារម្ភជាពិសេសដោយសារ តួនាទីសំខាន់របស់អង្គការមូលដ្ឋានក្នុងការឃ្លាំមើលគណនេយ្យភាពរបស់រដ្ឋាភិបាល និងជំរុញកំណែទម្រង់ដែលគិតគូរពីយេនឌ័រ។

បទដ្ឋានវប្បធម៌ និងសង្គមក៏បង្កជាឧបសគ្គផងដែរ។ ឥរិយាបទបែបបិតាធិប្បតេយ្យ និងផ្នត់គំនិតយេនឌ័រនៅតែមានទូទាំងថ្នាក់តំបន់ ដែលបានកម្រិតការចូលរួមរបស់ស្ត្រីក្នុងដំណើរការនៃការសម្រេចចិត្ត។

នៅក្នុងបរិបទខ្លះ ស្ត្រីនៅតែត្រូវចាត់ទុកជាជនរងគ្រោះដោយសារជម្លោះ ច្រើនជាងជាភ្នាក់ងារសកម្មនៃការផ្លាស់ប្តូរ ដែលធ្វើឱ្យប៉ះពាល់ដល់សក្តានុពលនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។

# ឱកាសៈ

ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ អាស៊ីអាគ្នេយ៍ក៏ផ្តល់នូវឱកាសសំខាន់ៗសម្រាប់វឌ្ឍនភាពនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ផងដែរ។ ប្រវត្តិដ៏សម្បូរបែបក្នុងតំបន់ នៃការកសាងសន្តិភាពដែលដឹកនាំដោយស្ត្រីផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់ការតស៊ូមតិ។ ឧទាហរណ៍ នៅប្រទេសហ្វីលីពីន ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រុះសម្រួលកិច្ចព្រមព្រៀងសន្តិភាពនិងការកសាងសហគមន៍ឡើងវិញនៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ ដូចជានៅកោះមីនដាណាវ [៦០]។ ជោគជ័យទាំងនេះបង្ហាញពីសារៈសំខាន់នៃការប្រើប្រាស់ជំនាញក្នុងស្រុក ដើម្បីផ្តល់ការតម្រង់ទិសដល់យុទ្ធសាស្ត្រថ្នាក់តំបន់។

ក្របខ័ណ្ឌថ្នាក់តំបន់ ដូចជាផែនការសកម្មភាពតំបន់អាស៊ាន ស្តីពី របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ជាវេទិកាសម្រាប់ការសហការនិងការកំណត់ស្តង់ដា។

ក្របខ័ណ្ឌទាំងនេះផ្តល់នូវភាសារួម និងការកំណត់គោលដៅ ដែលរដ្ឋជាសមាជិកអាចសម្របខ្លួនទៅនឹងបរិបទជាតិរបស់ពួកគេ។

ការពង្រឹងសមត្ថភាពរបស់អាស៊ានក្នុងការតាមដាននិងវាយតម្លៃការអនុវត្ត របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ អាចជួយផ្សាភ្ជាប់គម្លាតរវាងការប្តេជ្ញាចិត្តថ្នាក់តំបន់ និងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន។

ការកើនឡើងនៃការយកចិត្តទុកដាក់លើអន្តរប្រសព្វនិងបរិយាប័ន្ននៅក្នុងការតស៊ូមតិថ្នាក់តំបន់ ក៏ផ្តល់ជាឱកាសមួយផងដែរ។ ស្ថាប័នផ្សេងៗចាប់ផ្តើមទទួលស្គាល់ពីតម្រូវការក្នុងការដោះស្រាយទម្រង់ ប្រសព្វគ្នានៃអត្តសញ្ញាណចម្រុះ ដូចជាជាតិសាសន៍ ពិការភាព ឬ និន្នាការភេទជាដើម ដែលប្រទាក់ក្រឡាគ្នាបង្កើតបានជាបទពិសោធន៍នៃការទទួលរងការគាបសង្កត់ ឬភាពងាយរងគ្រោះខុសៗគ្នា។

ការផ្លាស់ប្តូរនេះ បង្កើតឱ្យមានលំហនិងវិធីសាស្ត្របែបបរិយាបន្នក្នុងការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដែលឆ្លុះបញ្ចាំងពីភាពចម្រុះក្នុងសង្គម ។

កម្មវិធីបច្ចេកវិទ្យា និងវេទិកាឌីជីថលផ្តល់មធ្យោបាយមួយទៀតសម្រាប់វឌ្ឍនភាព។ យុទ្ធនាការតស៊ូមតិតាមប្រព័ន្ធឌីជីថល និងតាមបណ្តាញអ៊ីនធឺណិត បានធ្វើឱ្យអង្គការហ្វេមីនីស្តចៀសផុតពីឧបសគ្គជាប្រពៃណី ក្នុងការចូលរួម និងចែកចាយព័ត៌មានព្រមទាំងអាចកៀរគរការគាំទ្រកាន់តែទូលំទូលាយ។ ឧទាហរណ៍ ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ១៩ អង្គការក្នុងតំបន់បានប្រើឧបករណ៍ឌីជីថលដើម្បីធានាថាសំឡេងស្ត្រីបានត្រូវបានដាក់បញ្ចូលក្នុងផែនការឆ្លើយតបគ្រោះមហន្តរាយ។

ជាចុងក្រោយ ការកើនឡើងនូវការគាំទ្រជាអន្តរជាតិសម្រាប់គំនិតផ្តួចផ្តើម របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនៅអាស៊ីអាគ្នេយ៍។ ភាពជាដៃគូជាមួយតួអង្គសកលដូចជា UN Women និងបណ្តាញអង្គការហ្វេមីនីស្តថ្នាក់តំបន់ បានផ្តល់ធនធានជំនាញ និងឱកាសជាច្រើនដែលត្រូវការសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងតំបន់។

វេទិកាស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខអាស៊ាន ដែលបង្កើតឡើងដើម្បីជំរុញរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅថ្នាក់តំបន់ គឺជាទីស្នាក់ការកណ្តាលនៃការចែករំលែកចំណេះដឹង ការអនុវត្តស្របតាមគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពក្នុងចំណោមរដ្ឋជាសមាជិក និងអ្នកពាក់ព័ន្ធ។

ភាពជាដៃគូទាំងនេះអាចជួយរក្សាសន្ទុះ និងធានាថាបញ្ហាប្រឈមក្នុងតំបន់ត្រូវបានឆ្លើយតបដោយមានការសម្របសម្រួល និងពីច្រើនភាគីពាក់ព័ន្ធ។

**អាស៊ីអាគ្នេយ៍មានសក្តានុពលធ្វើជាអ្នកដឹកនាំពិភពលោកក្នុងប្រតិបត្តិការរបៀបវារៈ ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ។ ទោះជាយ៉ាងណាក៏ដោយ ឆន្ទៈនយោបាយប្រកបដោយចីរភាពការពង្រឹងយន្តការគណនេយ្យភាពនិងការប្តេជ្ញាចិត្តក្នុងការការពារលំហពលរដ្ឋមានសារៈសំខាន់ក្នុងការសម្រេចបាននូវចក្ខុវិស័យនេះ។**

# ការអនុវត្តល្អៗ៖ ករណីសិក្សាក្នុងថ្នាក់តំបន់

## ផែនការសកម្មភាពជាតិស្តីពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ លើកទី៤ នៅប្រទេសហ្វីលីពីន

ផែនការសកម្មភាពជាតិរបស់ប្រទេសហ្វីលីពីនស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAPWPS) ឆ្នាំ២០២៣-២០៣៣ បានបង្ហាញឧទាហរណ៍អំពីវិធីសាស្ត្រដ៏រឹងមាំ និងប្រកបដោយបរិយាបន្នក្នុងការជំរុញរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ។ ក្នុងនាមជាប្រទេសអាស៊ីអាគ្នេយ៍ដំបូងគេ ដែលបានអនុម័ត ផែនការជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ក្នុងឆ្នាំ២០១០ ប្រទេសហ្វីលីពីនបានបង្ហាញពីការប្តេជ្ញាចិត្តចំពោះការងារនេះ។ ការរៀបចំផែនការសកម្មភាពជាតិលើកទី៤នេះ បានបន្តកេរ្តិ៍ដំណែលដ៏ល្អនេះ ដោយបញ្ចូលមេរៀនដែលទទួលបាន និងការដោះស្រាយចន្លោះប្រហោង ដែលបានកំណត់នៅក្នុងផែនការមុនៗ [៦១]។

លក្ខណៈកំណត់នៃវិធីសាស្ត្ររបស់ប្រទេសហ្វីលីពីន គឺការចូលរួមយ៉ាងទូលំទូលាយរបស់អង្គការសង្គមស៊ីវិល ដូចជា WE Act 1325 និងក្រុមតស៊ូមតិសិទ្ធិស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដ៏ទៃទៀត។ សម្រាប់ផែនការសកម្មភាពជាតិឆ្នាំ២០២៣-២០៣៣ ការពិគ្រោះយោបល់មានរួមបញ្ចូលស្ត្រីនៅមូលដ្ឋាន អង្គការហ្វេមីនីស្ត ក្រុមជនជាតិដើម និងអ្នកតស៊ូមតិ LGBTQIA+ ដោយធានានូវការឆ្លើយតបរបស់ផែនការទៅនឹងទស្សនៈទាននិងតម្រូវចម្រុះ និងភាពងាយរងគ្រោះ។ អង្គការសង្គមស៊ីវិលបានរួមចំណែកក្នុងរបៀបវារៈ១១ចំណុច ដោយផ្តោតលើកិច្ចការពារជម្លោះ ភាពជាតំណាង និងការកសាងសមត្ថភាពសម្រាប់ស្ត្រីនៅក្នុងថ្នាក់តំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ។

ផែនការសកម្មភាពជាតិរបស់ប្រទេសហ្វីលីពីនស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (NAPWPS) ឆ្នាំ២០២៣-២០៣៣ រួមបញ្ចូលនូវមុខងារពិសេសៗជាច្រើន។ ឧទាហរណ៍ ការរួមបញ្ចូលយ៉ាងច្បាស់នូវបញ្ហា ដែលកំពុងកើតមានដូចជា៖

- **សន្តិភាពឌីជីថល និងសន្តិសុខតាមអ៊ីនធឺណិត**
- **សន្តិសុខអាកាសធាតុ និង**
- **ផលប៉ះពាល់យេនឌ័រនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។**

ផែនការនេះក៏មានអនុវត្តប្រព័ន្ធតាមដាន ការវាយតម្លៃ គណនេយ្យភាព និងការសិក្សា (MEAL) ដើម្បីធានាបាននូវការតាមដានគ្រប់ជ្រុងជ្រោយនៃវឌ្ឍនភាព និងការប្រមូលទិន្នន័យបែបអន្តរប្រសព្វ។ នេះគឺជាការផ្លាស់ប្តូរដ៏សំខាន់មួយដើម្បីដោះស្រាយនូវការរិះគន់កន្លងមក រួមទាំងកង្វះនៃក្របខ័ណ្ឌត្រួតពិនិត្យដ៏រឹងមាំ និងការយល់ដឹងជាសាធារណៈនៅមានកម្រិតនៃគំនិតផ្តួចផ្តើមរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។

ទោះបីជាមានការរីកចម្រើនទាំងនេះក៏ដោយ ក៏បញ្ហាប្រឈមនៅតែមាន។ ការអនុវត្តមិនស្រុះគ្នាទូទាំងភ្នាក់ងាររដ្ឋាភិបាល ទិន្នន័យអន្តរប្រសព្វមិនពេញលេញ និងការខិតខំប្រឹងប្រែងធ្វើមូលដ្ឋានីយកម្មនៅមានកម្រិត នៅក្នុងតំបន់កោះមីនដាណាវ ត្រូវបានកំណត់ថា ជាឧបសគ្គក្នុងការសម្រេចបានពេញលេញនូវគោលដៅរបស់ ផែនការសកម្មភាពជាតិស្តីពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ។ ការអនុវត្តមិនទាន់បានពេញលេញនៃផែនការនិងថវិកាយេនឌ័រនិងការអភិវឌ្ឍន៍ (GAD) ធ្វើឱ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរ។

ទោះជាយ៉ាងណាក៏ដោយ ផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ឆ្នាំ២០២៣-២០៣៣ មានគោលបំណងដោះស្រាយចន្លោះប្រហោងទាំងនេះ តាមរយៈយុទ្ធសាស្ត្រជាគោលដៅ ដូចជាការពង្រឹងកិច្ចសហការរបស់អង្គការសង្គមស៊ីវិល ជាមួយរដ្ឋាភិបាល និងការរួមបញ្ចូល របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចកាន់តែទូលំទូលាយ។



# ជំពូកទី
# មូលដ្ឋានីយកម្មនៅថ្នាក់ប្រទេស

## ៣.១ សារៈសំខាន់នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅប្រទេសកម្ពុជា

ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងពីជម្លោះរ៉ាំរ៉ៃ និងភាពធន់របស់ខ្លួន។

របបខ្មែរក្រហម (១៩៧៥–១៩៧៩) និងផលវិបាករបស់របបនេះ បានបន្សល់ទុកនូវកេរ្តិ៍ដំណែលនៃអំពើហិង្សាទ្រង់ទ្រាយធំ អំពើប្រល័យពូជសាសន៍ ការជម្លៀសដោយបង្ខំ និងការរំលោភសិទ្ធមនុស្សជាប្រព័ន្ធ។ ស្ត្រីជាច្រើន រួមទាំងស្ត្រីជនជាតិភាគតិច និងជនជាតិដើមភាគតិចរងផលប៉ះពាល់ដោយអំពើហិង្សាផ្លូវភេទ ពលកម្មដោយបង្ខំ ការជម្លៀស និងការបែកបាក់គ្រួសារ។

ជាការពិតណាស់ ជាង ៦០% នៃអ្នករស់រានមានជីវិតពីរបបនេះគឺជា ស្ត្រី ដែលបានចូលរួមកសាងប្រទេសឡើងវិញពីការបំផ្លិចបំផ្លាញទាំងស្រុង ប៉ុន្តែពួកគេមិនត្រូវបានទទួលស្គាល់ក្នុងដំណើរស្វែងរកសន្តិភាពផ្លូវការនោះទេ ៦២។ បញ្ហាប្រឈមនៃប្រវត្តិសាសទាំងនេះ បានផ្តល់ផលប៉ះពាល់ជាយូរង្វែងពីមួយជំនាន់ទៅមួយជំនាន់ ជាពិសេសដល់ស្ត្រី និងក្រុមងាយរងគ្រោះ។ ការណ៍នេះ ទាមទារឱ្យមានវិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រក្នុងការកសាងសន្តិភាព ការផ្តល់ជំនួយមនុស្សធម៌ និងដំណើរការអភិវឌ្ឍន៍។

ទោះបីជាភ្លើងសង្គ្រាមត្រូវបានបញ្ចប់នៅប្រទេសកម្ពុជា ក៏របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នៅតែជាក្របខណ្ឌយ៉ាងសំខាន់សម្រាប់ការជំរុញឱ្យមានសន្តិភាព និងសន្តិសុខប្រកបដោយបរិយាបន្ន។ ជំពូកនេះនឹងពិភាក្សាអំពីសារៈសំខាន់របស់របៀបវារៈនេះនៅកម្ពុជា សក្តានុពលរបស់វាក្នុងការដោះស្រាយវិសមភាពជារចនាសម្ព័ន្ធ និងតួនាទីក្នុងការផ្តល់ភាពអង់អាចដល់សហគមន៍ងាយរងគ្រោះ។

*ការដែលធានាថាចំនួនស្ត្រីមិនត្រឹមតែត្រូវបានរាប់បញ្ចូលប៉ុណ្ណោះទេ ប៉ុន្តែវាជាកត្តាសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព គឺមិនត្រឹមតែជាបញ្ហានៃយុត្តិធម៌ទេ ប៉ុន្តែគឺជាលក្ខខណ្ឌបឋមជាចម្បងមួយសម្រាប់កសាងសន្តិភាពប្រកបដោយចីរភាពផងដែរ។*

# ៣.១.១. ស្ត្រី សន្តិភាព និងយុត្តិធម៌អន្តរកាល

សន្ធិសញ្ញាក្រុងប៉ារីស ឆ្នាំ១៩៩១ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលបានបញ្ចប់ជម្លោះរ៉ាំរ៉ៃ និងជាមូលដ្ឋានគ្រឹះសម្រាប់ការកសាងសន្តិភាពនិងការកសាងប្រទេសឡើងវិញ [៦៣]។

ខណៈដែលកិច្ចព្រមព្រៀងនេះបានបង្កើតជាយន្តការសម្រាប់ការផ្ទេរអំណាចនយោបាយនិងជាមូលដ្ឋានសម្រាប់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ វាក៏ជានិមិត្តរូបនៃនិន្នាការអន្តរជាតិ ដែលជារឿយៗមិនរាប់បញ្ចូលស្ត្រីក្នុងការចរចាសន្តិភាពបែបផ្លូវការនាពេលនោះ។

ទោះបីជាមានសមិទ្ធិផលសំខាន់ៗរបស់កិច្ចព្រមព្រៀងក៏ដោយ ក៏ការចូលរួមរបស់ស្ត្រីនៅមានកម្រិត លើកលែងករណីលោកស្រី ពុង ឈីវកេក ដែលបានដើរតួយ៉ាងសំខាន់ក្នុងការរៀបចំឱ្យមានកិច្ចជំនួបចរចារវាងភាគីជម្លោះពាក់ព័ន្ធ និងបានលេចឡើងក្លាយជាអ្នកតស៊ូមតិដ៏សំខាន់មួយដើម្បីសិទ្ធិមនុស្សនិងយុត្តិធម៌។ តួនាទីរបស់គាត់បង្ហាញពីសក្តានុពលនៃភាពជាអ្នកដឹកនាំស្ត្រី ក្នុងពេលដែលសំឡេងរបស់ស្ត្រីជារឿយៗមិនមានឱកាសបញ្ចេញ [៦៤]។

ដំណើរការនៃយុត្តិធម៌អន្តរកាល ជាពិសេសតាមរយៈការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅខ្លីថា សាលាក្តីខ្មែរក្រហម ឬ ECCC) បានផ្តល់សារៈសំខាន់មួយ ទោះបីជាមិនពេញលេញគ្រប់ជ្រុងជ្រោយ ប៉ុន្តែតុលាការនេះជាវេទិកាដ៏សំខាន់មួយក្នុងការដោះស្រាយសោកនាដកម្មកាលពីអតីតកាលនោះ។

អាណត្តិរបស់សាលាក្តីខ្មែរក្រហម រួមបញ្ចូលការកាត់ទោសអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ចំពោះឧក្រិដ្ឋកម្មដែលបំផ្លិចបំផ្លាញប្រទេស សម្លាប់រង្គាល និងបង្កផលប៉ះពាល់ដល់ប្រជាជនគ្រប់រូប រួមទាំង ស្ត្រី និងជនងាយរងគ្រោះដទៃទៀត យ៉ាងធ្ងន់ធ្ងរ។

អំពើហិង្សាលើយេនឌ័រ រួមទាំងការបង្ខំរៀបការ និងអំពើហិង្សាផ្លូវភេទយ៉ាងឃោរឃៅ ត្រូវបានលើកឡើងក្នុងចំណោមឧក្រិដ្ឋកម្មនានា បើទោះបីជាបញ្ហានេះមិនត្រូវបានស៊ើបអង្កេតឱ្យបានល្អិតល្អន់នៅដំណាក់កាលដំបូងនៃដំណើរការក្តីក៏ដោយ។

ការដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មជនរងគ្រោះ ដែលភាគច្រើនពួកគេជាស្ត្រីបានបន្ថែមទំហំនៃការងារតុលាការយ៉ាងសំខាន់ ក្នុងការពង្រីកការកត់ត្រាបទពិសោធន៍របស់អ្នករងគ្រោះ និងគូសបញ្ជាក់ពីភាពចាំបាច់នៃការរួមបញ្ចូលទស្សនៈយេនឌ័រទៅក្នុងដំណើរការយុត្តិធម៌អន្តរកាល។

ដំណើរការនេះ ក៏បានរំលេចឡើងនូវចំណុចខ្វះខាតផងដែរ។ ខណៈដែលសាលាក្តីខ្មែរក្រហម បានបោះជំហានទៅមុខក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ ផ្តោតសំខាន់លើការកាត់ទោសមេដឹកនាំខ្មែរក្រហមថ្នាក់លើដែលទទួលខុសត្រូវខ្ពស់បំផុត តែបានបន្សល់ទុកជនរងគ្រោះជាច្រើនដែលទទួលរងបទឧក្រិដ្ឋផ្សេងទៀតនៅថ្នាក់ក្រោម ដោយមិនបានទទួលការគាំទ្រឡើយ។

វិសាលភាពមានកំណត់នេះ បានបង្ហាញពីបញ្ហាប្រឈមធំមួយក្នុងការធានាថា យន្តការយុត្តិធម៌អន្តរកាលប្រកបដោយការរួមបញ្ចូល និងការឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ដែលរងផលប៉ះពាល់ទាំងអស់ ជាពិសេសស្ត្រី ដែលបន្តប្រឈមមុខនឹងឧបសគ្គជាប្រព័ន្ធនិងផ្នែករប្បធម៌ក្នុងការចូលរួម។

លើសពីយន្តការបែបផ្លូវការ កិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅកម្ពុជា បានជំរុញឱ្យមានគំនិតផ្តួចផ្តើមសំខាន់ៗនៅមូលដ្ឋានជាច្រើន។ អង្គការសង្គមស៊ីវិល ដែលជារឿយៗដឹកនាំដោយស្ត្រី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចងក្រងឯកសារប្រវត្តិសាស្ត្រ រក្សាការចងចាំ និងលើកទឹកចិត្តដល់កិច្ចសន្ទនាអន្តរជំនាន់។

គម្រោងជាច្រើនដូចជាកម្មវិធីសិល្បៈបែបចូលរួម និងការអប់រំដឹកនាំដោយសហគមន៍ អំពីប្រវត្តិសាស្ត្រខ្មែរក្រហម បានបង្កើតជាវេទិកាឲ្យមានការសះជា និងការឆ្លុះបញ្ចាំងដែលបានបំពេញភាពខ្វះខាតនៃដំណើរការតុលាការនេះ។ ប្រវត្តិសាស្ត្រដ៏ស្មុគស្មាញរបស់កម្ពុជាបានបង្ហាញពីសារៈសំខាន់យ៉ាងខ្លាំងនៃការរួមបញ្ចូលស្ត្រីក្នុងដំណើរការកសាងសន្តិភាព ដែលយ៉ាងហោចណាស់ត្រូវមានចំនួន ៣០% ក្នុងតួនាទីនៃការសម្រេចចិត្ត ។

ការដែលធានាថាចំនួនស្ត្រីមិនត្រឹមតែត្រូវបានរាប់បញ្ចូលប៉ុណ្ណោះទេ ប៉ុន្តែវាជាកត្តាសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាព គឺមិនត្រឹមតែជាបញ្ហានៃយុត្តិធម៌ទេ ប៉ុន្តែគឺជាលក្ខខណ្ឌបឋមជាចម្បងមួយសម្រាប់កសាងសន្តិភាពប្រកបដោយចីរភាពផងដែរ។

# ៣.១.២. ភាពជាអ្នកដឹកនាំរបស់កម្ពុជាក្នុងកិច្ចការងាររក្សាសន្តិភាពសកល

ចាប់តាំងពីឆ្នាំ ២០០៦ កម្ពុជាបានក្លាយជាអ្នកចូលរួមសកម្មយ៉ាងខ្លាំងក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដោយបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពចំនួនជាង ៩,១៩៧ នាក់ ដែលក្នុងនោះមានស្ត្រី ៨% ទៅកាន់បេសកកម្មចំនួន ១១ នៅតំបន់ជម្លោះជាសកល រួមមាន ប្រទេសស៊ូដង់ខាងត្បូង លីបង់ ម៉ាលី និងសាធារណរដ្ឋអាហ្វ្រិកកណ្តាល ៦៥។ ត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២៥ កម្ពុជាបានបញ្ជូនបុគ្គលិកឯកសណ្ឋានចំនួនច្រើនទៅកាន់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដែលធ្វើឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី ៣ ក្នុងចំណោមសមាជិកអាស៊ាន និងទី ២៨ (ក្នុងចំណោម ១២៣ ប្រទេស) ក្នុងសកល ៦៦។ រដ្ឋាភិបាលកម្ពុជាក៏មានគោលដៅបង្កើនភាគរយនៃស្ត្រីកងទ័ពមួកខៀវចូលរួមក្នុងបេសកកម្មរក្សាសន្តិភាព ឲ្យដល់ ២០% ក្នុងឆ្នាំ ២០២៤ ៦៧។ ការខិតខំប្រឹងប្រែងកំពុងបន្តដើម្បីជំរុញឱ្យចំនួនស្ត្រីកងទ័ពរក្សាសន្តិភាពកាន់តែខិតជិតសមភាពយេនឌ័រ។ ៦៨

ខណៈដែលស្ត្រីក្នុងនាមជាបុគ្គលិករដ្ឋបាលមានចំនួនច្រើន(៨៨%) ក៏ដោយ តំណាងស្ត្រីក្នុងតួនាទីដឹកនាំមានត្រឹមតែ ១៣% ប៉ុណ្ណោះ ដែលនេះបង្ហាញពីតម្រូវការក្នុងការពង្រឹកកិច្ចខំប្រឹងប្រែងបន្ថែមទៀតដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងតួនាទីសម្រេចចិត្ត និងដឹកនាំក្នុងកិច្ចការរក្សាសន្តិភាព។ ៦៩

ទោះបីមានភាពខ្វល់ចន្លោះនេះក៏ដោយ ស្ត្រីកងទ័ពមួកខៀវបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកសាងទំនុកចិត្តជាមួយសហគមន៍មូលដ្ឋាន ដោះស្រាយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ និងគាំទ្រភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងបរិបទក្រោយជម្លោះ។ ឧទាហរណ៍ នៅប្រទេសស៊ូដង់ខាងត្បូង ស្ត្រីកងទ័ពមួកខៀវកម្ពុជាបានធ្វើការជាមួយសហគមន៍មូលដ្ឋាន ដើម្បីបង្កើតបរិយាកាសមានសុវត្ថិភាពសម្រាប់ស្ត្រី និងកុមារ។ ៧០

ការខិតខំទាំងនេះបង្ហាញពីសក្តានុពលដ៏មានឥទ្ធិពលនៃការបញ្ជ្រាបទស្សនៈយេនឌ័រក្នុងបេសកកម្មរក្សាសន្តិភាពដែលស្របទៅនឹងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ។ ការដឹកនាំរបស់កម្ពុជានៅក្នុងវិស័យនេះក៏អាចជាគំរូសម្រាប់ប្រទេសក្រោយជម្លោះផ្សេងទៀត ដែលមានគោលដៅផ្លាស់ប្តូរពីការស្តារឡើងវិញទៅជាអ្នកចូលរួមសកម្មក្នុងការខិតខំប្រឹងប្រែងរក្សាសន្តិភាពជាសកល។

*“ខណៈពេលដែលកម្ពុជាកំពុងចាប់ផ្តើមដំណើរការរៀបចំផែនការសកម្មជាតិដំបូងរបស់ខ្លួនស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ វាជារឿងសំខាន់ក្នុងការជម្រុញតួនាទី និងការចូលរួមយ៉ាងពេញលេញរបស់ស្ត្រីក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ កម្ពុជាបានក្លាយជាអ្នកដឹកនាំថ្នាក់តំបន់មួយក្នុងវិស័យនេះ។ ខ្ញុំសង្ឃឹមថា... វានឹងជំរុញឲ្យប្រទេសសមាជិកអាស៊ានផ្សេងទៀតក៏បង្កើនការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងតួនាទីសន្តិភាព និងសន្តិសុខផងដែរ។”*

**លោកស្រី Christine Arab, នាយិកាថ្នាក់តំបន់ប្រចាំអាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ UN Women** ៧១

# ៣.១.៣. ភាពជាអ្នកដឹកនាំថ្នាក់តំបន់របស់កម្ពុជា

ដូចបានរៀបរាប់នៅជំពូកទី២ ផ្នែកទី១ កម្ពុជាបានដើរតួនាទីយ៉ាងសកម្មជាអ្នកដឹកនាំជំរុញរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ និងការត្រួតត្រាយផ្លូវឆ្ពោះទៅរកការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈនេះ ក្នុងតំបន់នៅក្នុងក្របខ័ណ្ឌអាស៊ាន។

ការចូលរួមរបស់កម្ពុជាក្នុងការបង្កើតផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ (ASEAN RPA-WPS) នេះ ត្រូវបានលើកសរសើរចំពោះការយកចិត្តទុកដាក់ក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់លើបញ្ហាយេនឌ័រនិងសន្តិសុខ។

ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាអាស៊ានលើរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ កម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើត ផែនការសកម្មភាពថ្នាក់តំបន់អាស៊ាននេះ ដែលត្រូវបានអនុម័តដោយមេដឹកនាំអាស៊ានក្នុងខែវិច្ឆិកា ឆ្នាំ២០២២ និងដាក់ឱ្យដំណើរការអនុវត្តនៅ ខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងភ្នំពេញ។[៧២]

បន្ថែមទៅលើការប្តេជ្ញាចិត្តក្នុងតំបន់នេះ កម្ពុជាបានដឹកនាំការរៀបចំ “កញ្ចប់ឧបករណ៍និងគោលការណែនាំសម្រាប់ការធ្វើមូលដ្ឋានីយកម្ម ផែនការសកម្មភាពតំបន់អាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ”។

ដាក់ឱ្យប្រើប្រាស់នៅក្រុងភ្នំពេញក្នុងខែធ្នូ ឆ្នាំ២០២៣ កញ្ចប់ឧបករណ៍នេះបានផ្តល់នូវការណែនាំ បច្ចេកទេសសម្រាប់រដ្ឋជាសមាជិកអាស៊ានក្នុងការបំលែង ផែនការសកម្មភាពថ្នាក់តំបន់អាស៊ាននេះទៅក្នុងបរិបទប្រទេសជាតិរបស់ពួកគេ។ ការណ៍នេះ នឹងជួយ សម្រួលដល់ការអនុវត្តគោលការណ៍នៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។[៧៣]

ជោគជ័យនៃគំនិតផ្តួចផ្តើមទាំងនេះ គឺអាស្រ័យលើ ការប្តេជ្ញាចិត្តផ្នែកនយោបាយ ការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព និងការចូលរួមជាបន្តបន្ទាប់ជាមួយសង្គមស៊ីវិលដើម្បីធានាបាននូវការអនុវត្តមួយប្រកបដោយបរិយាបន្ន និងគ្រប់ជ្រុងជ្រោយ។



# ៣.១.៤. ផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខរបស់កម្ពុជា (WPS NAP)

មកដល់ពេលនៃការរៀបចំសៀវភៅនេះ ការបង្កើតផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS NAP) របស់កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ។ក្រោមការដឹកនាំរបស់ក្រសួងកិច្ចការនារី សហការជាមួយអង្គការសហប្រជាជាតិ UN Women ការប្តេជ្ញាចិត្តក្នុងការរៀបចំផែនការសកម្មភាពជាតិនេះ បង្ហាញពីជំហានឆ្ពោះទៅមុខយ៉ាងសំខាន់ក្នុងការបញ្ចូលគោលការណ៍ នៃរបៀបវារៈស្ត្រីសន្តិភាពនិងសន្តិសុខនេះ ទៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិរបស់កម្ពុជា។

ដំណើរការនេះក៏បានបង្ហាញពីការចូលរួមយ៉ាងមុតមាំពីអង្គការសង្គមស៊ីវិល ដែលការរួមចំណែករបស់ពួកគេមានគោលបំណងចូលរួមចំណែករៀបចំផែនការសកម្មភាពមួយដែលប្រកបដោយបរិយាបន្ន ការចូលរួមនិងឆ្លុះបញ្ចាំងពីការពិតនៃបញ្ហាប្រឈមដែលស្ត្រីកម្ពុជាជួបប្រទះក្រោយសង្គ្រាម ជាពិសេស ទាក់ទងនឹងបញ្ហាសិទ្ធិស្ត្រី ដែលនៅតែជាបញ្ហាបន្ទាន់សម្រាប់មនុស្សជាច្រើន។

ការបង្កើត ផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាពនិងសន្តិសុខ ជាសក្ខីកម្មបង្ហាញពីការតាំងចិត្តនិងជាជោគជ័យមួយយ៉ាងសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាយេនឌ័រក្នុងកិច្ចការងារសន្តិភាពនិងសន្តិសុខ។ ការណ៍នេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងការទទួលស្គាល់ស្ត្រីថា មិនត្រឹមតែជាជនរងគ្រោះនៃជម្លោះប៉ុណ្ណោះទេ ប៉ុន្តែជាភ្នាក់ងារយ៉ាងសកម្មក្នុងការកសាងសន្តិភាព ការស្តារឡើងវិញ និងដំណើរការធ្វើការសម្រេចចិត្ត។

ដោយធ្វើស្ថាប័នីយកម្មនៃសសរស្តម្ភទាំងបួននៃរបៀបវារៈនេះ គេសង្ឃឹមថា ផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាពនិងសន្តិសុខ នឹងផ្តល់នូវវិធីសាស្ត្រជារចនាសម្ព័ន្ធមួយក្នុងការដោះស្រាយបញ្ហាប្រឈមជាប្រព័ន្ធ ដូចជា អំពើហិង្សាលើយេនឌ័រ កង្វះភាពជាតំណាងរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងភាពងាយរងគ្រោះដែលស្ត្រីប្រឈមមុខនៅក្នុងតំបន់ដែលងាយរងគ្រោះមហន្តរាយ និងសហគមន៍ដែលរងផលប៉ះពាល់ដោយជម្លោះ។

ខណៈដែល ការតាំងចិត្តក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីរបៀបវារៈស្ត្រី សន្តិភាពនិងសន្តិសុខរបស់កម្ពុជា តំណាងឱ្យភាពជោគជ័យដ៏សំខាន់មួយ ការរៀបចំនិងអនុវត្តផែនការនេះ ទំនងជាប្រឈមនឹងបញ្ហាចម្រុងៗមួយចំនួន។ បញ្ហាសំខាន់មួយនោះ គឺតម្រូវការធនធានឱ្យគ្រប់គ្រាន់និងឆន្ទៈនយោបាយជាប្រចាំ ដើម្បីធានាបានការអនុវត្តប្រកបដោយអត្ថន័យ។

ទោះបីមានក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយដូចជា ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ ដែលបង្ហាញពីការប្តេជ្ញារបស់កម្ពុជាចំពោះសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ក៏ដោយ មានអ្នកពាក់ព័ន្ធជាច្រើនបានបង្ហាញពីការព្រួយបារម្ភអំពីចន្លោះប្រហោងរវាងគោលនយោបាយ លើក្រដាសនិងការអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ ជាពិសេសតំបន់ជនបទ ដែលមានស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធនៅតែមានកម្រិត។

បទដ្ឋានយេនឌ័រចាក់ស្រេះ និងបរិយាកាសនយោបាយអាចជាឧបសគ្គក្នុងការលើកស្ទួយគោលការណ៍ WPS នៅគ្រប់ស្រទាប់សង្គម ដែលអាចធ្វើឱ្យមានភាពស្មុគស្មាញបន្ថែមទៀត ដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីធានាឱ្យមានការចូលរួម និងកិច្ចការពារប្រកបដោយអត្ថន័យសម្រាប់ស្ត្រី និងអ្នកដែលមានអត្តសញ្ញាណយេនឌ័រចម្រុះ។

បញ្ហាប្រឈមសំខាន់មួយទៀត គឺការយល់ដឹងនៅមានកម្រិតនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ រួមមានអង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអាជ្ញាធរ។ ឧទាហរណ៍ អង្គការជាច្រើនដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងសិទ្ធិស្ត្រី ការ

ដោះស្រាយវិវាទ និងអភិបាលកិច្ចល្អ ប្រហែលជាមិនទាន់បានចូលរួមពេញលេញជាមួយ ឬឈ្វេងយល់ពីរបៀបវារៈ WPS នេះឱ្យបានពេញលេញ ថាវាជាក្របខណ្ឌពិសេសមួយ។ ការណ៍នេះ កម្រិតឱកាសក្នុងការផ្ដល់ធាតុចូល និងកិច្ចសហការ។ ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពក្នុងចំណោមអង្គការសង្គមស៊ីវិល មន្ត្រីរាជការអាជ្ញាធរ និងសហគមន៍ មានសារៈសំខាន់ក្នុងការធានាថាផែនការនេះត្រូវបានយល់ច្បាស់ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

ជំហានសំខាន់មួយក្នុងទិសដៅនេះគឺការចាប់ផ្តើមកម្មវិធីថ្នាក់តំបន់មួយមានឈ្មោះថា ការលើកស្ទួយការងារសន្តិភាពរបស់ស្ត្រីនៅអាស៊ាន ហៅកាត់ថា AMPLIFY ដែលទទួលបានការឧបត្ថម្ភពីរដ្ឋាភិបាលនូវែលសេឡង់។ ក្នុងរយៈពេលប្រាំឆ្នាំ គម្រោង AMPLIFY ដែលដឹកនាំដោយអង្គការមូលនិធិអាស៊ី ដោយមានកិច្ចសហការជាមួយនឹងក្រសួងកិច្ចការនារី កំពុងវិនិយោគក្នុងការពង្រឹងសមត្ថភាព និងកសាងបណ្ដាញនៃអង្គសង្គមស៊ីវិលធ្វើការពាក់ព័ន្ធនឹងរបៀបវារៈ WPS។ ទាំងនេះ រួមមានការគាំទ្រការបណ្ដុះបណ្ដាល កិច្ចសន្ទនាអន្តរវិស័យ ការផ្ដល់ប្រឹក្សាបច្ចេកទេស និងការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អង្គការសង្គមស៊ីវិល និងក្រសួងពាក់ព័ន្ធដែលធ្វើការពាក់ព័ន្ធនឹងរបៀបវារៈ WPS នៅកម្ពុជា។

ការសិក្សាស្រាវជ្រាវបឋម ឆ្នាំ ២០២៣ របស់គម្រោង AMPLIFY បានបង្ហាញថា កម្ពុជាមានបរិបទស្មុគស្មាញក្នុងការអនុវត្តគោលនយោបាយនៃរបៀបវារៈ WPS ដោយមានផ្នែកខ្លះកម្ពុជាបានចូលរួមយ៉ាងសកម្ម ជាពិសេសតាមរយៈតួនាទីនៃភាពជាអ្នកដឹកនាំក្នុងបេសកកម្មរក្សាសន្តិភាពនៅថ្នាក់អន្តរជាតិ ដែលកម្ពុជាជាប្រទេសអាស៊ានដែលមានស្ត្រីចូលរួមច្រើនបំផុត។

ទោះជាយ៉ាងណា ក៏នៅមានកង្វះខាតដែលត្រូវដោះស្រាយក្នុងការអនុវត្តរបៀបវារៈនេះ ជាពិសេសក្នុងវិស័យកិច្ចការពារនិងឆ្លើយតបអំពើហិង្សាផ្អែកលើយេនឌ័រ ការទទួលបានយុត្តិធម៌ និងកំណែទម្រង់វិស័យសន្តិសុខ ដែលការរីកចម្រើនក្នុងផ្នែកទាំងនេះនៅតែមានកម្រិតខ្លាំង។

ប្រសិនបើអាចធានាបាននូវការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ផែនការសកម្មជាតិរបស់កម្ពុជាអាចក្លាយជាគំរូមួយសម្រាប់ថ្នាក់តំបន់ទាក់ទងនឹងរបៀបដែលគោលការណ៍នៃរបៀបវារៈ WPS អាចត្រូវបានយកទៅអនុវត្តក្នុងបរិបទសង្គមនយោបាយមួយដ៏ស្មុគស្មាញ។

ភាពជោគជ័យរបស់ផែនការសកម្មភាពជាតិនេះនឹងអាស្រ័យលើការប្ដេជ្ញាផ្នែកនយោបាយយ៉ាងម៉ឺងម៉ាត់ និងការសហការជានិច្ចរវាងអាជ្ញាធរ អង្គការសង្គមស៊ីវិល និងដៃគូអន្តរជាតិ ជាមួយនឹងការខិតខំប្រឹងប្រែងបន្តបន្ទាប់ក្នុងការកសាងសមត្ថភាពស្ថាប័ន ដោះស្រាយវិសមភាពយេនឌ័របែបប្រព័ន្ធ និងធានាបាននូវទំនួលខុសត្រូវក្នុងការអនុវត្តផែនការ។

# ៣.១.៥ ផែនការសកម្មភាព ជាតិរបស់ប្រទេសកម្ពុជា

## ហេតុអ្វីរបៀបវារៈស្ត្រីសន្តិភាពនិងសន្តិសុខនៅកម្ពុជាមានសារៈសំខាន់៖ លើសពីផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងគោលនយោបាយយេនឌ័រដែលមានស្រាប់

សំណួរដ៏សំខាន់មួយដែលបានលើកឡើងជាញឹកញាប់នៅក្នុងកិច្ចពិភាក្សាថ្នាក់គោលនយោបាយនោះគឺហេតុអ្វីបានជារបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ មានភាពចាំបាច់នៅកម្ពុជា ដោយសារតែកម្ពុជាមានផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) គោលនយោបាយសមភាពយេនឌ័រនិងក្របខ័ណ្ឌផ្សេងៗ ស្តីពី យេនឌ័រ និង អំពើហិង្សាលើយេនឌ័ររួចទៅហើយ?

ទោះបីជាក្របខ័ណ្ឌទាំងនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសមភាពយេនឌ័រនិងការដោះស្រាយបញ្ហាអំពើហិង្សាលើយេនឌ័រយ៉ាងណាក្តី ក៏ក្របខ័ណ្ឌទាំងនេះ មិនគ្របដណ្តប់គ្រប់ជ្រុងជ្រោយទាំងអស់នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ហើយក៏មិនរួមបញ្ចូលការទប់ស្កាត់ជម្លោះ ការកសាងសន្តិភាព និងការពិចារណាអំពីសុវត្ថិភាពក្នុងវិសាលភាពឯកសារទាំងនោះទេ។

ផ្ទុយពីគោលនយោបាយយេនឌ័រតាមវិស័យជាក់លាក់ ក្របខ័ណ្ឌនៃរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា ដោយផ្សារភ្ជាប់បញ្ហានៃអំពើហិង្សាផ្អែកលើយេនឌ័រ យុត្តិធម៌ អភិបាលកិច្ច ការដោះស្រាយជម្លោះ និងកំណែទម្រង់ផ្នែកសន្តិសុខ។

របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ សង្កត់ធ្ងន់មិនត្រឹមតែកិច្ចការពារចេញពីអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តោតសំខាន់លើការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តភាពជាអ្នកដឹកនាំ និងដំណើរការកសាងសន្តិភាពផងដែរ។

នៅក្នុងបរិបទកម្ពុជា របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មានភាពពាក់ព័ន្ធ ពីព្រោះ៖

- ជាស្ពានភ្ជាប់គម្លាតរវាងសន្តិសុខនិងយុត្តិធម៌យេនឌ័រ។ ខណៈដែលផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ផ្តោតជាចម្បងលើការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារនិងផ្លូវភេទ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ពង្រីកកិច្ចសន្ទនានេះ ដោយរួមបញ្ចូលអំពើហិង្សាបែបរចនាសម្ព័ន្ធ អសន្តិសុខសេដ្ឋកិច្ច និងតួនាទីរបស់ស្ត្រីក្នុងអភិបាលកិច្ចរក្សាសន្តិភាពនិងដោះស្រាយទំនាស់។

- របៀបវារៈនេះក៏ពង្រឹងការចូលរួមរបស់ស្ត្រីក្នុងយន្តការអភិបាលកិច្ច ការសម្រុះសម្រួល និង យុត្តិធម៌។ ខណៈដែលគោលនយោបាយដែលមានស្រាប់និយាយអំពីសមភាពយេនឌ័រយ៉ាងទូលំទូលាយ គោលនយោបាយទាំងនោះមិនបានធានា ជាក់លាស់ពីភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងថ្នាក់សម្រេចចិត្តទាក់ទងនឹងវិស័យទប់ស្កាត់ជម្លោះនិងសន្តិសុខនោះទេ។

- ផ្សារភ្ជាប់កិច្ចខិតខំប្រឹងប្រែងក្នុងស្រុកទៅនឹងការប្តេជ្ញាចិត្តជាសកល។ កម្ពុជាក្នុងនាមជាប្រទេសហត្ថលេខីនៃក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិនិងយុត្តិធម៌យេនឌ័រ អាចប្រើប្រាស់របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ដើម្បីផ្សាភ្ជាប់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ជាមួយនឹងការប្តេជ្ញាចិត្តជាសកល ដូចជា ក្នុងក្របខ័ណ្ឌ អនុសញ្ញាស៊ីដរ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ។

ដូច្នេះ របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ មិនមែនជាក្របខណ្ឌជាន់គ្នានឹងគោលនយោបាយដែលមានស្រាប់ណាមួយទេ តែផ្ទុយទៅវិញ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នេះ បានផ្តល់នូវវិធីសាស្ត្របែបរួមបញ្ចូលគ្នាបន្ថែមទៀត ដែលពង្រឹងការសម្រុះសម្រួលឆ្លើយតបនឹង

យេនឌ័រ ពង្រឹងការទទួលបានយុត្តិធម៌ ដែលផ្តោតលើជនរងគ្រោះជាចម្បង និងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការដោះស្រាយទំនាស់។

## ការសម្រុះសម្រួលឆ្លើយតបនឹងយេនឌ័រ៖ ភាពខ្លាំងនិងបញ្ហាប្រឈម

នៅកម្ពុជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាការអនុវត្តបែបប្រពៃណីមួយដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការដោះស្រាយវិវាទគ្រួសារ និងសហគមន៍ រួមទាំងវិវាទរវាងដៃគូស្និទ្ធស្នាលផងដែរ។

ទោះជាយ៉ាងណាក៏ដោយ យោងតាមការស្រាវជ្រាវពីមុនរបស់អង្គការនារីដើម្បីសន្តិភាព បានបង្ហាញថា យន្តការដោះស្រាយវិវាទមូលដ្ឋាន ជារឿយៗបានបរាជ័យក្នុងការផ្តល់អាទិភាពដល់សុវត្ថិភាពជនរងគ្រោះ ឬប្រកាន់ខ្ជាប់នូវគោលការណ៍សមភាពយេនឌ័រ [៧៤]។

ខណៈដែលមានបញ្ហាប្រឈមចម្បងៗក្នុងការប្រើប្រាស់វិធីសាស្ត្រដោះស្រាយក្រៅប្រព័ន្ធតុលាការក្នុងការឆ្លើយតបអំពើហិង្សាលើយេនឌ័រនៅប្រទេសកម្ពុជា មានកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលកំពុងដំណើរការ ដើម្បីបង្កើតជាផ្លូវការ និងកម្រិតការអនុវត្តការសម្រុះសម្រួលនេះ ដើម្បីធានាថា ជនរងគ្រោះបានទទួលការការពារនិងគាំទ្រ។ ហើយក៏មានកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកទឹកចិត្តស្ត្រីឱ្យដើរតួជាអ្នកសម្រុះសម្រួលគ្រប់កម្រិតផងដែរ។

ការសម្រុះសម្រួលដែលឆ្លើយតបនឹងយេនឌ័រ (GRM) ធ្វើឱ្យមានស្តង់ដារវិជ្ជាជីវៈក្នុងការអនុវត្តការសម្រុះសម្រួល ដោយកំណត់ការអនុវត្តចំពោះតែករណីទាំងឡាយណាដែលមិនរាប់បញ្ចូលអំពើហិង្សាលើរាងកាយ។ ការសម្រុះសម្រួលដែលឆ្លើយតបនឹងយេនឌ័រ (GRM) ក៏ផ្តោតសំខាន់លើការចាត់ទុកជនរងគ្រោះជាចម្បង បង្កើនកិច្ចការពារ និងកាត់បន្ថយហានិភ័យ។ ការណ៍នេះបានផ្តល់ជូននូវជម្រើសដោះស្រាយវិវាទ ដែលស្របច្បាប់ និងសមស្រប។

ទម្រង់នៃការសម្រុះសម្រួលដែលឆ្លើយតបនឹងយេនឌ័រ (GRM) រួមមាន:

- យន្តការត្រួតពិនិត្យបឋមនិងការបញ្ជូនបន្ត ដើម្បីធានាថា ករណីដែលពាក់ព័ន្ធនឹងអំពើហិង្សាត្រូវបានបញ្ជូនត្រឹមត្រូវតាមការអនុវត្តច្បាប់និងបទដ្ឋានផ្សេងៗទៀត។
- ការបណ្តុះបណ្តាលនិងការទទួលស្គាល់អ្នកសម្រុះសម្រួលដោយផ្តោតលើការបង្កើនសមាសភាពអ្នកសម្រុះសម្រួលជាស្ត្រី និងការអនុវត្តដែលគិតគូរពីយេនឌ័រ។
- គោលវិធីចាត់ទុកជនរងគ្រោះជាចម្បងដោយផ្តល់អាទិភាពដល់សុវត្ថិភាព និងតម្រូវការស្ត្រីដែលរងផលប៉ះពាល់ដោយវិវាទ។

ខណៈដែលកិច្ចខិតខំប្រឹងប្រែងទាំងនេះ ទំនងជាផ្តល់នូវផលជះវិជ្ជមាន ក៏នៅតែមានឧបសគ្គមួយចំនួនក្នុងការអនុវត្តគោលការណ៍នេះដាក់ស្តែង ឱ្យបានពេញលេញនិងប្រកបដោយប្រសិទ្ធភាព។ ទាំងនេះរួមមានភាពមិនស៊ីសង្វាក់គ្នាក្នុងការបណ្តុះបណ្តាលនិងការអនុវត្តចំណេះដឹងគម្លាតក្នុងការអនុវត្តសេចក្តីសម្រេចរដ្ឋបាល និងដីកាការពារនិងបទដ្ឋានវប្បធម៌ ដែលផ្តល់អាទិភាពដល់ការផ្សះផ្សាគ្រួសារជាងការការពារជនរងគ្រោះ។

បញ្ហាប្រឈមទាំងនេះបង្ហាញពីតម្រូវការក្នុងការបន្តការវិនិយោគលើការកសាងសមត្ថភាព ការណែនាំច្បាស់លាស់និងយន្តការដែលធានាថា ស្ត្រីដែលជួបប្រទះអំពើហិង្សា អាចទទួលបានទាំងយុត្តិធម៌ កិច្ចការពារ និងការគាំទ្រ។

## តួនាទីនៃការសម្រុះសម្រួលក្នុងការទប់ស្កាត់និងការចូលរួម

បន្ថែមលើតួនាទីដោះស្រាយវិវាទរដ្ឋប្បវេណី គោលការណ៍សម្រុះសម្រួលប្រកបដោយការឆ្លើយតបយេនឌ័ មានសក្តានុពលក្នុងការរួមចំណែកដល់ការទប់ស្កាត់អំពើហិង្សា និងបង្កើនការចូលរួមរបស់ស្ត្រីក្នុងការដោះស្រាយវិវាទ និងការដឹកនាំសហគមន៍។

ការសម្រុះសម្រួល នៅពេលដែលអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រកបដោយក្រមសីលធម៌ អាចប្រើប្រាស់ជាឧបករណ៍អន្តរាគមន៍បឋម កាត់បន្ថយភាពតានតឹង មុនពេលកើតមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរ។

លើសពីនេះ ការពង្រឹងសមត្ថភាពស្ត្រីក្លាយជាអ្នកសម្រុះសម្រួល ក៏ដូចជា ជាអ្នកដឹកនាំធ្វើសេចក្តីសម្រេច នៅក្នុងយន្តការដោះស្រាយវិវាទមូលដ្ឋាន អាចបង្កើនការចូលរួមរបស់ស្ត្រីក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពនិងរក្សាសន្តិសុខមូលដ្ឋានផងដែរ។

# ៣.២. ឈ្វេងយល់ពីសសរស្តម្ភ ទាំង៤ ក្នុងបរិបទកម្ពុជា

ដូចបានរៀបរាប់នៅជំពូកទី១ ផ្នែកទី៤ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ផ្តោតជាសំខាន់លើសសរស្តម្ភទាំង៤៖ ការទប់ស្កាត់ ការការពារ ការចូលរួម និង ការសង្គ្រោះនិងការស្តារឡើងវិញ។




សសរស្តម្ភទាំងនេះបានរចនាឡើងដើម្បីធានាថាទស្សនៈរួម តម្រូវការ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រី ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសន្តិភាពនិងសន្តិសុខសកល។

សសរស្តម្ភទាំងនេះផ្តល់នូវក្របខ័ណ្ឌបែបបត់បែនមួយ សម្រាប់ការយល់ដឹង និងដោះស្រាយលក្ខណៈយេនឌ័រនៃបញ្ហាជម្លោះ ការកសាងសន្តិភាព និងអភិបាលកិច្ចផ្នែកសន្តិសុខ ដោយធានាថាស្ត្រី ក្មេងស្រី និងអ្នកមានអត្តសញ្ញាណចម្រុះផ្សេងទៀត មិនត្រឹមតែទទួលបានការការពារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានការផ្តល់ភាពអង់អាចក្នុងនាមជាភ្នាក់ងារសកម្មក្នុងការផ្លាស់ប្តូរផងដែរ។

ផ្នែកនេះនឹងឈ្វេងយល់ពីការអនុវត្តសសរស្តម្ភទាំងបួននៅក្នុងបរិបទកម្ពុជា ដោយពិចារណាពីបទពិសោធន៍ប្រវត្តិសាស្ត្រ បញ្ហាប្រឈមសហសម័យ និងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការអនុវត្តគោលការណ៍របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។

ជាការសំខាន់ គប្បីកត់សម្គាល់ថា សសរស្តម្ភទាំងនេះមិនស្ថិតនៅតែឯងទេ (វាមានភាពរលូន និងត្រួតស៊ីគ្នា)។ បញ្ហា ករណីសិក្សា និងការពិចារណាអំពីគោលនយោបាយជាច្រើននៃសសរស្តម្ភនីមួយៗ ឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃភាពជាក់ស្តែងរបស់ការងារសន្តិភាពនិងសន្តិសុខ។

ក្របខ័ណ្ឌនេះជាចំណុចចាប់ផ្តើមសម្រាប់ការវិភាគនិងការពិភាក្សាកាន់តែស៊ីជម្រៅមួយស្តីពីរបៀបដែល របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ អាចត្រូវបានយកមកអនុវត្ត សម្រប និងដំណើរការក្នុងបរិបទកម្ពុជាបច្ចុប្បន្ន។

គោលបំណង គឺបង្ហាញពីឧទាហរណ៍មួយចំនួនស្តីពីរបៀបដែលគោលការណ៍ របៀបវារៈស្ត្រី សន្តិភាព និង សន្តិសុខ អាចត្រូវបានអនុវត្ត (និងបានអនុវត្តរួច) ដើម្បីបង្កើនសិទ្ធិ យុត្តិធម៌ សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី ក្មេងស្រី និងអ្នកមានអត្តសញ្ញាណចម្រុះ នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។

# ៣.២.១.

# សសរស្តម្ភទី ១

# ការទប់ស្កាត់

ការបង្ការទប់ស្កាត់ ដូចដែលបានបញ្ជាក់នៅក្នុងរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដោះស្រាយបញ្ហាឫសគល់នៃជម្លោះ និងផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងបញ្ចៀសអំពើហិង្សាមុនពេលវាកើតឡើង។

វាទទួលស្គាល់ពីវិសមភាពជាប្រព័ន្ធ ការរើសអើងយេនឌ័រ និងអតុល្យភាពអំណាចបែបរចនាសម្ព័ន្ធ ដែលជាញឹកញយបង្កើតជាវដ្តនៃអំពើហិង្សា។

តាមរយៈការដោះស្រាយឫសគល់នៃមូលហេតុទាំងនេះ ការបង្ការទប់ស្កាត់ មិនត្រឹមតែកាត់បន្ថយហានិភ័យភ្លាមៗនៃជម្លោះប៉ុណ្ណោះទេ ប៉ុន្តែក៏ជំរុញឱ្យមានបរិយាកាសអំណោយផលដល់សន្តិភាពយូរអង្វែងផងដែរ។

វារួមបញ្ចូលទាំងការលើកកម្ពស់សមធម៌យេនឌ័រ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនិងក្មេងស្រី និងធានាការរួមបញ្ចូលអភិបាលកិច្ច ដែលផ្តល់តម្លៃដល់សំឡេងចម្រុះ ជាពិសេសសំឡេងពីសហគមន៍ងាយរងគ្រោះ។

## នៅកម្ពុជា ការបង្ការទប់ស្កាត់មានភាពបន្ទាន់ ពិសេស។

ប្រវត្តិសាស្ត្រកម្ពុជា ដែលពោរពេញដោយជម្លោះរ៉ាំរ៉ៃ និងប្រើពេលជាច្រើនទសវត្សរ៍ក្នុងការស្តារឡើងវិញ គូសបញ្ជាក់ពីសារៈសំខាន់នៃការបង្ការទប់ស្កាត់ភាពតានតឹងរវាងក្រុមផ្សេងៗ និងការការពារស្ត្រីនិងក្មេងស្រីដែលរងអយុត្តិធម៌ជាប្រព័ន្ធ។

ក្នុងបរិបទនេះ មានកិច្ចការសំខាន់ៗពីរ នោះគឺទំនាស់អន្តរជាតិពិន្ទុ ឬសាសនា និងទំនាស់ដីធ្លីនិងធនធានធម្មជាតិ ដែលបានបង្ហាញពីផលប៉ះពាល់ដែលមានលក្ខណៈយេនឌ័រ នៃកិច្ចខិតខំប្រឹងប្រែងក្នុងការបង្ការទប់ស្កាត់ និងសារៈសំខាន់នៃការរួមបញ្ចូលគោលការណ៍នៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។

**ការទប់ស្កាត់ទំនាស់ចម្រុះជាតិសាសន៍ និងសាសនា**

**ការទប់ស្កាត់ទំនាស់ដីធ្លី និងធនធានធម្មជាតិ**

→ តើអ្នកអាចទឹកឃើញឧទាហរណ៍បន្ថែមទៀតទាក់ទងនឹងសសរស្តម្ភបង្ការទប់ស្កាត់នេះក្នុងបរិបទកម្ពុជា?

# ទំនាស់ចម្រុះជាតិសាសន៍ និងសាសនាះ ស្ត្រីនៅចំណុចប្រសព្វ

ភាពតានតឹងរវាងជនជាតិ និង សាសនាភាគតិចផ្សេងៗ ជាពិសេស នៅក្នុងសហគមន៍ជនបទ និង ងាយរងគ្រោះ គឺមិនមែនជារឿងចម្លែកសម្រាប់កម្ពុជានោះទេ។ ទំនាស់ទាំងនេះ ជារឿយៗបង្កឡើង ដោយការប្រកួតប្រជែងយក ធនធាន ការយល់ច្រឡំផ្នែកវប្បធម៌ ឬ ដោយសារកត្តានយោបាយ និងប្រវត្តិសាស្ត្រ។

បើទោះបីជា ទំនាស់ទាំងនេះ ផ្តល់ផលជះលើសហគមន៍ទាំងមូលក៏ដោយ ស្ត្រីតែងតែទទួលបន្ទុកដ៏ពិសេស និង ច្រើនជាងគេ។ ស្ត្រីមិនត្រឹមតែមានភាពងាយរងគ្រោះទៅនឹងអំពើហិង្សា ដែលបណ្តាលមកពីទំនាស់រវាងក្រុមនានា ទេ ប៉ុន្តែ ក៏ត្រូវបានបដិសេធមិនឱ្យចូលរួមក្នុងយន្តការដោះស្រាយទំនាស់ផងដែរ។

ក្នុងករណីជាច្រើន បែបផែនបិតាធិបតេយ្យ បញ្ជាក់ថាបុរសគួរតែជាអ្នកគ្រប់គ្រងលើការសម្រេចចិត្ត ទាំងនៅក្នុង បរិបទផ្លូវការ និងក្រៅផ្លូវការ ដោយបង្ហាញថាសំឡេងរបស់ស្ត្រីមិនត្រូវបានឮ។ ការបដិសេធនេះ បន្តបង្កើតវដ្ត វិសមភាព និង បិទបាំងជីវិតពិតរបស់ស្ត្រីដែលជាអ្នកចរចានិងអ្នកថែទាំក្នុងសហគមន៍នៅពេលមានវិបត្តិ។

ឧទាហរណ៍មួយដែលបង្ហាញពីបញ្ហានេះ គឺការរើសអើងដែលស្ត្រីជនជាតិចាមមូស្លីម នៅកម្ពុជាជួបប្រទះ ជាពិសេសការផាត់ចេញដោយផ្អែកលើការប្រតិបត្តិសាសនានិងកត្តាយេនឌ័រ។

ភាពតានតឹងចម្រុះជាតិសាសន៍និងសាសនាបានកើនឡើងដល់កម្រិតខ្ពស់បំផុត នៅឆ្នាំ១៩៧៥ -១៩៧៩ នៅពេល ដែលជនជាតិភាគតិចវៀតណាម និងចាមមូស្លីម ត្រូវបានខ្មែរក្រហមកំណត់គោលដៅក្នុងការសម្លាប់រង្គាលក្នុង របបខ្មែរក្រហម។ ឧក្រិដ្ឋកម្មនេះ ត្រូវបានសាលាក្តីខ្មែរក្រហមកាត់ទោសថា ជាបទអំពើប្រល័យពូជសាសន៍មកលើក្រុមជនជាតិភាគតិចវៀតណាមនិងចាម។ កេរ្តិ៍ដំណែលនៃអំពើហិង្សានេះ នៅតែបន្តប៉ះពាល់និងធ្វើឱ្យមានភាព តានតឹងរវាងជនជាតិភាគតិចទាំងនេះនៅកម្ពុជានាពេលបច្ចុប្បន្ន។

ភាពងាយរងគ្រោះរបស់ពួកគេបង្ហាញពីតម្រូវការចាំបាច់ សម្រាប់ក្របខ័ណ្ឌរបៀបវារៈស្ត្រីសន្តិភាព និងសន្តិសុខ ដែលផ្តល់អាទិភាពដល់ការចូលរួមរបស់ស្ត្រីដែលមកពីអត្តសញ្ញាណចម្រុះនិងភាគតិចទាំងនេះ ចូលរួម ក្នុងកិច្ចការកសាងសន្តិភាព។ ការវិនិយោគលើការអប់រំសន្តិភាព កិច្ចសន្ទនាចម្រុះជាតិសាសន៍និងអន្តរវប្បធម៌ និងគំនិតផ្តួចផ្តើមទាក់ទងនឹងការសម្រុះសម្រួលដឹកនាំដោយសហគមន៍ ដែលបន្លើសំឡេងស្ត្រី គឺជាវិធីសាស្ត្រមួយឈានទៅមុខ។

ដូចដែលឃើញក្នុងករណីសិក្សាខាងក្រោម កម្មវិធីសហគមន៍ដែលដឹកនាំដោយអង្គការស្ត្រីនៅកម្ពុជា បានបង្ហាញ ពី សក្តានុពលក្នុងការបង្កើតកន្លែងសុវត្ថិភាពសម្រាប់ការសន្ទនារវាងក្រុម ផ្សាភ្ជាប់គន្លាតខុសគ្នាផ្នែកវប្បធម៌ និងកាត់បន្ថយភាពតានតឹង។

# ករណីសិក្សាអំពីការអនុវត្តល្អៗ៖

## ការទប់ស្កាត់ទំនាស់ចម្រុះជាតិសាសន៍និងសាសនាតាមរយៈ ការកសាងសន្តិភាពសហគមន៍

### អង្គការនារីដើម្បីសន្តិភាព (នដស ឬ WPM)

ខណៈដែលភាគីច្រើននៃប្រជាជនកម្ពុជាជាជនជាតិខ្មែរ ប្រទេសកម្ពុជាក៏ជាជម្រកនៃសហគមន៍ចម្រុះជាតិសាសន៍ និងសាសនា រួមមាន ជនជាតិភាគតិចវៀតណាម ចាមឬខ្មែរឥស្លាម ចិន លាវ ជនជាតិដើមភាគតិច និងក្រុមភាគតិចដទៃទៀត។ ក្រុមជនជាតិភាគតិចនៅតែបន្តប្រឈមមុខនឹងបញ្ហានានា ដូចជា ការរើសអើង ការផាត់ចេញ និងភាពតានតឹងអន្តរសហគមន៍។ សោកនាដកម្មប្រវត្តិសាស្ត្រ វិវាទដីធ្លី និងភាពងាយរងគ្រោះក្នុងសង្គម ធ្វើឱ្យមានការបែកបាក់គ្នាកាន់តែខ្លាំង ហើយក្នុងករណីខ្លះឈានដល់ទំនាស់ហិង្សា។

ដោយទទួលស្គាល់តម្រូវការបន្ទាន់ក្នុងការទប់ស្កាត់ទំនាស់ចម្រុះជាតិសាសន៍និងសាសនា អង្គការនារីដើម្បីសន្តិភាព (នដស) បានអនុវត្តកម្មវិធីសន្តិភាពនិងការបំប្លែងទំនាស់តាមរយៈការសម្រុះសម្រួលឆ្លើយតបយេនឌ័រ ការប្រាស្រ័យទាក់ទងអហិង្សា (NVC) កិច្ចសន្ទនាអន្តរជាតិពន្ធនិងអន្តរសាសនា និងនីតិវិធីផ្សេងៗទៀតក្នុងការដោះស្រាយទំនាស់ ដើម្បីកសាងទំនុកចិត្ត ការយោគយល់ និងកិច្ចសហប្រតិបត្តិការរវាងសហគមន៍។

### ការបង្ការទប់ស្កាត់ទំនាស់ដោយអហិង្សា និងការពង្រឹងភាពជាអ្នកដឹកនាំសន្តិភាពរបស់ស្ត្រី

ធាតុស្នូលមួយនៃវិធីសាស្ត្ររបស់ នដស គឺការផ្តល់អំណាចដល់ស្ត្រីក្នុងនាមជាអ្នកកសាងសន្តិភាព អ្នកដឹកនាំ និងជាអ្នកបង្កើតការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេ ដោយលើសពីតួនាទីជាជនរងគ្រោះ ឬអ្នកចូលរួមទៅទៀត។ តាមរយៈការបណ្តុះបណ្តាលលើវិធីសាស្ត្របំប្លែងទំនាស់ កិច្ចសន្ទនាប្រកបដោយបរិយាបន្ន ការកសាងទំនុកចិត្តនិងទំនាក់ទំនងចម្រុះជាតិសាសន៍ ការសិក្សាស្រាវជ្រាវសហគមន៍ និងការកៀរគរសហគមន៍ធ្វើសកម្មយ៉ាងមានប្រសិទ្ធភាព ស្ត្រីនិងយុវជនមកពីគ្រប់អត្តសញ្ញាណយេនឌ័រ ជនជាតិ សាសនា និងស្ថានភាពសង្គមចម្រុះ ត្រូវបានបណ្តុះបណ្តាលឱ្យមានជំនាញក្នុងការកាត់បន្ថយភាពតានតឹង ដោះស្រាយទំនាស់ចម្រុះជាតិសាសន៍និងសាសនាក្នុងសង្គម និងកៀរគរឱ្យមានការរួមរស់ជាមួយភាពខុសគ្នាដោយសន្តិភាព។

សិក្ខាកាមជាច្រើន ដែលអ្នកខ្លះថែមទាំងបានបង្កើតជាបណ្តាញ បានបន្តដឹកនាំសកម្មភាពសន្តិភាព និងជួយទប់ស្កាត់ការរីករាលដាលនៃព័ត៌មានមិនពិត កាត់បន្ថយអាកប្បកិរិយាបែបរើសអើងក្នុងសហគមន៍ និងសម្របសម្រួលកិច្ចសន្ទនាអន្តរជំនឿ និងរវាងក្រុមដែលធ្លាប់មានការមិនចុះសម្រុងគ្នាពីមុនមក។

នដស ក៏ប្រើឧបករណ៍ច្នៃប្រឌិត និងបែបចូលរួម ដូចជា វិធីសាស្ត្រស្រាវជ្រាវតាមបែបសន្ទនា ឬ Facilitative Listening Design (FLD) ដែលជាឧបករណ៍ស្រាវជ្រាវសន្តិភាពមួយដែល នដស បង្កើតឡើង ដើម្បីស្វែងយល់ពីបរិបទទំនាស់ដែលមានភាពរសើប និងបង្កើតការអន្តរាគមន៍ប្រកបដោយយុទ្ធសាស្ត្រ និងចំគោលដៅ។ ឧបករណ៍នេះក៏ជាឯកសារដែលផ្អែកលើភស្តុតាង ក្នុងការជះឥទ្ធិពលដល់គោលនយោបាយ ការសំដែងមតិជាសាធារណៈ និងតួអង្គពាក់ព័ន្ធសំខាន់ៗ។[៧៧]

នដស មានគោលបំណងបញ្ចូលទស្សនៈយេនឌ័រទៅក្នុងការដោះស្រាយទំនាស់ចម្រុះជាតិសាសន៍និងសាសនា ដើម្បីឱ្យកម្មវិធីទាំងនេះ ស្របទៅនឹងរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ជាពិសេសក្រោមសសរស្តម្ភនៃការការពារ។ នដស ចង់ចូលរួមចំណែកកាត់ផ្តាច់វដ្តនៃអំពើហិង្សា លុបបំបាត់ការរើសអើងជាប្រព័ន្ធ និងបង្កើនសាមគ្គីភាពសង្គម រយៈពេលវែងរវាងសហគមន៍ចម្រុះជាតិសាសន៍ និងសាសនានៅកម្ពុជា ខណៈដែលដោះស្រាយបញ្ហានៃការរើសអើងផ្អែកលើយេនឌ័រចំពោះស្ត្រីដែលត្រូវបានគេផាត់ចេញ និងជម្រុញភាពជាអ្នកដឹកនាំ និងសិទ្ធិស្ត្រីទូទៅផងដែរ។

ការធ្វើស្ថាប័នីយកម្មលើ ហេដ្ឋារចនាសម្ព័ន្ធសន្តិភាពនៅក្នុងសង្គម គឺសំខាន់ណាស់ដើម្បីសម្រេចបានការកសាងសន្តិភាពប្រកបដោយចីរភាព ហើយនដស កំពុងខិតខំបញ្ជ្រៀបការអប់រំសន្តិភាព និងការសម្រុះសម្រួលវិវាទនៅក្នុងសាលារៀន ទៅតាមសាលាមធ្យមសិក្សានៅតាមតំបន់ជនបទផងដែរ។

# ទំនាស់ដីធ្លីនិងធនធានធម្មជាតិ៖ ផលប៉ះពាល់យេនឌ័រនិងសន្តិសុខកម្មសិទ្ធិកាន់កាប់ដីធ្លី

ការអភិវឌ្ឍដ៏លឿនរហ័សនៃសេដ្ឋកិច្ចកម្ពុជាបានបង្កើតបញ្ហាប្រឈមចម្បងៗ ដូចជា ទំនាស់ដីធ្លីនិងធនធានធម្មជាតិ។

ការវិនិយោគដីធ្លីជាលក្ខណៈទ្រង់ទ្រាយធំ ជាទូទៅសម្រាប់អាជីវកម្មកសិកម្ម ឬការទាញយកឧស្សាហកម្មរ៉ែ បានធ្វើឱ្យប្រជាជននៅទីជនបទរាប់ពាន់គ្រួសារត្រូវផ្លាស់ទីលំនៅដោយបង្ខំ ដែលប៉ះពាល់ដល់ស្ត្រីផងដែរ។[៧៨]

ទំនាស់ទាំងនេះកាន់តែប្រឈមខ្លាំងឡើងដោយសារប្រវត្តិអសន្តិសុខក្នុងការកាន់កាប់ដីធ្លីនៅកម្ពុជា ដែលកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជម្លោះ មិនអាចបង្កើតប្រព័ន្ធកាន់កាប់ដីធ្លីរឹងមាំមួយ ដើម្បីការពារប្រជាជនដែលងាយរងគ្រោះ។

សម្រាប់ស្ត្រី ទំនាស់ដីធ្លីបង្កផលវិបាកជាច្រើន។ ស្ត្រីជាទូទៅត្រូវបានផាត់ចេញពីកម្មសិទ្ធិដីធ្លី ដោយសារតែកត្តាបទដ្ឋានវប្បធម៌ ដែលផ្តល់អាទិភាពដល់មរតកនិងកម្មសិទ្ធិទៅបុរស។

ការមិនបានទទួលសិទ្ធិទាំងនេះ ធ្វើឱ្យពួកគេជាច្រើនងាយរងគ្រោះពីការធ្វើចំណាកស្រុក និងអសន្តិសុខសេដ្ឋកិច្ចនៅពេលមានវិបត្តិកើតឡើង។

ជាពិសេសស្ត្រីជាមេគ្រួសារ ប្រឈមមុខនឹងហានិភ័យខ្ពស់ ដោយសារពួកគេទទួលរងការគំរាមកំហែងនៃការបណ្តេញចេញ ឧបសគ្គផ្នែកច្បាប់ និងការរើសអើងជាប្រព័ន្ធ។

ឧទាហរណ៍ ទំនាស់ដីធ្លី ជារឿយៗនាំឱ្យមានការកើនឡើងខ្ពស់នៃអត្រាអំពើហិង្សាលើយេនឌ័រ។[៧៩]

ការផ្លាស់ទីលំនៅ ដែលបណ្តាលមកពីការបណ្តេញចេញដោយបង្ខំ ធ្វើឱ្យមានការកើនឡើងនូវភាពងាយរងគ្រោះដល់ស្ត្រីនិងក្មេងស្រីក្នុងការកេងប្រវ័ញ្ច ការជួញដូរ និងការបំពាន។ ហានិភ័យទាំងនេះ កាន់តែធ្ងន់ធ្ងរនៅពេលស្ត្រីនិងក្មេងស្រីដែលរងផលប៉ះពាល់ មិនត្រូវបានដាក់បញ្ចូលនៅក្នុងដំណើរការ សម្រេចចិត្តលើកម្មសិទ្ធិដីធ្លីនិងកិច្ចខិតខំប្រឹងប្រែងកៀរគរការគាំទ្រ។

ការដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារការរួមបញ្ចូលគោលវិធីឆ្លើយតបយេនឌ័រទៅក្នុងគោលនយោបាយអភិបាលកិច្ចដីធ្លី។

ការពង្រឹងសន្តិសុខកម្មសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រីនិងការទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងនាមជាម្ចាស់ដីធ្លីគឺជាជំហានដ៏សំខាន់មួយ។ គំនិតផ្តួចផ្តើមផ្សេងៗ ដូចជាកម្មវិធីយល់ដឹងផ្នែកច្បាប់ ជាពិសេសផ្តោតលើស្ត្រីដែលប្រឈមនឹងការបណ្តេញចេញ និងកិច្ចខិតខំប្រឹងប្រែងសម្របខ្លួនក្នុងសហគមន៍ដឹកនាំដោយអង្គការសិទ្ធិមនុស្សនិងអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ធ្វើការលើការគាំទ្រប្រជាជនដែលរងផលប៉ះពាល់ ឬមានហានិភ័យខ្ពស់។

ឧទាហរណ៍ អង្គការសង្គមស៊ីវិលកម្ពុជា ដូចជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានតស៊ូមតិក្នុងការបង្កើតគោលនយោបាយដីធ្លី និងលំនៅឋាន ដែលឆ្លើយតបនឹងយេនឌ័រ ខណៈដែលអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ធ្វើការផ្តោតលើការផ្តល់ភាពអង់អាចដល់សហគមន៍ តាមរយៈការផ្តល់ចំណេះដឹងអំពីសិទ្ធិដីធ្លីរបស់ពួកគេ ដោយសង្កត់ធ្ងន់លើការរើសអើងយេនឌ័រជាប្រព័ន្ធ ស្តីពីការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ (សូមអានករណីសិក្សាខាងក្រោម) ។

# ករណីសិក្សាអំពីការអនុវត្តល្អៗ៖

## ការគាំទ្រដល់សន្តិសុខកម្មសិទ្ធិដីធ្លីរបស់ស្ត្រី

### ការតស៊ូមតិ៖ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានដឹកនាំការងារទប់ស្កាត់ទំនាស់ដីធ្លី ដោយការតស៊ូមតិដើម្បីសន្តិសុខកម្មសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី។ កម្មសិទ្ធិដីធ្លីរបស់ស្ត្រី គឺជាកត្តាសំខាន់មួយក្នុងការធ្វើឱ្យសហគមន៍មានស្ថិរភាព និងកាត់បន្ថយហានិភ័យនៃជម្លោះនិងការបណ្តេញចេញ ប៉ុន្តែឧបសគ្គជាប្រព័ន្ធ ធ្វើឱ្យស្ត្រីងាយរងគ្រោះដោយសារការរំលោភដីធ្លី ការបណ្តេញចេញដោយបង្ខំ និងអំពើហិង្សាយេនឌ័រ (GBV)។

ឯកសាររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានបង្ហាញថា នៅពេលដែលស្ត្រីខ្វះកម្មសិទ្ធិកាន់កាប់ដីធ្លី ពួកគេប្រឈមមុខនឹងភាពមិនច្បាស់លាស់ខាងផ្នែកសេដ្ឋកិច្ច អំពើហិង្សា និងចំណាកស្រុក ដែលបង្កើនលទ្ធភាពនៃចលាចលក្នុងសង្គមនិងភាពតានតឹងអន្តរសហគមន៍។ តាមរយៈការវិភាគផ្នែកច្បាប់ របាយការណ៍សិទ្ធិមនុស្សនិងយុទ្ធនាការតស៊ូមតិ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ធ្វើការដើម្បីធានាថា គោលនយោបាយដីធ្លីដែលគិតគូរពីយេនឌ័រ ត្រូវបានផ្តល់អាទិភាពនៅក្នុងក្របខ័ណ្ឌអភិបាលកិច្ចថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ចំណុចស្នូលនៃការងាររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គឺការទប់ស្កាត់ និងការការពារ (ដោយបង្កើនទទួលខុសត្រូវនៃតួអង្គរដ្ឋ ក្រុមហ៊ុនឯកជន និងម្ចាស់ដីដែលមានអំណាច)។ ការតស៊ូមតិរបស់ពួកគេ មានគោលបំណងកាត់បន្ថយនិទណ្ឌភាពចំពោះការទន្ទ្រានយកដី និងបង្កើតគំរូផ្លូវច្បាប់ ដែលការពារសិទ្ធិដីធ្លីរបស់ស្ត្រីក្នុងរយៈពេលយូរអង្វែង។ ដោយធានាថា ស្ត្រីអាចកាន់កាប់ ទទួលមរតក និងការពារដីធ្លី មិនត្រឹមតែធ្វើឱ្យសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេបានប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយទប់ស្កាត់ជម្លោះដែលអូសបន្លាយ និងអស្ថិរភាព ជាពិសេសនៅក្នុងបរិបទដែលពួកគេប្រឈមនឹងភាពងាយរងគ្រោះបែបរចនាសម្ព័ន្ធផងដែរ។

អ្នកអាចអានរបាយការណ៍ពេញនៅទីនេះ៖ https://www.cchrcambodia.org/en/publications/general-reports/116

### ការពង្រឹងភាពអង់អាចសហគមន៍៖ អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)

អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ បានផ្តោតលើការផ្តល់សិទ្ធិអំណាចដល់សហគមន៍តាមរយៈការអប់រំនិងការកសាងសមត្ថភាពមូលដ្ឋាន ក្នុងគោលបំណងទប់ស្កាត់ទំនាស់ដីធ្លី មុនពេលវាកើតឡើងឬកើនឡើង។ អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ គាំទ្រគំនិតផ្តួចផ្តើមដែលដឹកនាំដោយសហគមន៍ក្នុងការពង្រឹងសន្តិសុខកម្មសិទ្ធិកាន់កាប់ដីធ្លីសម្រាប់ស្ត្រី និងក្រុមបាត់បង់ឱកាសដោយផ្តល់ការអប់រំផ្នែកច្បាប់ ការបណ្តុះបណ្តាលស្តីពីសិទ្ធិដីធ្លី និងគំនិតផ្តួចផ្តើមផ្សេងទៀតក្នុងការអភិវឌ្ឍនៅមូលដ្ឋាន ដូចជា ក្រុមសន្សំប្រាក់និងគម្រោងកសិកម្មជាដើម។

កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសហគមន៍របស់ពួកគេ ជាវេទិកាសម្រាប់សមាជិកសហគមន៍ រួមទាំងស្ត្រីនិងជនជាតិដើមភាគតិចផងដែរ ក្នុងការចែករំលែកព័ត៌មាន បង្ហាញពីកង្វល់ និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិដីធ្លី និងបញ្ហាពាក់ព័ន្ធ។ អង្គការអភិវឌ្ឍន៍សំលេង សហគមន៍ ក៏មានគោលបំណងធានាថា សមាជិកសហគមន៍បានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងដីធ្លី ដើម្បីលើកកម្ពស់សមធម៌និងតម្លាភាពក្នុងការគ្រប់គ្រង។

ទោះបីជាមានកិច្ចការជាច្រើនត្រូវធ្វើក៏ដោយ ក៏អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ធ្វើការដើម្បីទប់ស្កាត់ទំនាស់ដីធ្លីនៅកម្ពុជា ដោយផ្តល់ភាពអង់អាចដល់សហគមន៍ជាមួយនឹងឧបករណ៍ចំណេះដឹងនិងវេទិកាដែលចាំបាច់ ដើម្បីគ្រប់គ្រងធនធានរបស់ពួកគេប្រកបដោយចីរភាព និងតស៊ូមតិសម្រាប់សិទ្ធិរបស់ពួកគេប្រកបដោយប្រសិទ្ធភាព។

អ្នកអាចអានរបាយការណ៍ពេញនៅទីនេះ៖
https://bcv-cambodia.org/what-we-do-en/

៣.២.២.

**សសរស្តម្ភទី ២**

**ការការពារ**

## ការធានាសុវត្ថិភាព ការទទួលបានយុត្តិធម៌ និងសិទ្ធិសម្រាប់ជនងាយរងគ្រោះបំផុត

ការការពារ គឺជាសសរស្តម្ភស្នូលស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដោយផ្តោតលើការទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សា ធានាការទទួលបានយុត្តិធម៌ និងការការពារសិទ្ធិរបស់ស្ត្រី និងក្រុមងាយរងគ្រោះ។

នៅប្រទេសកម្ពុជា ចំណុចនេះរួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែងដើម្បីការពារអ្នកដែលប្រឈមមុខនឹងអំពើហិង្សាយេនឌ័រ ការជួញដូរ និងឧក្រិដ្ឋកម្ម ដើម្បីធានាថាជនរងគ្រោះបានទទួលការគាំទ្រដែលពួកគេត្រូវការ។

ឧទាហរណ៍៖

- **អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)** ផ្តល់ទីជម្រក ប្រឹក្សាផ្នែកច្បាប់ និងគាំទ្រការធ្វើសមាហរណកម្មដល់ជនរងគ្រោះពីគ្រប់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ។

- **អង្គការបន្ទាយស្រី**គាំទ្រដល់សុវត្ថិភាពរបស់ស្ត្រីតាមរយៈការងារសហគមន៍ កិច្ចការពារជនរងគ្រោះ និងការតស៊ូមតិដើម្បីយុត្តិធម៌ និងសិទ្ធិរបស់ជនរងគ្រោះ (សូមមើលករណីសិក្សា)។

- **គំនិតផ្តួចផ្តើមប្រឆាំងការជួញដូរ** ធ្វើការដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចលើស្ត្រីនិងក្មេងស្រី ដោះស្រាយការជួញដូរឆ្លងដែន និងពលកម្មដោយបង្ខំ។

ខណៈដែលមានការរីកចម្រើនឆ្ពោះទៅរកការពង្រឹងកិច្ចការពារជនរងគ្រោះពីអំពើហិង្សាយេនឌ័រ ការកែលម្អការអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងករណីវិវាទគ្រួសារ នៅតែមានសារៈសំខាន់យ៉ាងខ្លាំង។

ក្នុងការអនុវត្តជាក់ស្តែង ករណីអំពើហិង្សាដៃគូស្និទ្ធស្នាល ជារឿយៗនៅតែត្រូវបានដោះស្រាយដោយការសម្រុះសម្រួលជំនួសឱ្យការដោះស្រាយតាមផ្លូវតុលាការ ដែលបង្កើនហានិភ័យដល់ជនរងគ្រោះ។

ការពង្រឹងប្រព័ន្ធត្រួតពិនិត្យបឋមនិងបញ្ជូនបន្ត គឺ មានភាពចាំបាច់ណាស់ ដើម្បីធានាថា ករណីពាក់ព័ន្ធនឹងអំពើហិង្សានឹងត្រូវកំណត់អត្តសញ្ញាណបានត្រឹមត្រូវនិងបញ្ជូនបន្តទៅរកសេវាផ្នែកច្បាប់ និងផ្តល់ជំនួយចាំបាច់។ ការណ៍នេះ គឺដើម្បីការពារជនរងគ្រោះ កុំឱ្យរងគ្រោះម្តងទៀត និងរក្សាសិទ្ធិរស់រានមានជីវិតរបស់ពួកគេ។

យន្តកិច្ចការពាររបស់កម្ពុជាកំពុងរីកចម្រើនបណ្តើរៗទៅរកគោលវិធីដែលចាត់ទុកជនរងគ្រោះជាចម្បង និងផ្អែកលើសិទ្ធិ។ យ៉ាងណាមិញ បញ្ហាប្រឈមនៅតែមាន ក្នុងការធានាសិទ្ធិទទួលបានយុត្តិធម៌តាមផ្លូវតុលាការ ទប់ស្កាត់ការក្លាយជាជនរងគ្រោះម្តងទៀត និង ដោះស្រាយការគំរាមកំហែងប្រភេទថ្មីដែលកំពុងកើតមាន ដូចជា ការកេងប្រវ័ញ្ចតាមអ៊ីនធឺណិត និងប្រតិបត្តិការឆបោកតាមអ៊ីនធឺណិតជាដើម។

**កិច្ចការពារអំពើហិង្សាផ្អែកលើយេនឌ័រ**

**កិច្ចការពារពលករចំណាកស្រុក និងការជួញដូរ**

**តើអ្នកអាចឱ្យឧទាហរណ៍ផ្សេងទៀតទាក់ទងនឹងសសរស្តម្ភការពារនេះក្នុងបរិបទកម្ពុជា?**

# កិច្ចការពារអំពើហិង្សាផ្អែកលើយេនឌ័រ

អំពើហិង្សាផ្អែកលើយេនឌ័រ នៅតែជាការគំរាមកំហែងសន្តិសុខមនុស្សយ៉ាងរាលដាលបំផុតដែលស្ត្រីខ្មែរកំពុងប្រឈមមុខ ជាពិសេសស្ត្រីមកពីសហគមន៍ងាយរងគ្រោះ។

ទោះបីមានការអនុម័តជាបន្តបន្ទាប់នូវផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW) ដោយទទួលបានការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ឧបសគ្គជាប្រព័ន្ធនៅបន្តមាន ជាពិសេសការទទួលបានយុត្តិធម៌ កិច្ចការពារ និងការគាំទ្រដែលផ្តោតលើជនរងគ្រោះនៅមានកម្រិត។

អំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា បន្តបង្ហាញក្នុងទម្រង់ផ្សេងៗគ្នា រួមមាន អំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ការជួញដូរ និងការបៀតបៀននៅកន្លែងធ្វើការ។

ស្ត្រីមកពីជនបទ ជនជាតិភាគតិច ជនជាតិដើមភាគតិច សហគមន៍ស្រលាញ់ភេទដូចគ្នា និងជនមានពិការភាព ប្រឈមមុខនឹងការកើនឡើងនៃភាពងាយរងគ្រោះ ដែលជារឿយៗមានការលំបាកទទួលបានសេវាផ្លូវច្បាប់និងផ្លូវចិត្ត។

ករណីជាច្រើនមិនត្រូវបានគេរាយការណ៍ ដោយសារតែភាពអាម៉ាស់សង្គម ការពឹងផ្អែកផ្នែកសេដ្ឋកិច្ច និងការភ័យខ្លាចចំពោះការសងសឹក ខណៈជនរងគ្រោះដែលស្វែងរកយុត្តិធម៌ ជាញឹកញាប់ជួបប្រទះអាកប្បកិរិយារើសអើង និងឧបសគ្គផ្នែកការិយាល័យធិបតេយ្យក្នុងប្រព័ន្ធច្បាប់។[៨០]

លើសពីនេះ គម្លាតក្នុងការផ្តល់សេវាកិច្ចការពារ ជាពិសេសនៅតាមទីជនបទ ធ្វើឱ្យជនរងគ្រោះភាគច្រើនជាស្ត្រីខ្វះទីជម្រកសុវត្ថិភាព ឬជំនួយផ្លូវច្បាប់។

ខណៈដែលផែនការសកម្មភាពថ្នាក់ជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានពង្រឹងក្របខ័ណ្ឌគោលនយោបាយ ប្រសិទ្ធភាពរបស់វានៅតែពឹងផ្អែកលើការវិនិយោគជាបន្តបន្ទាប់ទៅលើ ការផ្តល់សេវាកម្មដែលចាត់ទុកជនរងគ្រោះជាចម្បង ការឆ្លើយតបនិងការអនុវត្តច្បាប់ឱ្យបានតឹងរឹង និងការខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិល (សូមអានករណីសិក្សាខាងក្រោម) ដើម្បីគាំទ្រជនរងគ្រោះ និងកែប្រែបទដ្ឋានវប្បធម៌ ដែលបន្តឱ្យកើតមានអំពើហិង្សាលើយេនឌ័រ។

# ករណីសិក្សាអំពីការអនុវត្តល្អៗ៖

## ការផ្តល់កិច្ចការពារប្រកបដោយការឆ្លើយតបយេនឌ័រ និងបរិយាបន្នពិការភាពដល់ជនរងគ្រោះនៃអំពើហិង្សាលើយេនឌ័រ

### អង្គការបន្ទាយស្រី

ស្ត្រីនិងក្មេងស្រីមានពិការភាពនៅកម្ពុជាប្រឈមនឹងហានិភ័យខ្ពស់នៃអំពើហិង្សា រួមទាំង ការរំលោភបំពានពីគ្រួសារ និងការរំលោភបំពានផ្លូវភេទ។ នៅឆ្នាំ២០២២ អង្គការបន្ទាយស្រី បានផ្តល់សេវាដល់ស្ត្រីមានពិការភាពចំនួនប្រាំពីរនាក់ តាមរយៈកម្មវិធីផ្ទះសុវត្ថិភាព ក្នុងចំណោមស្ត្រីសរុប១៥៨នាក់ដែលបានទទួលសេវានេះ៨១។ ករណីទាំងនេះ រួមមាន អំពើហិង្សាក្នុងទម្រង់ផ្សេងៗទាំងផ្លូវកាយ និងផ្លូវចិត្ត។

បន្ទាយស្រី ជាអង្គការក្នុងស្រុកដែលបង្កើតឡើងដោយផ្តោតលើការផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់ជនរងគ្រោះនៃអំពើហិង្សាលើយេនឌ័រ រួមទាំងការប្រឹក្សា និងការផ្តល់ជំនួយក្នុងដំណើរការតុលាការ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីមានពិការភាពតែងតែជួបប្រទះនឹងឧបសគ្គសំខាន់ៗជាច្រើននៅពេលស្វែងរកយុត្តិធម៌។ ការស្វះស្វែងដំបូងដើម្បីទទួលបានជំនួយពីអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ តែងទទួលបានការឆ្លើយតបមិនស្មើភាពគ្នា ដោយខ្លះចង់ឱ្យមានការដោះស្រាយក្រៅប្រព័ន្ធជាជាងមានវិធានការផ្លូវច្បាប់។

បញ្ហាប្រឈមសម្រាប់ស្ត្រីរងគ្រោះដែលមានពិការភាព ដូចជា ការលំបាកក្នុងការទំនាក់ទំនង ការយល់ដឹងនៅមានកម្រិតលើនីតិវិធីច្បាប់ និងឧបសគ្គផ្នែកហិរញ្ញវត្ថុ ជាកត្តាបន្ថែមទៀតដែលរារាំងដល់សិទ្ធិទទួលបានយុត្តិធម៌របស់ពួកគេ។ អង្គការបន្ទាយស្រីបានពន្យល់ថា ការយល់ឃើញអវិជ្ជមានពីសង្គម ក៏រួមចំណែកដល់ភាពងាយរងគ្រោះរបស់ពួកគេផងដែរ ហើយអាជ្ញាធរមូលដ្ឋាន ជារឿយៗខ្វះការយល់ដឹង ឬមិនមានឆន្ទៈគ្រប់គ្រាន់ក្នុងការគាំទ្រពួកគេប្រកបដោយប្រសិទ្ធភាព។

នៅពេលធ្វើការដើម្បីការពារប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ ជាការសំខាន់ណាស់ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រដែលតម្រូវឱ្យមានចូលរួមយ៉ាងសកម្មពីស្ត្រី និងការគាំទ្រស្ត្រី និងក្មេងស្រីដែលមានពិការភាព។ ការងាររបស់អង្គការបន្ទាយស្រី ជាឧទាហរណ៍ពីការអនុវត្តដ៏ល្អនៅក្នុងសសរស្តម្ភការពារ ដោយផ្តល់ការគាំទ្រដល់ក្រុមងាយរងគ្រោះជាស្ត្រីរងអំពើហិង្សាលើយេនឌ័រ។

អ្នកអាចអានបន្ថែមអំពីការងាររបស់អង្គការបន្ទាយស្រី ក្នុងកិច្ចការពារ និងជម្រុញសិទ្ធិស្ត្រី នៅទីនេះ៖ https://banteaysrei.info/

# ស្ត្រីពលករចំណាកស្រុក៖ បញ្ហាប្រឈមក្នុងកិច្ចការពារនិងហានិភ័យ

ការធ្វើចំណាកស្រុកដើម្បីរកការងារ បានក្លាយជាកត្តាចាំបាច់ក្នុងការចិញ្ចឹមជីវិតសម្រាប់ស្ត្រីកម្ពុជាជាច្រើន ជាពិសេស អ្នកមកពីជនបទ និងមានផលលំបាកខាងផ្នែកសេដ្ឋកិច្ច។

ស្ត្រីខ្មែររាប់ពាន់នាក់ធ្វើចំណាកស្រុកជារៀងរាល់ឆ្នាំ ដើម្បីធ្វើការងារបម្រើតាមផ្ទះ រោងចក្រ កសិកម្ម និងសំណង់នៅប្រទេសជាច្រើន ដូចជាប្រទេសថៃ និងម៉ាឡេស៊ី។ យ៉ាងណាមិញ ការធ្វើចំណាកស្រុករបស់ពួកគេជាទូទៅមិនមានការការពារ មិនផ្លូវការ និងងាយរងគ្រោះជាខ្លាំងពីការកេងប្រវ័ញ្ច។

ពលករចំណាកស្រុកជាស្ត្រីប្រឈមនឹងហានិភ័យសន្តិសុខជាច្រើនប្រភេទ ដូចជា៖

- ការរំលោភសិទ្ធិការងារ៖ ស្ត្រីជាច្រើនធ្វើការក្នុងស្ថានភាពមិនមានសុវត្ថិភាពនិងកេងប្រវ័ញ្ច ដោយទទួលបានប្រាក់ឈ្នួលទាប ម៉ោងធ្វើការច្រើនហួសហេតុ និងគ្មានការការពារផ្លូវច្បាប់។ ជាពិសេស ពលករបម្រើការងារតាមផ្ទះនៅតែមិនរាប់បញ្ចូលក្នុងច្បាប់ការងារជាផ្លូវការ ដែលធ្វើឱ្យពួកគេងាយរងការរំលោភបំពាន។

- អំពើហិង្សាលើយេនឌ័រ៖ ស្ត្រីដែលធ្វើការតាមផ្ទះជាឯកជន ឬនៅកន្លែងដែលដាច់ដោយឡែកពីគេមានហានិភ័យខ្ពស់ក្នុងការទទួលរងការបៀតបៀនផ្លូវភេទ ការរំលោភបំពានលើរាងកាយ និងពលកម្មដោយបង្ខំ។

- ការជាប់បំណុលនិងពលកម្មដោយបង្ខំ៖ កម្រៃក្នុងការជ្រើសរើសពលករនិងការអនុវត្តប្រាក់កម្ចីបែបកេងប្រវ័ញ្ចជាអន្ទាក់នៃវដ្តបំណុលសម្រាប់ស្ត្រីចំណាកស្រុក ដែលធ្វើឱ្យពួកគេពិបាកចាកចេញពីស្ថានភាពការងារដែលត្រូវបានកេងប្រវ័ញ្ច។ ស្ត្រីជាច្រើនបានបង្ខិតបង្ខំឱ្យធ្វើការដើម្បីសងបំណុលទៅមេខ្យល់និងភ្នាក់ងារផ្សេងៗ។[៨២]

- ការជួញដូរមនុស្សនិងការរត់ពន្ធមនុស្ស៖ កង្វះការតម្រង់ទិសក្នុងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ធ្វើឱ្យមានការកើនឡើងនូវលទ្ធភាពដែលស្ត្រីកម្ពុជាត្រូវបានជួញដូរតាមរយៈគម្រោងជ្រើសរើសបុគ្គលិកបោកប្រាស់ ធ្វើឱ្យមានការកេងប្រវ័ញ្ចការងារ ឬកាន់តែធ្ងន់ធ្ងរ គឺឧក្រិដ្ឋកម្មដោយបង្ខំ។

រដ្ឋាភិបាលកម្ពុជាមានវិធានការមួយចំនួនដើម្បីដោះស្រាយហានិភ័យទាំងនេះ រួមមាន ការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា (MoUs) ជាមួយបណ្តាប្រទេសគោលដៅ [៨៣]។ តែទោះជាយ៉ាងណាគម្លាតនៅតែមាននៅក្នុងការអនុវត្តជាក់ស្តែង និងយន្តការការពារ ជាពិសេសសម្រាប់ពលករដែលមិនមានឯកសារផ្លូវច្បាប់។

តួនាទីរបស់អង្គការធ្វើលើសិទ្ធិការងារ (សូមមើលករណីសិក្សា) មានសារៈសំខាន់ក្នុងការបំពេញនូវគម្លាតទាំងនេះ ដើម្បីធានាថាពលករចំណាកស្រុកជាស្ត្រីអាចទទួលបានការគាំទ្រ យុត្តិធម៌ និងយន្តការដោះស្រាយ។

# ករណីសិក្សាការអនុវត្តល្អៗ៖

## កិច្ចការពារស្ត្រីពលករចំណាកស្រុកដែលងាយរងគ្រោះ

### មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (CENTRAL) គឺជាអង្គការតស៊ូមតិឈានមុខគេមួយធ្វើការលើការការពារសិទ្ធិពលករចំណាកស្រុកស្ត្រីកម្ពុជា ដើម្បីដោះស្រាយភាពងាយរងគ្រោះជាប្រព័ន្ធ ដែលនាំឱ្យប្រឈមនឹងការកេងប្រវ័ញ្ចនិងការរំលោភបំពាន។ តាមរយៈកម្មវិធីជំនួយផ្នែកច្បាប់ ការតស៊ូមតិផ្នែកគោលនយោបាយ និងការផ្តល់សិទ្ធិអំណាចដល់កម្មករ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ពង្រឹងការការពារសម្រាប់ស្ត្រីដែលធ្វើចំណាកស្រុកទៅធ្វើការក្រៅប្រទេស ជាពិសេស ទៅប្រទេសថៃនិងម៉ាឡេស៊ី។

អន្តរាគមន៍ស្នូលមួយរបស់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស គឺការផ្តល់ជំនួយផ្នែកច្បាប់ ដោយផ្ទាល់ដល់ពលករចំណាកស្រុកដែលរងគ្រោះពីការលួចប្រាក់ឈ្នួល ការបណ្តេញចេញដោយខុសច្បាប់ ឬអំពើហិង្សាយេនឌ័រ។ ស្ត្រីខ្មែរជាច្រើនធ្វើចំណាកស្រុកតាមរយៈបណ្តាញក្រៅផ្លូវការ ដោយគ្មានកិច្ចសន្យាឬការការពារផ្លូវច្បាប់ឡើយ។ ពេលមានករណីកេងប្រវ័ញ្ចកើតឡើង ពួកគេជាទូទៅមានលទ្ធភាពតិចតួចប៉ុណ្ណោះ ក្នុងការទាមទារសិទ្ធិរបស់ខ្លួន។ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ធ្វើការជាមួយស្ត្រីរងគ្រោះ ដើម្បីដាក់ពាក្យបណ្តឹង ទាមទារសំណង ហើយក្នុងករណីខ្លះចរចាដោយផ្ទាល់ជាមួយនិយោជក ឬភ្នាក់ងារជ្រើសរើសបុគ្គលិក ដើម្បីបានទទួលប្រាក់ឈ្នួលដែលមិនទាន់បានទទួលសំណងស្របច្បាប់។

លើសពីការគាំទ្រផ្នែកច្បាប់ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស គឺជាសំឡេងដ៏សំខាន់ក្នុងការតស៊ូមតិផ្នែកគោលនយោបាយ ដោយជំរុញឱ្យមានការការពារកាន់តែខ្លាំងនៅក្នុងកិច្ចព្រមព្រៀងរបស់កម្ពុជាជាមួយប្រទេសទទួលពលករ។ អង្គការនេះបានចូលរួមយ៉ាងសកម្មជាមួយអ្នកបង្កើតគោលនយោបាយក្នុងការទាមទារលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ដោយធានាថា ស្ត្រីកម្ពុជាត្រូវបានការពារដោយច្បាប់ការងារពាក់ព័ន្ធ ហើយថ្លៃសេវាក្នុងការជ្រើសរើសដោយកេងប្រវ័ញ្ច (ដែលជារឿយៗជំរុញឱ្យកម្មករចំណាកស្រុកធ្លាក់ចូលទៅក្នុងបំណុល) ត្រូវបានលុបចោល។

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ក៏ផ្តោតលើការងារបង្ការទប់ស្កាត់ផងដែរ ដោយផ្តល់ជាវគ្គបណ្តុះបណ្តាលមុនចេញដំណើរ ដើម្បីអប់រំស្ត្រីអំពីសិទ្ធិរបស់ពួកគេ ការការពារផ្លូវច្បាប់ និងរបៀបរាយការណ៍អំពីការរំលោភបំពាន។ ពួកគេក៏គាំទ្រពលករចំណាកស្រុកដែលត្រឡប់មកវិញផងដែរ ដោយជួយពួកគេឱ្យធ្វើសមាហរណកម្មឡើងវិញ និងចៀសវាងការកេងប្រវ័ញ្ចម្តងទៀត។

មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស អាចត្រូវគេមើលឃើញថា ជាអង្គភាពពង្រឹងសសរស្តម្ភការការពារ ស្តីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ដោយរួមបញ្ចូលកិច្ចការពារដែលគិតគូរពីយេនឌ័រទៅក្នុងគោលនយោបាយចំណាកស្រុក ដោយធានានូវសន្តិសុខសេដ្ឋកិច្ច និងសិទ្ធិមនុស្ស សម្រាប់ពលករចំណាកស្រុកជាស្ត្រី។ ការងាររបស់ពួកគេគូសបញ្ជាក់ពីតម្រូវការកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល សហជីព និងសង្គមស៊ីវិល ដើម្បីធ្វើឱ្យការចំណាកស្រុកក្លាយជាវិថីឆ្ពោះទៅរកឱកាសជាជាងការកេងប្រវ័ញ្ច។

# ៣.២.៣.

## សសរស្តម្ភទី

# ការសង្គ្រោះ និងការស្តារឡើងវិញ

កិច្ចខិតខំប្រឹងប្រែងសង្គ្រោះនិងការស្តារឡើងវិញមានភាពចាំបាច់ ដើម្បីធានាថា វិបត្តិ មិនថាបណ្តាលមកពីជម្លោះ គ្រោះមហន្តរាយ ឬ អស្ថិរភាពនយោបាយ មិនបន្តឱ្យមានវិសមភាពយេនឌ័រតទៅទៀត។

សសរស្តម្ភនៃការសង្គ្រោះនិងការស្តារឡើងវិញស្តីពីរបៀបវារៈស្ត្រី សន្តិភាពនិងសន្តិសុខ ផ្តោតលើការផ្តល់ការជំនួយមនុស្សធម៌ដែលឆ្លើយតបនឹងយេនឌ័រនិងប្រកបដោយបរិយាបន្ន ដោយការកសាងសហគមន៍ឡើងវិញ និងធានាថាការខិតខំប្រឹងប្រែងស្តារឡើងវិញ នឹងដោះស្រាយនូវតម្រូវការរបស់ស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះដទៃទៀត រួមទាំងបុគ្គលស្រឡាញ់ភេទដូចគ្នា និងជនមានពិការភាព។

នៅកម្ពុជា កិច្ចខិតខំប្រឹងប្រែងសង្គ្រោះនិងស្តារឡើងវិញ មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ដែលបណ្តាលមកពីអាកាសធាតុ ការកាន់កាប់ដីដោយខុសច្បាប់ និងការកសាងឡើងវិញក្រោយជម្លោះ។ កម្ពុជាប្រឈមនឹងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតជាញឹកញាប់ ដែលជះឥទ្ធិពលមិនសមាមាត្រគ្នាដល់ស្ត្រី ជាពិសេសស្ត្រីនៅជនបទនិងសហគមន៍ជនជាតិដើមភាគតិច ដែលរាំងស្ទះដល់ជីវភាពរស់នៅ ការកើនឡើងហានិភ័យនៃអំពើហិង្សាលើយេនឌ័រ និងការទទួលបានសេវាសំខាន់ៗនៅមានកម្រិត។

លើសពីនេះទៀត ការបណ្តេញចេញពីដីធ្លីលក្ខណៈទ្រង់ទ្រាយធំ និងការផ្ទេរសម្បទានដីសេដ្ឋកិច្ច បាននាំឱ្យមានករណីជម្លៀសដោយបង្ខំ ជាពិសេសប៉ះពាល់ដល់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ កម្មករក្រៅប្រព័ន្ធ និងអ្នកដែលមានលំនៅឋានមិនច្បាស់លាស់។

ជាមួយនឹងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ និងគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាល ដែលទទួលស្គាល់បទពិសោធន៍ចម្រុះរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយជម្លោះ វាបានបង្ហាញឱ្យឃើញថា មានការកើនឡើងនៃការទទួលស្គាល់កាន់តែច្រើនស្តីពីសារៈសំខាន់នៃសំឡេងនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្រុមងាយរងគ្រោះមកពីគ្រប់មជ្ឈដ្ឋាន ទៅក្នុងដំណើរការនៃការស្តារឡើងវិញ។

***កម្ពុជាប្រឈមមុខនឹងការកើនឡើងហានិភ័យ ពីគ្រោះមហន្តរាយនៃការប្រែប្រួលអាកាសធាតុ រួមមាន ទឹកជំនន់ និងគ្រោះរាំងស្ងួត ក៏ដូចជាផលប៉ះពាល់ជាបន្តបន្ទាប់នៃជម្លោះពីអតីតកាល។ ការណ៍នេះ ជាការចាំបាច់ក្នុងការដាក់បញ្ចូលនូវកម្មវិធីនិងគោលនយោបាយ ដែលគិតគូរពីយេនឌ័រទៅក្នុងការឆ្លើយតបលើការងារមនុស្សធម៌ ការកសាងសន្តិភាព និងកិច្ចខិតខំប្រឹងប្រែងក្នុងការស្តារឡើងវិញ។***

ការកាត់បន្ថយហានិភ័យ
គ្រោះមហន្តរាយដែលមាន
លក្ខណៈឆ្លើយតបនឹងយេនឌ័រ។

យុត្តិធម៌អន្តរកាលដែល
ឆ្លើយតបនឹងយេនឌ័រ។

**តើមានឧទាហរណ៍អ្វីផ្សេងទៀតដែលអ្នកដឹង
ទាក់ទងនឹងសសរស្តម្ភការសង្គ្រោះនិងការ
ស្តារឡើងវិញក្នុងបរិបទកម្ពុជា?**

# ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ

នៅកម្ពុជា ការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយមានផលប៉ះពាល់លើស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះមិនស្មើគ្នាទេ ដែលធ្វើឱ្យវិសមភាពដែលមានស្រាប់កាន់តែធ្ងន់ធ្ងរ និងគំរាមកំហែងដល់សិទ្ធិមនុស្សជាមូលដ្ឋាន។

បញ្ហាអាកាសធាតុចម្បងៗ រួមមាន ទឹកជំនន់ គ្រោះរាំងស្ងួត និងព្យុះទីហ្វុង មានផលប៉ះពាល់បំផ្លិចបំផ្លាញ ដល់ជីវភាពរស់នៅ សន្តិសុខស្បៀង និងការទៅទទួលសេវាសំខាន់ៗមួយចំនួន។ វិបត្តិទាំងនេះធ្វើឱ្យមានការកើនឡើងនូវភាពងាយរងគ្រោះរបស់ស្ត្រី ចំពោះអសន្តិសុខសេដ្ឋកិច្ច អំពើហិង្សាយេនឌ័រ និងឧបសគ្គក្នុងការសម្រេចចិត្តលើកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ។

## សិទ្ធិទទួលបានការការពារនិងភាពធន់

ស្ត្រីមានសិទ្ធិទទួលបានការការពារពីហានិភ័យទាក់ទងនឹងអាកាសធាតុ ហើយពួកគេគួរត្រូវបានដាក់បញ្ចូលក្នុងការត្រៀមលក្ខណៈ និងការឆ្លើយតបគ្រោះមហន្តរាយ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយ កាត់បន្ថយហានិភ័យគ្រោះមហន្តរាយរបស់កម្ពុជា និងយុទ្ធសាស្ត្របន្សាំអាកាសធាតុអាចមិនផ្តល់អាទិភាពលើវិធីសាស្ត្រដែលឆ្លើយតបយេនឌ័រ។ ការផាត់ស្ត្រីចេញពីផែនការឆ្លើយតបគ្រោះមហន្តរាយ ការសម្រេចចិត្តលើផែនការប្រើប្រាស់ដីធ្លី និងកម្មវិធីសម្របខ្លួនទៅនឹងអាកាសធាតុកម្រិតនូវសមត្ថភាពរបស់ពួកគេក្នុងការជះឥទ្ធិពលលើគោលនយោបាយ ដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ។

## សិទ្ធិចូលរួមការសម្រេចចិត្ត

ទោះបីជាទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ស្ត្រីនៅតែមានភាពជាតំណាងតិចតួចនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ។ ការចូលរួមដ៏មានអត្ថន័យនៅក្នុងគណៈកម្មាធិការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមូលដ្ឋាន យុទ្ធសាស្ត្របន្សាំនឹងអាកាសធាតុ និងកម្មវិធីស្តារឡើងវិញ មានភាពចាំបាច់ដើម្បីធានាថា ការឆ្លើយតបផ្តល់អាទិភាពដល់តម្រូវការយេនឌ័រជាក់លាក់ ហើយពឹងផ្អែកលើចំណេះដឹងនៅមូលដ្ឋាន។ គំនិតផ្តួចផ្តើមកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដែលដឹកនាំដោយស្ត្រីនៅប្រទេសកម្ពុជាបង្ហាញពីឥទ្ធិពលស្ត្រីនិងក្រុមងាយរងគ្រោះក្នុងការបង្កើនភាពធន់របស់សហគមន៍និងការស្តារឡើងវិញប្រកបដោយនិរន្តរភាព។

## សិទ្ធិចិញ្ចឹមជីវិតនិងសន្តិសុខសេដ្ឋកិច្ច

គ្រោះមហន្តរាយបង្កឡើងដោយអាកាសធាតុ ធ្វើឱ្យមានការរំខានដល់ស្ត្រីក្នុងការអាស្រ័យផលលើដីធ្លី ទឹក និងឱកាសសេដ្ឋកិច្ច ដែលនេះកាន់តែធ្វើឱ្យមានភាពក្រីក្រ និងបន្ថកម្រិតសមត្ថភាពរបស់ស្ត្រីក្នុងការស្តារឡើងវិញ។ ជាពិសេស ស្ត្រីនៅជនបទ កសិករខ្នាតតូច និងសហគមន៍ជនជាតិដើមភាគតិច ប្រឈមនឹងការរឹបអូសដីធ្លី និងការគាំទ្រលើការបន្សាំអាកាសធាតុមិនគ្រប់គ្រាន់ធ្វើឱ្យការស្តារសេដ្ឋកិច្ចមានការលំបាក។ ការធានាឱ្យមានគោលនយោបាយសម្របខ្លួនដែលមានលក្ខណៈឆ្លើយតបយេនឌ័រ ការទទួលបានធនធានហិរញ្ញវត្ថុ និងកម្មវិធីកសាងសមត្ថភាពនិងជំនាញ មានសារៈសំខាន់សម្រាប់ការលើកកម្ពស់យុត្តិធម៌អាកាសធាតុ។

# ករណីសិក្សាពីការអនុវត្តល្អៗ៖

## កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយដែលដឹកនាំដោយស្ត្រី

### អង្គការអាក់សិនអេតកម្ពុជា (ActionAid Cambodia) និង មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា (CWDCC)

គម្រោង ជម្រើសជំនួសដែលដឹកនាំដោយស្ត្រីស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា (WLACC) ជាគំរូដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងអង្គការអាក់សិនអេតកម្ពុជា (ActionAid Cambodia) និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា (CWDCC) ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីស្តីពីភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ គម្រោងនេះបានដាក់ឱ្យដំណើរការនៅខែមេសា ឆ្នាំ២០២២ ដោយដាក់ឱ្យដំណើរការនៅខេត្តកំពត កោះកុង កំពង់ធំ និងពោធិ៍សាត់ [៩៤]។

ចំណុចសំខាន់មួយនៃគំនិតផ្តួចផ្តើមគម្រោងនេះ គឺការបង្កើតបណ្តាញជើងឯកស្ត្រី (WCN)។ បណ្តាញនេះផ្តល់អំណាចដល់ស្ត្រីឱ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន និងដំណើរការនៃការសម្រេចចិត្តទាក់ទងនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយ។ តាមរយៈសិក្ខាសាលាពង្រឹងសមត្ថភាពជើងឯកស្ត្រីបានបណ្តុះបណ្តាលក្នុងការដឹកនាំវាយតម្លៃហានិភ័យ ភាពងាយរងគ្រោះ និងការវាយតម្លៃសមត្ថភាព (HVCAs) បង្កើតជាប្រព័ន្ធព្រមានជាមុន និងការអនុវត្តប្រកបដោយចីរភាព ដូចជាការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព និងកសិកម្មដែលធន់នឹងអាកាសធាតុ។

គម្រោងនេះក៏សង្កត់ធ្ងន់លើសារៈសំខាន់នៃការរួមបញ្ចូលទស្សនៈរបស់ស្ត្រីក្នុងក្របខ័ណ្ឌគោលនយោបាយ។ តាមរយៈការសម្របសម្រួលកិច្ចសន្ទនារវាងអ្នកដឹកនាំស្ត្រីនិងមន្ត្រីរដ្ឋាភិបាលនៅកម្រិតផ្សេងៗ គម្រោងនេះធានាថាស្ត្រីមានសំឡេងនៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយទាក់ទងនឹងអាកាសធាតុ និងគ្រោះមហន្តរាយ។ វិធីសាស្ត្រនេះមិនត្រឹមតែដោះស្រាយភ្លាមៗនូវបញ្ហាប្រឈមរបស់បរិស្ថានទោះទេ ប៉ុន្តែក៏លើកកម្ពស់ផងដែរនូវសមភាពយេនឌ័រ ដោយការទទួលស្គាល់ការរួមចំណែករបស់ស្ត្រីដល់ភាពធន់របស់សហគមន៍។

តាមរយៈភាពជាដៃគូរវាងអង្គការអាក់សិនអេតកម្ពុជា និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា គម្រោងនេះបានបង្ហាញពីប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមដែលដឹកនាំដោយស្ត្រីនិងជម្រុញដោយសហគមន៍ ក្នុងការកសាងសមត្ថភាពសម្របខ្លួន និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅចំពោះមុខការប្រែប្រួលអាកាសធាតុ។

អ្នកអាចអានបន្ថែមអំពីការងាររបស់ Action-Aid Cambodia នៅទីនេះ៖ https://cambodia.actionaid.org/publications/2022/action-aid-cambodia-newsletter-may-2022-1

# យុត្តិធម៌អន្តរកាលដែលឆ្លើយតបនឹងយេនឌ័រ

យុត្តិធម៌អន្តរកាល (TJ) គឺជាយន្តការសំខាន់មួយក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្សពីអតីតកាល លើកកម្ពស់ការផ្សះផ្សា និងធានានិរន្តរភាពនៃសន្តិភាពនិងការស្តារឡើងវិញនៅក្នុងសង្គម ក្រោយជម្លោះ។ កេរ្តិ៍ដំណែលរបបខ្មែរក្រហម បន្តផលវិបាកដល់ប្រទេសកម្ពុជាលើគ្រប់ផ្នែក រួមទាំង នយោបាយ សង្គម និងសេដ្ឋកិច្ច។ យន្តការយុត្តិធម៌អន្តរកាល មានសារៈសំខាន់ណាស់ ក្នុងការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរដល់ជនរងគ្រោះ និងទប់ស្កាត់ការកើតមានឡើងវិញនូវអំពើហិង្សាបែបនេះនាពេលអនាគត។

### ហេតុអ្វីបានជាយន្តការយុត្តិធម៌អន្តរកាលមានសារៈសំខាន់នៅកម្ពុជា?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក ឬ ECCC) គឺជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់មួយក្នុងការស្វែងរកយុត្តិធម៌សម្រាប់អំពើឃោរឃៅក្នុងសម័យខ្មែរក្រហម។ ប៉ុន្តែវិធីសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រនៅមានកម្រិតនៅឡើយ។

ខណៈដែលមានការដោះស្រាយឧក្រិដ្ឋកម្មនៃការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ជនរងគ្រោះជាច្រើន ជាពិសេស ស្ត្រី នៅតែបន្តទទួលនូវការម៉ាក់ងាយពីសង្គម ការប៉ះទង្គិចផ្លូវចិត្ត និងកង្វះការទទួលបានសំណង។ លើសពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម យុត្តិធម៌អន្តរកាលដែលឆ្លើយតបនឹងយេនឌ័រត្រូវតែឆ្ពោះទៅមុខបន្ថែមទៀតដោយទទួលស្គាល់និងដោះស្រាយៈ

- ផលប៉ះពាល់រយៈពេលវែងនៃអំពើហិង្សាលើយេនឌ័របង្កឡើងដោយជម្លោះ រួមទាំងភាពងាយរងគ្រោះផ្នែកសង្គមនិងសេដ្ឋកិច្ចរបស់ជនរងគ្រោះ។
- ផលប៉ះពាល់អន្តរជំនាន់នៃជម្លោះ ជាពិសេស លើគ្រួសារដែលស្ត្រីជាមេគ្រួសារ សហគមន៍ដែលត្រូវបានជម្លៀស និងជនជាតិភាគតិច។
- តម្រូវការសម្រាប់កិច្ចខិតខំប្រឹងប្រែងសហគមន៍ក្នុងការចងចាំនិងនិយាយការពិត ដែលទទួលស្គាល់បទពិសោធន៍ និងការរួមចំណែករបស់ស្ត្រីមកពីគ្រប់អត្តសញ្ញាណក្នុងការកសាងសន្តិភាព។

នៅក្នុងសសរស្តម្ភសង្គ្រោះនិងការស្តារឡើងវិញរបស់ របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ យន្តការយុត្តិធម៌អន្តរកាលដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា កេរ្តិ៍ដំណែលនៃអំពើហិង្សាទាក់ទងនឹងជម្លោះ រួមទាំងអំពើហិង្សាលើយេនឌ័រត្រូវបានដោះស្រាយតាមរយៈការអប់រំ និងការសន្ទនា ដើម្បីការពារមិនឱ្យមានវដ្តនៃអំពើហិង្សានិងការរើសអើងបែបនេះកើតឡើងមានម្តងទៀតនាពេលអនាគត។

ខណៈដែល អ.វ.ត.ក បានតម្រង់ទិសវិថីនេះកន្លងមក ការងារមួយចំនួននៅបន្តមានធ្វើក្នុងការធានាថាយុត្តិធម៌អន្តរកាលរួមចំណែកដល់ការកសាងសន្តិភាពប្រកបដោយបរិយាបន្នយេនឌ័រនិងមានអត្ថន័យសម្រាប់ជនរងគ្រោះគ្រប់រូប។

អង្គការសង្គមស៊ីវិលនៅកម្ពុជាមានសារៈសំខាន់ក្នុងការផ្សាភ្ជាប់ចន្លោះប្រហោងទាំងនេះ តាមរយៈគំនិតផ្តួចផ្តើមដែលដឹកនាំដោយជនរងគ្រោះ ការសន្ទនាអន្តរជំនាន់ និងកម្មវិធីយុត្តិធម៌ដែលជំរុញដោយសហគមន៍ (សូមអានករណីសិក្សា)។

# ករណីសិក្សាពីការអនុវត្តល្អៗ៖

## ការគាំទ្រស្ត្រីដែលរួចរស់មានជីវិតពីអំពើហិង្សា លើយេនឌ័រនៃរបបខ្មែរក្រហម

### អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO)

ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) អំពើហិង្សាយេនឌ័របានរីករាលដាល។ ទោះជាយ៉ាងណាក៏ដោយ វានៅតែមិនបានដោះស្រាយឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ នៅក្នុងដំណើរការយុត្តិធម៌អន្តរកាល។ ជនរងគ្រោះជាពិសេសស្ត្រី ប្រឈមមុខនឹងការរៀបការដោយបង្ខំជាលក្ខណៈប្រព័ន្ធ ការរំលោភនៅក្នុងពន្ធនាគារ និងអំពើហិង្សាផ្លូវភេទប្រព្រឹត្តដោយទាហានខ្មែរក្រហម។ ទោះយ៉ាងណាក៏ដោយ ឧក្រិដ្ឋកម្មទាំងនេះបានទទួលការចាប់អារម្មណ៍តិចតួចពីសាធារណជន កាលពីពេលដែលប្រទេសស្ថិតនៅដំណាក់កាលនៃការស្តារឡើងវិញ។

ជាលទ្ធផល ស្ត្រីរងគ្រោះជាច្រើននាក់បានរស់នៅក្នុងភាពស្ងៀមស្ងាត់អស់ជាច្រើនទសវត្ស ដោយប្រឈមមុខនឹងការមាក់ងាយពីសង្គម ការរបួសផ្លូវចិត្ត និងកង្វះសេវាកម្មគាំទ្រ ឬការទទួលស្គាល់ផ្លូវច្បាប់។ ជាការឆ្លើយតប អង្គការចិត្តសង្គមអន្តរវប្បធម៌ បានអនុវត្តកម្មវិធីជំនួយសុខភាពផ្លូវចិត្ត និងយុត្តិធម៌សហគមន៍ ដើម្បីផ្តល់ការទទួលស្គាល់ការថែទាំផ្លូវចិត្ត និងជំនួយផ្នែកច្បាប់សម្រាប់ស្ត្រីទាំងនេះ។

សកម្មភាពសំខាន់មួយនៃកម្មវិធីនេះ គឺពិធីព្យាបាលតាមបែបសក្ខីកម្ម (Testimonial Therapy) ទៅដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជនរងគ្រោះទទួលបានការលើកទឹកចិត្តឱ្យចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងបែបបទមួយដែលមានការគាំទ្រ។ វគ្គទាំងនេះបានបញ្ចប់ជាមួយនឹងពិធីជាសាធារណៈ ដែលទទួលស្គាល់ជាផ្លូវការនូវការឈឺចាប់នៃការដក់ជាប់អារម្មណ៍របស់ពួកគេ ជំរុញការព្យាបាលផ្លូវចិត្ត និងការទទួលស្គាល់ពីសង្គម។ សម្រាប់មនុស្សជាច្រើន នេះគឺជាលើកដំបូងដែលសំឡេងរបស់ពួកគេត្រូវបានទទួលស្គាល់ ផ្តល់នូវធូរស្បើយចិត្ត និងការពង្រឹងទំនុកចិត្ត។

ដើម្បីគាំទ្របន្ថែមដល់ការស្តារឡើងវិញរបស់ស្ត្រី អង្គការចិត្តសង្គមអន្តរវប្បធម៌ បានផ្តល់សេវាសុខភាពផ្លូវចិត្តនៅទីឯកន្លែងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ស្ត្រីដែលចូលរួមនៅក្នុងដំណើរការផ្លូវច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម បានទទួលការប្រឹក្សាព័ត៌មានពីរបួសផ្លូវចិត្តមុនពេល អំឡុងពេល និងក្រោយពេលផ្តល់សក្ខីកម្ម។

លើសពីនេះ អង្គការចិត្តសង្គមអន្តរវប្បធម៌ បានបណ្តុះបណ្តាលអ្នកជំនាញផ្នែកច្បាប់ និងអ្នកតស៊ូមតិសហគមន៍ ស្តីពីវិធីសាស្ត្រផ្តោតលើជនរងគ្រោះ ដែលធានាថា ស្ត្រីដែលកំពុងស្វែងរកយុត្តិធម៌បានទទួលសេចក្តីថ្លៃថ្នូរ អារម្មណ៍ជឿទុកចិត្ត និងការគាំទ្រសមរម្យ។

ការងាររបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ បានចូលរួមចំណែកដោយផ្ទាល់ដល់សសរស្តម្ភការសង្គ្រោះ និងស្តារឡើងវិញ ដោយធានាថា ស្ត្រីដែលរងផលប៉ះពាល់ដោយអំពើហិង្សាលើយេនឌ័រ បានទទួលយុត្តិធម៌ ការថែទាំ និងស្ថិតលើផ្លូវឆ្ពោះទៅកាន់ភាពជាសះស្បើយ។

អ្នកអាចអានបន្ថែមអំពីការងាររបស់ TPO នៅទីនេះ៖ https://tpocambodia.org/community-mental-health-programs/survivors-and-victims-of-gender-based-violence-under-khmer-rouge-regime/

៣.២.៤.

# សសរស្តម្ភទី ៤

ការចូលរួម

## ការធានាឱ្យបាននូវភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងកិច្ចការសន្តិភាព និងសន្តិសុខ

សសរស្តម្ភការចូលរួម ស្ដីពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ផ្ដោតលើការលើកកម្ពស់តួនាទីស្ត្រីក្នុងការសម្រេចចិត្ត អភិបាលកិច្ច និងដំណើរការសន្តិភាព។

នៅប្រទេសកម្ពុជា ខណៈដែលមានការរីកចម្រើន ស្ត្រីនៅតែមានតំណាងតិចតួចនៅក្នុងតួនាទីជាអ្នកដឹកនាំក្នុងថ្នាក់សម្រេចចិត្តផ្នែកនយោបាយនិងផ្នែកសន្តិសុខ។ ការពង្រឹងការចូលរួមរបស់ស្ត្រី នៅគ្រប់កម្រិត មានសារៈសំខាន់ណាស់ ដើម្បីធានាថា គោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពឆ្លុះបញ្ចាំងនូវទស្សនៈទានចម្រុះនិងតម្រូវការនានា។

- **ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យនយោបាយ** គំនិតផ្តួចផ្តើមគាំទ្រភាពជាតំណាងរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល និងរចនាសម្ព័ន្ធដឹកនាំក្នុងមូលដ្ឋានបានជួយបង្កើនសំឡេងរបស់ស្ត្រីក្នុងការធ្វើគោលនយោបាយ និងការសម្រេចចិត្ត ប៉ុន្តែឧបសគ្គនៅតែមានក្នុងការសម្រេចបាននូវសមភាពយេនឌ័រ។ នៅថ្នាក់មូលដ្ឋាន គោលនយោបាយបានកំណត់ថា យ៉ាងហោចណាស់គួរមានស្ត្រីម្នាក់កាន់តំណែងនៅថ្នាក់ ១. ខេត្ត ក្រុង រាជធានី ស្រុក និងខណ្ឌ ២. ថ្នាក់ឃុំឬសង្កាត់ ជាជនបង្គោលក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ (គ.ក.ន.ក) និង ៣. នៅថ្នាក់ភូមិ ។[៨៥]

- **ស្ត្រីក្នុងកិច្ចការរក្សាសន្តិភាព** កម្ពុជាជាប្រទេសនាំមុខគេប្រចាំតំបន់សម្រាប់ការចូលរួមរបស់ស្ត្រីក្នុងការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជាមួយនឹងភាគរយខ្ពស់បំផុតនៃកងរក្សាសន្តិភាពជាស្ត្រីក្នុងចំណោមប្រជាជាតិអាស៊ាន។ ស្ត្រីកម្ពុជាបានបម្រើក្នុងបេសកកម្មនានានៅអាហ្វ្រិក និងមជ្ឈិមបូព៌ា រួមចំណែកដល់ការដោះស្រាយជម្លោះ ជំនួយមនុស្សធម៌ និងការស្តារឡើងវិញក្រោយជម្លោះ។

- **ស្ត្រីក្នុងប្រតិបត្តិការដោះមីន៖** ផែនការបញ្ជ្រាបយេនឌ័រក្នុងវិស័យសកម្មភាពមីន (GMAP) ២០២១-២០២៥ មានគោលបំណងរួមបញ្ចូលការគិតគូរពីយេនឌ័រនៅគ្រប់ទិដ្ឋភាពទាំងអស់នៃសកម្មភាពដោះមីន។ ការលើកកម្ពស់ការចូលរួមស្មើភាពគ្នារបស់ស្ត្រីក្នុងសកម្មភាពដោះមីន និងដំណើរការនៃធ្វើការសម្រេចចិត្ត។ ផែនការនេះផ្តោតលើការអនុវត្តគោលការណ៍ណែនាំដែលគិតគូរលើយេនឌ័រ ការកសាងសមត្ថភាពក្នុងចំណោមភាគីពាក់ព័ន្ធ និងធានាការចូលរួមប្រកបដោយបរិយាបន្នក្នុងវិស័យកម្មភាពមីន រួមទាំងការគាំទ្រសម្រាប់ជនរងគ្រោះ និងគំនិតផ្តួចផ្តើមនានាទាក់ទងនឹងការអប់រំពីគ្រោះថ្នាក់មីន។

ស្ត្រីនៅសមរភូមិមុខ៖ ប្រតិបត្តិការ
រក្សាសន្តិភាព

ភាពជាអ្នកដឹកនាំរបស់ស្ត្រីនិង
ការពង្រឹងភាពអង់អាចក្នុងវិស័យ
នយោបាយ

តើមានឧទាហរណ៍អ្វីបន្ថែមទៀតដែល
អ្នកដឹង ទាក់ទងនឹងសសរស្តម្ភនៃការចូលរួម
នេះក្នុងបរិបទកម្ពុជា?

# ភាពជាតំណាងស្ត្រីក្នុងបេសកម្មរក្សាសន្តិភាព

កម្ពុជាបានលេចធ្លោជាអ្នកចូលរួមដ៏សំខាន់ក្នុង បេសកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជាពិសេសដោយមានការចូលរួមខ្ពស់ពីស្ត្រី។ ចាប់តាំងពីឆ្នាំ ២០០៦ ប្រទេសកម្ពុជាបានបញ្ជូនកងរក្សាសន្តិភាពជាង ៩២០០ នាក់ទៅកាន់បេសកម្មចំនួន ១២ នៅក្នុងប្រទេសចំនួន ១០ ដែលស្ត្រីមានសមាសភាពប្រហែល ៨,២%។ [៨៦]

ការប្តេជ្ញាចិត្តនេះបានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសអាស៊ានទីមួយ សម្រាប់ការបញ្ជូនស្ត្រីទៅបេសកម្មរក្សាសន្តិភាព ហើយឈរលេខរៀងទី ៩ ជាសកល ក្នុងចំណោមប្រទេសចូលរួម ១២៣។ នៅឆ្នាំ ២០២៤ សមាសភាពស្ត្រីក្នុងកងរក្សាសន្តិភាពកម្ពុជាបានឈានដល់ជាង ១៧% ដែលលើសគោលដៅរបស់អង្គការសហប្រជាជាតិឆ្នាំ ២០២៥ ដែលកំណត់ត្រឹម ១៥%។

ស្ត្រីរក្សាសន្តិភាពទាំងនេះបម្រើការងារក្នុងតួនាទីច្រើនប្រភេទ រួមមាន បុគ្គលិកវេជ្ជសាស្ត្រ កងសន្តិសុខ វិស្វករស៊ីវិល និងអ្នកជំនាញដោះមីន ដែលបានបង្កើនប្រសិទ្ធភាពនៃការប្រតិបត្តិការរក្សាសន្តិភាព តាមរយៈវិធីសាស្ត្រដែលគិតគូរលើយេនឌ័រ។ កងយោធពលខេមរភូមិន្ទ (RCAF) ក៏បានអនុវត្តកម្មវិធីបណ្តុះបណ្តាលជាក់លាក់ និងបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ ដើម្បីលើកស្ទួយភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងតួនាទីរក្សាសន្តិភាព។៨៧

ការផ្តោតជាយុទ្ធសាស្ត្រទៅលើបរិយាបន្នយេនឌ័រនេះ មិនត្រឹមតែធ្វើឲ្យកម្ពុជាមានមុខមាត់ខ្ពស់ក្នុងវិស័យរក្សាសន្តិភាពជាសកលទេ ប៉ុន្តែថែមទាំងជំរុញសារៈសំខាន់នៃតួនាទីស្ត្រីក្នុងការសម្រេចបានទូវសន្តិភាព និងសុវត្ថិភាពប្រកបដោយចីរភាពផងដែរ។

# ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការពង្រឹងភាពអង់អាចក្នុងវិស័យនយោបាយ

ទោះបីជាប្រជាជនកម្ពុជាច្រើនជាងពាក់កណ្តាលគឺជាស្ត្រី ក៏ស្ត្រីនៅតែមានភាពជាតំណាងតិចតួចខ្លាំងក្នុងតួនាទីដឹកនាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ នៅក្នុងការបោះឆ្នោតសកលឆ្នាំ២០២៣ ស្ត្រីទទួលបានតែ ១៣% ប៉ុណ្ណោះនៃអាសនៈរដ្ឋសភា ដែលជា ការធ្លាក់ចុះបើប្រៀបនឹងអណត្តិមុន ។[៨៨]

ជាការឆ្លើយតប រដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគំនិតផ្តួចផ្តើមមួយចំនួន ដូចជាផែនការយុទ្ធសាស្ត្រនារីរតនៈ (២០២៤-២០២៨) ដែលមានគោលបំណងលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រីលើវិស័យផ្សេងៗ ។[៨៩]

នៅកម្រិតថ្នាក់តំបន់ កម្ពុជាក៏បានជំរុញឱ្យមានតំណាងស្ត្រីកាន់តែច្រើនក្នុងការសម្រេចចិត្តតាមរយៈមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) ។[៩០]

នៅថ្នាក់ក្រោមជាតិ រដ្ឋាភិបាលបានកំណត់គោលដៅបង្កើនភាគរយនៃតួនាទីជាអ្នកដឹកនាំរបស់ស្ត្រីក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ដល់ចន្លោះពី ២៨% និង ៣៦% ត្រឹមឆ្នាំ២០២៨ រួមជាមួយនឹងការបង្កើនការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់ស្ត្រីទាំងនេះ ដើម្បីធានាបាននូវចំនួនសមស្របនៃអ្នកដឹកនាំស្ត្រីដែលមានសមត្ថភាព ។[៩១]

ទោះយ៉ាងណាក៏ដោយ ឧបសគ្គចម្បងៗនៅតែមាន។ បទដ្ឋានវប្បធម៌ចាក់ឫសយ៉ាងជ្រៅ នៅតែបន្តបំបាក់ទឹកចិត្តស្ត្រីពីតួនាទីជាអ្នកដឹកនាំ ខណៈដែលឧបសគ្គសេដ្ឋកិច្ចនិងការចូលរួមការបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំនិងការអប់រំបន្ថែមនៅមានកម្រិត ក៏ជាកត្តារឹតត្បិតឱកាសបន្ថែមទៀត។

បើគ្មានការវិនិយោគក្នុងគោលនយោបាយដែលគិតគូរយេនឌ័រ កម្មវិធីបង្វឹកនិងជំនួយហិរញ្ញវត្ថុសម្រាប់ស្ត្រីអ្នកដឹកនាំ ការសម្រេចបាននូវសមភាពយេនឌ័រនៅតែជាបញ្ហាប្រឈម។ កិច្ចខិតខំប្រឹងប្រែងប្រកបដោយនិរន្តរភាពទាំងរដ្ឋាភិបាលនិងសង្គមស៊ីវិលមានសារៈសំខាន់ណាស់ក្នុងការធានាថាសំឡេងស្ត្រីមកពីគ្រប់មជ្ឈដ្ឋានត្រូវបានយកចិត្តទុកដាក់ក្នុងការតម្រង់ទិសអនាគតប្រទេសកម្ពុជា។

# ករណីសិក្សាពីការអនុវត្តល្អៗ៖

## ការលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យអភិបាលកិច្ច

## អង្គការសីលការ

របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ទទួលស្គាល់ថា ការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រីក្នុងការគ្រប់គ្រង និងការសម្រេចចិត្ត គឺជាកត្តាចាំបាច់សម្រាប់កសាងសន្តិភាពប្រកបដោយនិរន្តរភាព។ អង្គការសីលការបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី រួមទាំង នៅថ្នាក់ក្រោមជាតិ តាមរយៈកម្មវិធីអ្នកដឹកនាំស្ត្រីនៅថ្នាក់ក្រោមជាតិ (WLSN) ។[៩២]

### ការកសាងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យអភិបាលកិច្ច

កម្មវិធីអ្នកដឹកនាំស្ត្រីនៅថ្នាក់ក្រោមជាតិ (WLSN) ផ្តោតលើការផ្តល់ភាពអង់អាចដល់អ្នកដឹកនាំស្ត្រីនិងសកម្មជនស្ត្រីវ័យក្មេង ដើម្បីចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាន ការបង្កើតគោលនយោបាយ និងការតស៊ូមតិ។ អនុវត្តក្នុងស្រុកចំនួនប្រាំបីនៅទូទាំងខេត្តចំនួនប្រាំមួយ កម្មវិធីនេះបានលើកកម្ពស់ជំនាញក្នុងការសម្រេចចិត្តរបស់ស្ត្រី សមត្ថភាពដឹកនាំ និងទំនុកចិត្តក្នុងការចូលរួមផ្នែកនយោបាយដោយជោគជ័យ។

### សកម្មភាពសំខាន់ៗរបស់កម្មវិធីរួមមាន៖

- **ការកសាងសមត្ថភាព** បណ្តុះបណ្តាលអ្នកដឹកនាំស្ត្រីស្តីពីអភិបាលកិច្ច សមភាពយេនឌ័រ និងការតស៊ូមតិផ្នែកគោលនយោបាយ។
- **ការកសាងទំនាក់ទំនងនិងការណែនាំ** ការពង្រឹងបណ្តាញមិត្តគាំទ្រមិត្តក្នុងចំណោមស្ត្រីក្នុងភាពជាអ្នកដឹកនាំ ដើម្បីបង្កើនការចាប់អារម្មណ៍និងឥទ្ធិពល។
- **ការតស៊ូមតិនិងការចូលរួមជាសាធារណៈ** ការរៀបចំវេទិកាសាធារណៈ យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមដោយផ្ទាល់ជាមួយអ្នកបង្កើតគោលនយោបាយ ដើម្បីលើកកម្ពស់ភាពជាតំណាងនិងសំឡេងរបស់ស្ត្រីក្នុងការសម្រេចចិត្ត។

### ផលប៉ះពាល់និងការរួមចំណែកដល់សសរស្តម្ភការចូលរួមរបស់របៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ

ដោយបានបំពាក់ជំនាញសម្រាប់ស្ត្រី កសាងបណ្តាញ និងទំនុកចិត្តក្នុងការចូលរួមក្នុងវិស័យអភិបាលកិច្ច កម្មវិធីអ្នកដឹកនាំស្ត្រីនៅថ្នាក់ក្រោមជាតិ គាំទ្រដោយផ្ទាល់ដល់សសរស្តម្ភការចូលរួមរបស់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ។ ការបង្កើនភាពជាតំណាងរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ នឹងពង្រឹងអភិបាលកិច្ចដែលឆ្លើយតបនឹងយេនឌ័រ ដោយធានាថាកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពនិងការអភិវឌ្ឍន៍ដោះស្រាយតម្រូវការនិងអាទិភាពរបស់ស្ត្រី។

ការងារកំពុងដំណើរការរបស់អង្គការសីលការបានរួមចំណែកដល់ការកសាងរចនាសម្ព័ន្ធនៃការសម្រេចចិត្តប្រកបដោយបរិយាបន្ន និងធ្វើឱ្យដំណើរការប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាកាន់តែរឹងមាំ ដែលជាទិដ្ឋភាពសំខាន់ស្តីពីការអនុវត្តរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ ។

អ្នកអាចអានបន្ថែមអំពីការងាររបស់អង្គការសីលការនៅទីនេះ៖ https://www.silaka.org/archives/our_projects/wlsn-2/

# ឯកសារយោង


1. Peace Women <https://www.peacewomen.org/why-WPS/solutions/resolutions>.
2. WILPF, '1325 NAPs: Liberia,' <https://1325naps.peacewomen.org/index.php/liberia/#:~:text=The%20most%20recent%20armed%20conflict,-multiple%20provisions%20addressing%20women's%20rights>.
3. Hudson, H., & Madsen, D. H. (2024). The Politics of Space and Relationality: Localization and the Women, Peace and Security Agenda in Uganda. Journal of Intervention and Statebuilding, 18(3), 346-366.
4. Office of the Philippine Presidential Adviser on the Peace, Reconciliation and Unit, 'NAPWPS,' <https://peace.gov.ph/national-action-plan-women-peace-security/>.
5. Netherlands Institute for Multiparty Democracy, (NIMD), Breaking new ground: Colombia's inclusive journey to a National Action Plan, <https://nimd.org/breaking-new-ground-colombias-inclusive-journey-to-a-national-action-plan/>.
6. Council on Foreign Relations (CFR), 'Women's Participation in Peace Processes,' <https://www.cfr.org/womens-participation-in-peace-processes/>.
7. CFR, ibid.
8. Crespo-Sancho, C. (2018, March 28). Can gender equality prevent violent conflict? World Bank Blogs, <https://blogs.worldbank.org/en/dev4peace/can-gender-equality-prevent-violent-conflict>.
9. Dialogue Institute. (2021). Report from WPS meeting on shrinking civic space. Embassy of Sweden. https://www.swedenabroad.se/globalassets/ambassader/dialogue-institute/documents/report-from-wps-meeting-on-shrinking-civic-space.pdf
10. NIMD, above n., 5.
11. Gender-Based Violence Area of Responsibility (UNFPA), Who We Are. <https://gbvaor.net/about-us#who-we-are>.
12. Women, Peace & Security and Humanitarian Action Compact, 'Home,' <https://wpshacompact.org/>.
13. WILPF, 'National Action Plans at a Glance,' <https://1325naps.peacewomen.org/>
14. PeaceWomen. 'National Action Plan (NAP) development toolkit,' Women's International League for Peace and Freedom (WILPF), <https://www.peacewomen.org/assets/file/national_action_plan_development_toolkit.pdf>.

15. UN, ‘Documents for Women, Peace and Security: Secretary-General’s Reports,’ <https://www.securitycouncilreport.org/un_documents_type/secretary-generals-reports/?ctype=Women%2C%20Peace%20and%20Security&cbtype=women-peace-and-security>.
16. GPPAC, ‘Developing National Action Plans on WPS: What role can civil society play?’ <https://www.gppac.net/news/developing-national-action-plans-wps-what-role-can-civil-society-play>
17. UN Women, ‘National Action Plans: Women, Peace and Security,’ <https://asiapacific.unwomen.org/en/focus-areas/peace-and-security/national-action-plans>.
18. Hutchison, S., ‘What does the Trump presidency mean for Women, Peace and Security?’ Lowy Institute, 23 January 2025, <https://www.lowyinstitute.org/the-interpreter/what-does-trump-presidency-mean-women-peace-security>
19. Jogensen, M., ‘Abandoning the rules-based order is no solution,’ The Interpreter, 28 January 20205, <https://www.lowyinstitute.org/the-interpreter/abandoning-rules-based-order-no-solution>.
20. GAPS UK, ‘Participation of Women in the Development of the Action Plan for Resolution 1325 in Colombia,’ <https://gaps-uk.org/wp-content/uploads/2024/10/LEAP4Peace-Colombia-paper-FINAL.pdf>.
21. Generations for Peace (GFP) ‘Generations For Peace to Address Gender-Based Violence in Schools,’ <https://www.generationsforpeace.org/en/generations-for-peace-to-address-gender-based-violence-in-schools-with-new-grant-from-u-s-embassy-in-uganda>.
22. Government of Sierra Leone, The Sierra Leone National Action Plan (SiLNAP) II (2019-2023) <https://1325naps.peacewomen.org/wp-content/uploads/2021/07/Sierra-Leone-2019-2023.pdf>.
23. UN Women, ‘Kenya unites women peacebuilders through new national network,’ 2 November 2021, <https://africa.unwomen.org/en/news-and-events/stories/2021/11/kenya-unites-women-peacebuilders-through-new-national-network>.
24. Groundswell International, ‘Community-Led Responses to Conflict in the Sahel: Displaced Families Finding Refuge through Agroecology,’ <https://www.groundswellinternational.org/blog/community-led-responses-to-conflict-in-the-sahel-agroecology/>.
25. Government of Sierra Leone, above n., 22.
26. Bacon, L. (2017). Liberia’s gender-sensitive police reform: Improving representation and responsiveness in a post-conflict setting. In Development Assistance for Peacebuilding (pp. 90-115). Routledge.
27. JASS, (2018) ‘Between a Rock and a Hard Place,’ <https://th.boell.org/sites/default/files/jass_sea_report_jan_2019_e-version.pdf>

28. Spotlight Initiative, ‘Establishing safe spaces to help end VAWG, Malawi,’ <https://www.spotlightinitiative.org/create-women-and-girls-safe-spaces>.
29. Nove Ukraine, ‘Support Educational Development in Ukraine, <https://novaukraine.org/project/educational-projects/>.
30. NIMD, above n., 5.
31. UN Women, ‘Women Building their Future Gender Breakthroughs in Post-Tsunami Aceh,’ <https://wrd.unwomen.org/sites/default/files/2021-11/19842_unifemenarsonacehgenderbreakthrough.pdf>.
32. UNFPA, ‘Mobile camps bring life-saving care to Nepal’s quake-affected,’ 2 June 2015, <https://www.unfpa.org/news/mobile-camps-bring-life-saving-care-nepals-quake-affected>.
33. Bhalla, N., ‘Rwanda’s genocide survivors find reconciliation, income in women’s cooperatives,’ Reuters, 12 April 2019, <https://www.reuters.com/article/world/rwandas-genocide-survivors-find-reconciliation-income-in-womens-cooperatives-idUSKCN1RO1SL/>.
34. The Nonviolence Project, ‘How Women Ended Liberia’s Civil War: Women of Liberia Mass Action for Peace,’ <https://thenonviolenceproject.wisc.edu/2024/02/04/how-women-ended-liberias-civil-war-women-of-liberia-mass-action-for-peace/>.
35. UNDP, ‘Launch of the Women Insider Mediators - Rapid Action Mobilization Platform (WIM-RAMP),’ <https://www.undp.org/philippines/news/bangsamoro-women-helm-peacebuilding-and-community-resilience-barmm>.
36. UN Women, ‘Gender-Sensitive Police Reform in Post-Conflict Societies, <https://www.unwomen.org/sites/default/files/Headquarters/Attachments/Sections/Library/Publications/2012/10/WPSsourcebook-04B-GenderSensitivePoliceReform-en.pdf>.
37. WOLA, ‘Imperfect Justice Is Still Justice for Wartime Rape Survivors in Guatemala,’ <https://www.wola.org/analysis/justice-wartime-rape-guatemala/>.
38. WILPF, ‘Introducing the WPS Global Study, <https://peacewomen.org/e-news/article/introducing-wps-global-study-highlights-part-1-context-and-framework>.
39. Finland Abroad, ‘Joint Statement by the co-chairs of the Group of Champions of YPS: Republic of Finland and the Hashemite Kingdom of Jordan,’ <https://finlandabroad.fi/web/un/nordic-statements/-/asset_publisher/7AjSWaX3YnO3/content/joint-statement-by-the-co-chairs-of-the-group-of-champions-of-yps-republic-of-finland-and-the-hashemite-kingdom-of-jordan/384951>.
40. Building Blocks for Peace Foundation (BBFP) ‘What We Do,’ <https://bbforpeace.org/programmes/>.

41. UNITAR, 'Youth-led Peace and Reconciliation in Colombia: a Transformational Approach,' <https://unitar.org/youth-led-peace-and-reconciliation-colombia-transformational-approach>.
42. Ministry of Foreign Affairs of Finland, 'Youth, Peace and Security Finland's National Action Plan,' https://youthapproved.rycowb.org/wp-content/uploads/2024/05/UM_2021_05.pdf>.
43. Gordon, E. (2022). Peacebuilding practitioners with caring responsibilities: Navigating COVID-19 challenges and opportunities to advance an ethics of care in peacebuilding. Global Change, Peace & Security, 34(2-3), 143-164.
44. Council of the European Union, 'EU Action Plan on Women, Peace and Security (WPS) 2019-2024,' <https://data.consilium.europa.eu/doc/document/ST-11031-2019-INIT/en/pdf>.
45. UNDP Serbia, 'Public Call for CSO initiatives promoting reconciliation and dialogue in the Western Balkans,' <https://www.undp.org/serbia/news/public-call-cso-initiatives-promoting-reconciliation-and-dialogue-western-balkans>.
46. ECDPM, 'How the women, peace and security agenda is integrated into the EU's gender action plan,' <https://ecdpm.org/application/files/3816/5538/7686/Women-Peace-Security-Agenda-Integrated-EU-Gender-Action-Plan-ECDPM-Briefing-Note-141-2021.pdf>.
47. UN, 'The state of Women Peace and Security Agenda in Africa,' <https://www.un.org/shestandsforpeace/content/state-women-peace-and-security-agenda-africa>.
48. ECOWAS, 'ECOWAS Commission Launches Guidelines on Women, Peace and Security' <https://ecowas.int/ecowas-commission-launches-guidelines-on-women-peace-and-security/>.
49. McAleese, M. K. M. (2018). WPS and the Organization of American States. The Oxford Handbook of Women, Peace, and Security, 413.
50. Inter-American Defense Board, 'Women, Peace and Security,' <https://jid.org/en/lineas/mujeres-paz-y-seguridad/>.
51. WILPF, 'Timor-Leste,' <https://1325naps.peacewomen.org/index.php/timor-leste/>.
52. Asia-Pacific Development, Diplomacy & Defence Dialogue, What does it look like for Australia to be a strategic partner on Women, Peace and Security with the Pacific (Canberra 2023): <www.asiapacific4d.com>.
53. ASEAN, 'ASEAN launches guidelines for member countries to adapt women, peace and security policy,' 14 December 2023, <https://wps.asean.org/stories/asean-launches-guidelines-for-member-countries-to-adapt-women-peace-and-security-policy/>.
54. ICAN, '24 Years After UNSCR 1325: Women, War, and Insecurity,' 30 October 2024, <https://icanpeacework.org/2024/10/24-years-after-unscr-1325/>.

55. RSIS, ‘Upscaling Disaster Resilience In Southeast Asia – Engaging Women Through The WPS Agenda,’ <https://www.rsis.edu.sg/wp-content/uploads/2018/03/PR180314_Upscaling-Disaster-Resilience_WEB.pdf>.
56. Asia-Pacific Forum on Women, Law and Development (APWLD), <https://apwld.org/>.
57. JASS, above n., 27.
58. UN Women, ‘The Global Study on 1325 Fact Sheet: Latin America and the Caribbean Region,’ <https://wps.unwomen.org/resources/r-fact-sheets/GS-FactSheet-LAC.pdf>.
59. JASS, above n., 27.
60. WPS ASEAN, ‘Women, Peace And Security in the Autonomous Region in Muslim Mindanao: A Civil Society Report,’ <https://wps.asean.org/resources/women-peace-and-security-in-the-autonomous-region-in-muslim-mindanao-a-civil-society-report/>.
61. WPS ASEAN, ‘Philippine National Action Plan on Women, Peace and Security 2023-2033,’ <https://wps.asean.org/resources/philippines-national-action-plan-on-women-peace-and-security-2023-2033/>.
62. McGrew, L., Frieson, K., & Chan, S. (2004, March). Good governance from the ground up: Women’s roles in post-conflict Cambodia. Women Waging Peace Policy Commission. <https://inclsvescurity.wpenginepowered.com/wp-content/uploads/2012/08/12_good_governance_from_the_ground_up_women_s_roles_in_post_conflict_cambodia.pdf>.
63. DFAT, ‘30th Anniversary of Cambodia’s Peace Agreements,’ <https://www.foreignminister.gov.au/minister/marise-payne/media-release/30th-anniversary-cambodias-peace-agreements>.
64. Peace Women Across the Globe, ‘Pung Chhiv Kek Galabru (Cambodia)’ <https://wikipeacewomen.org/wpworg/en/?page_id=1640>.
65. Som, S., ‘Woman officer to lead Blue Helmets to S Sudan,’ Khmer Times, 23 January 2025, <https://www.khmertimeskh.com/501627935/woman-officer-to-lead-blue-helmets-to-s-sudan/>.
66. Royal Government of Cambodia. (2024, June 18–20). Statement of Cambodia on enhancement of cooperation and assistance: Intersessional meeting, Geneva, <https://www.apminebanconvention.org/fileadmin/_APMBC-DOCUMENTS/Meetings/2024/IM24-4-Coop-Cambodia.pdf>.
67. UN Women, ‘New report identifies barriers and opportunities to increase the deployment of Cambodian women to UN Peacekeeping Operations,’ <https://asiapacific.unwomen.org/en/stories/press-release/2024/07/cambodian-women-to-un-peacekeeping-operations>

68. UN Women, ‘Report on Results of the Measuring Opportunities for Women in Peace Operations (MOWIP) Assessment, <https://asiapacific.unwomen.org/en/digital-library/publications/2024/07/mowip-2023-assessment>.
69. Gordon, E., above n., 43.
70. UN (2021) ‘The young Cambodian peacekeeper inspiring change: Paving the road to lasting peace amidst the pandemic,’ <https://cambodia.un.org/en/128883-young-cambodian-peacekeeper-inspiring-change-paving-road-lasting-peace-amidst-pandemic>.
71. UN Women, ‘New report identifies barriers and opportunities to increase the deployment of Cambodian women to UN Peacekeeping Operations,’ <https://asiapacific.unwomen.org/en/stories/press-release/2024/07/cambodian-women-to-un-peacekeeping-operations>.
72. UN Women, ‘ASEAN Regional Plan of Action on Women, Peace and Security,’ <https://asiapacific.unwomen.org/en/digital-library/publications/2022/12/asean-rpa-wps>.
73. UN Women, ‘ASEAN launches guidelines for member countries to adapt women, peace and security policy,’ <https://asiapacific.unwomen.org/en/stories/press-release/2023/12/asean-launches-localisation-toolkit-for-wps-policy>.
74. Women Peace Makers (WPM) ‘Preserving harmony, or preventing justice? A study of local dispute resolution practices in cases of domestic and intimate partner violence in Cambodia,’ <https://wpmcambodia.org/project/preserving-harmony-or-preventing-justice/>.
75. Women Peace Makers (WPM) ‘Voice & Visbility: A participatory exploration of Minority Women’s human rights in Cambodia,’ <https://wpmcambodia.org/wp-content/uploads/2024/07/Voice-and-Visibility_FPAR_report_2024.pdf>.
76. WPM, ibid.
77. Women Peace Makers (WPM) ‘Peace & Conflict Transformation Program,’ <https://wpmcambodia.org/peace-conflict-transformation-program/>.
78. Inclusive Development International, IDI, ‘Cambodia: Communities reach resolution with Mitr Phol, <https://www.inclusivedevelopment.net/cases/mitr-phol/>.
79. CCHR (2016) ‘Cambodia’s Women in Land Conflict,’ <https://www.cchrcambodia.org/en/publications/general-reports/116>
80. LICADHO, ‘No Punishment, No Protection: Cambodia’s Response to Domestic Violence,’ <https://www.licadho-cambodia.org/reports/files/225DV_Report_Eng_20171201.pdf>.
81. NGO CEDAW, ‘CEDAW Monitoring Report for 2022,’ <https://ngocedaw.org/wp-content/uploads/2023/12/2022-CEDAW-Monitoring-Report-EN.pdf>.

82. Chea, S., 'CENTRAL advises migrant workers of rights,' The Phnom Penh Post, 20 March 2023, <https://www.phnompenhpost.com/national/central-advises-migrant-workers-rights>.
83. ILO, 'Cambodia's labour migration governance framework,' <https://www.ilo.org/sites/default/files/2024-05/Cambodia-labour-migration-governance-framework-en-2024.pdf>
84. ActionAid Cambodia, 'Newsletter, May 2022,' <https://cambodia.actionaid.org/publications/2022/actionaid-cambodia-newsletter-may-2022-1>.
85. Ministry of Women's Affairs. (2024, June). Cambodia national report: On the occasion of the thirtieth anniversary of the Fourth World Conference on Women and the adoption of the Beijing Declaration and Platform for Action (1995). Royal Government of Cambodia. <https://www.unwomen.org/sites/default/files/2024-09/b30_report_cambodia_en.pdf>.
86. Ministry of Women's Affairs, ibid.
87. Ministry of Women's Affairs, above n., 86.
88. IPU Parline, 'Cambodia, National Assembly: Data on women,' <https://data.ipu.org/parliament/KH/KH-LC01/data-on-women/>.
89. Ministry of Women's Affairs & Australian Embassy Cambodia. (2024, April 10). 'Neary Rattanak VI Strategic Plan launches to bolster gender equality and empower women and girls' [Joint press release], <https://cambodia.embassy.gov.au/files/PENH/10042024-Joint-PR-Neary-Rattanak-VI-Strategic-Plan-MoWA-and-DFAT-English.pdf>.
90. Hang. P., 'Cambodia urges AIPA to boost women empowerment,' Khmer Times, 21 October 2024, <https://www.khmertimeskh.com/501577108/cambodia-urges-aipa-to-boost-women-empowerment/>.
91. Strategic Plan to Increase the Number of Women in Management Positions at the Sub-National Administrative Level for 2024-2028. (2024). <https://policypulse.org/wp-content/uploads/2025/06/declaration-on-the-implementation-of-the-strategic-plan-to-increase-the-number-of-women-in-management-positions-at-the-sub-national-administrative-level%E2%80%8B-for-2024-2028.pdf>
92. SILAKA, 'Women Leaders at Subnational Level,' <https://www.silaka.org/archives/our_projects/wlsn-2/>.

# តើទស្សនៈវិស័យសកលសម្រាប់សន្តិភាព សន្តិសុខ និងសមភាពយេនឌ័រអាចចាក់ឫសនៅក្នុងសហគមន៍ដែលធ្លាប់ឆ្លងកាត់ជម្លោះ និងភាពធន់ដោយរបៀបណា?

សៀវភៅណែនាំស្តីពីមូលដ្ឋានគ្រឹះនៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ នេះនឹងធ្វើការ ស្វែងយល់ពីសំណួរនេះតាមរយៈបរិបទដ៏ពិសេសរបស់ប្រទេសកម្ពុជា តាំងពីភាពជាអ្នកដឹកនាំ ក្នុងបេសកកម្ម រក្សាសន្តិភាព រហូតដល់កេរ្តិ៍ដំណែលនៃយុត្តិធម៌អន្តរកាល និងការកើនឡើងនៃកិច្ចខំប្រឹងប្រែងរបស់ស្ត្រីនៅមូលដ្ឋាន។ ដោយឈរលើគោលការណ៍នៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លេខ ១៣២៥ សៀវភៅណែនាំនេះនឹងផ្តល់នូវការឧទាហរណ៍ជាក់ស្តែង និងបរិបទជាក់លាក់សម្រាប់ការអនុវត្តរបៀបវារៈ ស្ត្រី សន្តិភាព និងសន្តិសុខ ឱ្យមានអត្ថន័យ និងផលជះវិជ្ជមាន។ តាក់តែងឡើងដោយផ្អែកតាមសសរស្តម្ភទាំងបួននៃរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ រួមមាន ការទប់ស្កាត់ ការការពារ ការចូលរួម និងការសង្គ្រោះនិងការស្តារឡើងវិញ សៀវភៅនេះបង្ហាញពីបញ្ហាប្រឈម និងភាពជោគជ័យក្នុងការធ្វើមូលដ្ឋានីយកម្មនៃក្របខ័ណ្ឌសកលនេះក្នុងបរិបទកម្ពុជា។ វារួមបញ្ចូលនូវទស្សនៈប្រសព្វដូចជា យុវជន និងសន្តិសុខអាកាសធាតុ និងផ្តល់នូវការណែនាំជាជំនួយស្មារតីសម្រាប់អ្នកតាក់តែងគោលនយោបាយ អង្គការសង្គមស៊ីវិល និងអ្នកកសាងសន្តិភាព។

មិនថាអ្នកជាប្រតិបត្តិករ អ្នកតស៊ូមតិ ឬអ្នកតាក់តែងគោលនយោបាយក៏ដោយ សៀវភៅនេះអាចជាឧបករណ៍ជំនួយស្មារតីសម្រាប់ផ្សារភ្ជាប់យុត្តិធម៌យេនឌ័រទៅនឹងចំណុចស្នូលនៃការកសាងសន្តិភាព និងអភិបាលកិច្ច។

អង្គការនារីដើម្បីសន្តិភាព
WOMEN PEACE MAKERS
organization

9 789924 625148 >